សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Science Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អនីតិជនក្នុងរឿងក្ដីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ៖ **លោក ហូ ស៊ីយ៉ុះ**
**កញ្ញា ឡឹក សុភារីកា**

សាស្ត្រាចារ្យណែនាំ
**លោក ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៧
ឆ្នាំចូលរៀន ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហូ ស៊ីយ៉រ** និងនាងខ្ញុំឈ្មោះ **ឡឹក សុភារិកា** ជានិស្សិតផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា ២០១៣-២០១៧ ជំនាន់ទី ១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាដំបូង ខ្ញុំបាទ និងនាងខ្ញុំ សូមថ្លែងអំណរគុណចំពោះ លោកឪពុក អ្នកម្តាយទាំងទ្វេរ ដែលបានបង្កើតរូបកាយកូន និងចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មាន និងឧបត្ថម្ភគ្រប់បែបយ៉ាងតាំងពីតូចដល់ធំ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត មិនគិតពីការនឿយហត់របស់លោកទាំងពីរនោះឡើយ ថែមទាំងបានឲ្យកូនបានរៀនសូត្រមានចំណេះដឹង រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។ គុណយ៉ាងធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុត ដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងពីរជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនៗ មានទំហំធំធេងរកអ្វីមកប្រៀបផ្ទឹមមិនបានឡើយ។ ទង្វើរបស់លោកទាំងពីរធ្វើឲ្យកូនៗ ចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបាន ហើយនឹងស្ថិតក្នុងដួងព្រលឹងរបស់កូនៗជារៀងដរាបគ្មានថ្ងៃសូន្យនោះឡើយ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការផ្តល់នូវពុទ្ធិល្អៗសម្រាប់ជាប្រទីបបំភ្លឺជីវិតយើងខ្ញុំ។

ជាពិសេសនោះ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ដែលជាសាស្ត្រាចារ្យណែនាំ ដើម្បីធ្វើឲ្យដំណើរការនៃការតាក់តែងសារណានេះឡើងប្រកបដោយជោគជ័យ។ លោកសាស្ត្រាចារ្យបានចំណាយទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ផ្តល់អនុសាសន៍ល្អៗ និងជួយកែលម្អនូវចំនុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឲ្យសារណាយើងខ្ញុំបានទទួលនូវលទ្ធផលយ៉ាងល្អប្រសើរ។

ជាចុងបញ្ចប់ យើងខ្ញុំគោរពជូនពរដល់ លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យទាំងអស់ឲ្យជួបតែ សេចក្តីសុខ សុខភាពល្អ អាយុយឺនយូរ ជៀសផុតពីរោគាព្យាធិ និងសត្រូវប៉ុនប៉ងធ្វើបាបឆ្ងាយជិតឲ្យវិនាសបាត់បង់។

# **អារម្ភកថា**

ឆ្លងកាត់ការសិក្សាអស់រយៈពេល ៤ ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គឺជាពេលវេលាដែលមានអត្ថន័យបំផុតសម្រាប់និស្សិតទាំងអស់ ដែលបានសិក្សានៅក្នុងជំនាន់ទី ១៧ និងជាពិសេសសម្រាប់ខ្ញុំបាទឈ្មោះ **ហូ ស៊ីឃ័រ** និងនាងខ្ញុំ **ឡឹក សុភារីកា** ។ ការដែលទទួលបានឱកាសក្លាយខ្លួនជានិស្សិតនៃសាកលវិទ្យាល័យនេះ គឺជាកិត្តិយសដ៏ក្រៃលែងសម្រាប់យើងខ្ញុំទាំងពីរនាក់ ហើយអ្វីដែលកាន់តែពិសេសទៀតនោះគឺសាកលវិទ្យាល័យ បានផ្តល់នូវឱកាសដល់យើងខ្ញុំ ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនេះ។ ហេតុដូច្នេះហើយ យើងខ្ញុំទាំងពីរនាក់ក៏បានព្រមព្រៀងមតិគ្នាជ្រើសរើសនូវប្រធានបទ " **អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ** " ។

ជាក់ស្តែង អនីតិជន គឺជាជនដែលងាយរងគ្រោះបំផុតក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដោយសារតែមូលហេតុនៃអាយុ ក៏ដូចជាចំណេះដឹង និងបទពិសោធន៍ឆ្លងកាត់ក្នុងជីវិតរបស់ពួកគេមានតិចតួច ដែលជាហេតុនាំឲ្យបុគ្គលទាំងនេះមានគំនិតគិតខ្លី ឆេវឆាវ ឬក៏ធ្វើការសម្រេចចិត្តដោយមិនមានហេតុផលច្បាស់លាស់ហើយចូលចិត្តប្រើកំលាំងដើម្បីតទល់ ឬដោះស្រាយបញ្ហាជាមួយគូបដិបក្ខរបស់ខ្លួន។ ប៉ុន្តែដោយហេតុតែអនីតិជន នៅក្មេងសេចក្តីបែបនេះហើយ ទើបជាហេតុនាំឲ្យសង្គមត្រូវផ្តោតការយកចិត្តទុកដាក់ ការការពារ និងធ្វើការកែតម្រូវ និងការអនុគ្រោះខ្លាំងបំផុតដល់ពួកគេ។ ជាក់ស្តែងយើងឃើញថា ពេលខ្លះអនីតិជនបានប្រព្រឹត្តកំហុស ក៏ប៉ុន្តែពួកគេនៅតែអាចមានសិទ្ធិទទួលបានឱកាសក្នុងការកសាងខ្លួនឡើងវិញ ដោយពួកគេអាចបានទទួលនូវការលើកលែងទោស ឬសម្រាលទោសឲ្យនូវតិចតួចបំផុត។ ទោះបីយ៉ាងណាក៏ដោយ មានករណីខ្លះអនីតិជនបែរជាត្រូវទទួលទោសព្រហ្មទណ្ឌយ៉ាងធ្ងន់ធ្ងរទៅវិញ។ ហេតុផលទាំងនេះហើយដែលជាមូលហេតុនាំឲ្យយើងខ្ញុំទាំងពីរនាក់ មានចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ ឲ្យបានស៊ីជម្រៅទៅលើផ្នែកសំខាន់ៗជាច្រើនដែលពាក់ព័ន្ធដូចជា ច្បាប់ទាំងឡាយដែលត្រូវបានយកមកអនុវត្តចំពោះអនីតិជន លំហូរនៃនីតិវិធីដែលអនុវត្តចំពោះអនីតិជន មូលហេតុនៃការទទួលទោស និងការលើកលែង និងការអនុវត្តទោស ។ល។

ប្រធានបទនេះត្រូវបានស្រាវជ្រាវពី ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ រហូតដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧។ ក្នុងរយៈពេលនេះ ខ្ញុំបាទ និងនាងខ្ញុំ បានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីស្រាវជ្រាវនូវឯកសារសំខាន់ៗជាច្រើនដែលពាក់ព័ន្ធ ដែលមានទាំងច្បាប់ជាតិ និងអន្តរជាតិ

ហើយបានចងក្រងឯកសារទាំងនោះបញ្ចូលគ្នា ដោយទទួលបានការផ្តល់ប្រឹក្សាយោបល់ពី **លោកសាស្ត្រាចារ្យ ហ៊ាង ឡេង** ទើបសារណាបញ្ចប់ការសិក្សាមួយនេះត្រូវបញ្ចប់ដោយជោគជ័យ។

ក្រោយពីបានស្រាវជ្រាវប្រធានបទនេះហើយ ខ្ញុំបាទ និងនាងខ្ញុំ សង្ឃឹម និងជឿជាក់ថា ចំណេះដឹង និងបទពិសោធន៍ទាំងឡាយដែលទទួលបានពីការស្រាវជ្រាវនេះ អាចឲ្យយើងខ្ញុំទាំងពីរនាក់ យកមកប្រើប្រាស់បានដើម្បីជាប្រយោជន៍សម្រាប់ខ្លួនផ្ទាល់ និងសង្គមជាតិទាំងមូលនាថ្ងៃអនាគត។ ម៉្យាងវិញទៀត ស្នាដៃនេះនឹងអាចក្លាយជាឯកសារជំនួយក្នុងការស្រាវជ្រាវរបស់សិស្សនិស្សិតជំនាន់ក្រោយ ឬបុគ្គលទាំងឡាយណា ដែលមានបំណងចង់សិក្សា ស្វែងយល់ និងទទួលបានចំណេះដឹង បន្ថែមលើប្រធានបទនេះ ក៏ដូចជាប្រធានបទដែលពាក់ព័ន្ធ ឬប្រហាក់ប្រហែល។

# មាតិកា


**សេចក្តីផ្តើម** .......... ១

**ជំពូកទី ១ ៖ ការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវរបស់អនីតិជន** .......... ៥

**១. ១. លក្ខខណ្ឌគតិយុត្តនៃការទទួលខុសត្រូវព្រហ្មទណ្ឌ** .......... ៥

១. ១. ១. លក្ខខណ្ឌទាក់ទងនឹងធាតុផ្សំនៃបទល្មើស .......... ៥

១. ១. ១. ១. ធាតុនីត្យានុកូល ឬធាតុច្បាប់ .......... ៥

១. ១. ១. ២. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ .......... ៦

១. ១. ១. ៣. ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ .......... ៧

១. ១. ២. លក្ខខណ្ឌទាក់ទងនឹងអាយុរបស់អនីតិជន .......... ៨

**១. ២. ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី** .......... ១០

១. ២. ១. លក្ខខណ្ឌនៃការទាមទារសំណងនៃការខូចខាត .......... ១០

១. ២. ២. បុគ្គលដែលត្រូវទទួលខុសត្រូវ .......... ១២

១. ២. ២. ១. កាតព្វកិច្ចរបស់តតិយជន .......... ១២

១. ២. ២. ២. ការទទួលខុសត្រូវដោយសាមគ្គីភាព .......... ១៣

**១. ៣. ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ** .......... ១៣

១. ៣. ១. លក្ខខណ្ឌទាក់ទងនឹងអាយុ .......... ១៣

១. ៣. ២. លក្ខខណ្ឌផ្សេងៗ .......... ១៥

១. ៣. ២. ១. បទល្មើសអំពើអូសទាញ .......... ១៦

១. ៣. ២. ២. បទល្មើសរួមភេទជាមួយអនីតិជនក្រោម ១៥ ឆ្នាំ .......... ១៧

១. ៣. ២. ៣. បទល្មើសអាសប្រព្រឹត្តទៅលើអនីតិជនក្រោម ១៥ ឆ្នាំ .......... ១៨

**ជំពូកទី ២ ៖ លំហូរនីតិវិធី ដែលត្រូវអនុវត្តចំពោះអនីតិជន** .......... ២០

**២. ១. ដំណាក់កាលនគរបាលយុត្តិធម៌** .......... ២០

២. ១. ១. សិទ្ធិអំណាចនៅទីកន្លែងកើតហេតុ .......... ២០

២. ១. ១. ១.  ការចាប់ខ្លួនអនីតិជន ........................................ ២០
២. ១. ១. ២.  ការឆែកឆេរខ្លួនអនីតិជន ........................................ ២១
២. ១. ១. ៣.  ការឃាត់ខ្លួនអនីតិជន ........................................ ២១
២. ១. ២.  កាតព្វកិច្ចរបស់នគរបាលយុត្តិធម៌នៅប៉ុស្តិ៍នគរបាល ........................................ ២៣
២. ១. ៣.  សិទ្ធិជាមូលដ្ឋានរបស់អនីតិជន ........................................ ២៣
២. ១. ៤.  នីតិវិធីនៃការស្តាប់ចម្លើយ ........................................ ២៤
២. ១. ៤. ១. បញ្ជី និងកំណត់ហេតុស្តីពីការឃាត់ខ្លួន ........................................ ២៥
២. ១. ៤. ២. កំណត់ហេតុសរុបនៃការឃាត់ខ្លួន ........................................ ២៦
**២. ២.  ដំណាក់កាលអយ្យការ** ........................................ ២៦
២. ២. ១.  ការពិនិត្យអំពីអត្ថិភាព ឬនត្ថិភាពនៃអាយុរបស់អនីតិជន ........................................ ២៧
២. ២. ២.  ការស្តាប់ចម្លើយ ........................................ ២៧
២. ២. ៣.  ការបង្វែរ ........................................ ២៨
២. ២. ៣. ១.  លក្ខខណ្ឌអប្បបរមានៃការបង្វែរ ........................................ ២៩
២. ២. ៣. ២.  លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ ........................................ ២៩
២. ២. ៣. ៣.  នីតិវិធីនៃការបង្វែរ ........................................ ៣០
២. ២. ៣. ៤.  អ្នកទទួលបន្ទុកក្នុងការបង្វែរ ........................................ ៣១
**២. ៣.  ដំណាក់កាលចៅក្រមស៊ើបសួរ** ........................................ ៣៣
២. ៣. ១.  តួនាទីរបស់ចៅក្រមស៊ើបសួរ ........................................ ៣៣
២. ៣. ១. ១.  សមត្ថកិច្ចនៃការស៊ើបសួរ ........................................ ៣៤
២. ៣. ១. ២.  ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ ........................................ ៣៤
២. ៣. ១. ៣.  ការស្តាប់ចម្លើយ ........................................ ៣៤
២. ៣. ២.  អំណាចរបស់ចៅក្រមស៊ើបសួរ ........................................ ៣៥
២. ៣. ២. ១.  ការព្យួរការសិក្សា ឬការងាររបស់អនីតិជន ........................................ ៣៦

២. ៣. ២. ២. អំណាចក្នុងការបង្វែរ ............ ៣៦
២. ៣. ២. ៣. ការឃុំខ្លួនបណ្ដោះអាសន្ន ............ ៣៧
២. ៣. ២. ៣. ក. មូលហេតុនៃការឃុំខ្លួន ............ ៣៧
២. ៣. ២. ៣. ខ. ថេរវេលានៃការឃុំខ្លួន ............ ៣៧
២. ៣. ២. ៤. ការដោះលែងឲ្យនៅក្រៅឃុំ ............ ៣៨
២. ៣. ២. ៤. ក. ឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ ............ ៣៩
២. ៣. ២. ៤. ខ. បណ្ដឹងរបស់ព្រះរាជអាជ្ញា ............ ៣៩
២. ៣. ២. ៤. គ. បណ្ដឹងរបស់ជនត្រូវចោទ ............ ៣៩
២. ៣. ២. ៥. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ............ ៤០
**២. ៤. ដំណាក់កាលសវនាការរបស់ចៅក្រមជំនុំជម្រះ ............ ៤១**
២. ៤. ១. សមត្ថកិច្ចរបស់តុលាការជាន់ទាប ............ ៤២
២. ៤. ១. ១. នីតិវិធីមុនសវនាការ ............ ៤២
២. ៤. ១. ២. នីតិវិធីសវនាការ ............ ៤២
២. ៤. ២. សមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់ ............ ៤៣
២. ៤. ២. ១. ការប្ដឹងទៅតុលាការជាន់ខ្ពស់ ............ ៤៤
២. ៤. ២. ២. ការទទួលបានសិទ្ធិអាទិភាពជំនុំជម្រះមុន ............ ៤៤
**ជំពូកទី ៣ ៖ ការប្រកាសទោស និងការអនុវត្តទោសចំពោះអនីតិជន ............ ៤៦**
**៣. ១. របបនៃការប្រកាសទោស ............ ៤៦**
៣. ១. ១. ការប្រកាសមូលទោស ............ ៤៦
៣. ១. ២. ការប្រកាសទោសបន្ថែម ............ ៥១
៣. ១. ៣. ការប្រកាសទោសជំនួស ............ ៥២
៣. ១. ៣. ១. ការប្រកាសទោសការងារសហគមន៍ ............ ៥២
៣. ១. ៣. ២. ការប្រកាសទោសស្ដីបន្ទោស ............ ៥៣

៣. ១. ៤. ការប្រកាសទោសព្យួរទោសសាកល្បង ........ ៥៣

**៣. ២. ការអនុវត្តទោសក្នុងពន្ធនាគារ ឬមណ្ឌលឃុំនីតិសម្បទា** ........ ៥៦

៣. ២. ១. លក្ខខណ្ឌនៃការឃុំខ្លួន ........ ៥៦

៣. ២. ២. សិទ្ធិរបស់អនីតិជនក្នុងអំឡុងពេលអនុវត្តទោស ........ ៥៧

**៣. ៣. ការផ្តល់ និងការស្តារនីតិសម្បទា** ........ ៥៨

៣. ៣. ១. ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ ........ ៥៩

៣. ៣. ២. ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់ ........ ៦០

៣. ៣. ៣. សមត្ថកិច្ចគ្រប់គ្រងមណ្ឌលឃុំនីតិសម្បទា ........ ៦០

៣. ៣. ៣. ១. ភ្នាក់ងារក្នុងមណ្ឌលឃុំនីតិសម្បទា ........ ៦១

៣. ៣. ៣. ២. ការធ្វើអធិការកិច្ចមណ្ឌលឃុំនីតិសម្បទា ........ ៦២

**៣. ៤. ការដោះលែងដោយមានលក្ខខណ្ឌ** ........ ៦២

៣. ៤. ១. លក្ខខណ្ឌទាក់ទងនឹងបុគ្គល ........ ៦២

៣. ៤. ២. លក្ខខណ្ឌទាក់ទងនឹងគំនិត មារយាទ និងការទទួលរងទោស ........ ៦២

៣. ៤. ៣. អាជ្ញាធរមានសមត្ថកិច្ចដែលផ្តល់ការដោះលែងដោយមានលក្ខខណ្ឌ ........ ៦៣

**សេចក្តីសន្និដ្ឋាន** ........ ៦៥

**អនុសាសន៍** ........ ៦៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. បុព្វហេតុនៃការសិក្សា

នៅតាមបណ្តាប្រទេសជុំវិញពិភពលោក មិនថាប្រទេសនោះ មានរបបនៃការដឹកនាំសង្គមរបស់ខ្លួន បែបកុម្មុយនីសត្តិ ឬបែបប្រជាធិបតេយ្យក្តី គេតែងតែបង្កើតច្បាប់សម្រាប់គ្រប់គ្រងសង្គម ដើម្បីកុំឲ្យសង្គមរបស់ខ្លួនមានភាពអាណាធិបតេយ្យ គ្មានរបៀបរៀបរយ អសន្តិសុខ គ្មានសណ្តាប់សាធារណៈ ឬមានការប្រើប្រាស់សិទ្ធិ ដែលច្បាប់ផ្តល់ឲ្យខ្លួនហួសដែនកំណត់ជាដើម។ ប្រទេសមួយចំនួន បានបង្កើតឲ្យមានវិធាននៃការទទួលខុសត្រូវចំពោះអំពើមួយចំនួន មិនថាជាប្រជាពលរដ្ឋរបស់ខ្លួន ឬជនបរទេស ដែលបានប្រព្រឹត្តអំពើណាមួយ ដែលបានប៉ះពាល់ដល់សង្គម ឬប្រទេសរបស់គេត្រូវតែទទួលខុសត្រូវចំពោះអំពើនោះ ហើយក៏មានទណ្ឌកម្មជាច្រើនដើម្បីយកមកអនុវត្តចំពោះបុគ្គលទាំងនោះមានដូចជា៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ, ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ចំពោះជនរងគ្រោះ ឬរដ្ឋជាអាទិ៍។ ផ្ទុយទៅវិញ បណ្តាប្រទេសមួយចំនួនក៏មិនតម្រូវឲ្យមានការទទួលខុសត្រូវចំពោះអំពើមួយចំនួនផងដែរ ដោយសារតែប្រទេសទាំងនោះ មានការរីកចម្រើនលើគ្រប់វិស័យ មិនថាសេដ្ឋកិច្ច ពាណិជ្ជកម្ម ការអប់រំ ជាពិសេសសម្បូរទៅដោយសម្បត្តិធម្មជាតិ (រ៉ែត្បូង, រ៉ែថ្មដុង, រ៉ែមាស, ឬរ៉ែប្រេងកាត) ជាហេតុធ្វើឲ្យប្រទេសសម្បូរអ្វីគ្រប់បែបយ៉ាង។ ដូច្នេះ បានជាសង្គមរបស់គេបានចាត់ទុកថាអំពើ ដែលមានលក្ខណៈបង្កឲ្យមានការខូចខាតមិនសូវធ្ងន់ធ្ងរ មិនចាត់ទុកថាជាអំពើដែលច្បាប់ហាមឃាត់ ហើយក៏មិនតម្រូវឲ្យមានការទទួលខុសត្រូវចំពោះអំពើនោះផងដែរ។

ជាក់ស្តែងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលបុគ្គលម្នាក់ បានប្រព្រឹត្តបទល្មើស មិនថាបុគ្គលនោះជា នីតិជនក្តី ឬអនីតិជនក្តី គឺតម្រូវឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬសំណងរដ្ឋប្បវេណីចំពោះជនរងគ្រោះ ឬការដាក់ទណ្ឌកម្មផ្សេងៗទៀត តាមរយៈការដាក់ពន្ធនាគារ ដើម្បីយកបុគ្គលនោះមកធ្វើការអប់រំណែនាំ ឲ្យដឹងពីកំហុសខ្លួននិងបន្ទាប់ពីការអនុវត្តទោសរួចហើយ នោះនឹងបញ្ជូនជននោះទៅរស់នៅក្នុងសង្គមវិញ ដើម្បីធ្វើជាពលរដ្ឋល្អដែលមានប្រយោជន៍សម្រាប់សង្គម គ្រួសារ មិត្តភក្តិជាដើម។ ប៉ុន្តែការតម្រូវឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងការដាក់ទណ្ឌកម្មផ្សេងៗទៀត ចំពោះនីតិជនក្តី ឬអនីតិជនក្តី តម្រូវឲ្យគោរពនូវលក្ខខណ្ឌមួយចំនួន ដែលច្បាប់បានកំណត់ផងដែរ។ តួយ៉ាងនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវចំពោះបុគ្គលទាំងពីរនេះ គឺឃើញថាមាន លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ របបនៃការប្រកាសទោសសម្រាប់បុគ្គល

ទាំងពីរ និងជាពិសេសនោះគឺ នីតិវិធីនៃការអនុវត្តទោសចាប់តាំងពីដំណាក់កាលនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលជំនុំជម្រះ និងការអនុវត្តទោសនោះ គឺមានភាពខុសគ្នាយ៉ាងច្រើនផងដែរ។

ការតម្រូវឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ គឺក្នុងគោលបំណងឲ្យបុគ្គល ដែលបានប្រព្រឹត្ត អំពើល្មើសច្បាប់ព្រហ្មទណ្ឌ ទទួលខុសត្រូវនូវអំពើរបស់ខ្លួន ដែលបានប្រព្រឹត្តនោះតាមរយៈការដាក់ពន្ធនាគារ ឬការទទួលខុសត្រូវក្នុងការសងសំណងនៃការខូតខាតដល់ជនរងគ្រោះ ឬបង់ប្រាក់ពិន័យចូលរដ្ឋ ឬវិធានការផ្សេងៗក្រៅពីការដាក់ពន្ធនាគារ និងជាពិសេសក៏បានរួមចំណែកក្នុងការបង្ការកុំឲ្យមានបទល្មើសកើតឡើងផងដែរ។ មានន័យថា ពេលដែលប្រជាពលរដ្ឋនៅក្នុងសង្គមនោះបានប្រព្រឹត្តបទល្មើស គឺពួកគាត់នឹងត្រូវបានគេដកហូតនូវសិទ្ធិសេរីភាពរបស់ខ្លួន តាមអំណាចនៃសាលក្រម ឬសាលដីកានៃតុលាការជាន់ខ្ពស់ ដែលមានការកំណត់អំឡុងពេលមួយច្បាស់លាស់។ បន្ថែមពីលើនេះទៀត គេនឹងត្រូវមានឈ្មោះថាជា ទណ្ឌិត ដែលជាហេតុអាចធ្វើឲ្យទំនាក់ទំនងនៅក្នុងសង្គម គ្រួសារ មិត្តភក្តិ និងញាតិជិតខាង ដែលខ្លួនធ្លាប់មានទំនាក់ទំនងជាមួយ មានភាពមិនសូវស្និតស្នាលដូចមុន ឬអាចកាត់ផ្តាច់នូវទំនាក់ទំនងជាមួយខ្លួនផងដែរ។

នៅពេលដែលសង្គមគ្មានភាពអាណាធិបតេយ្យ អសន្តិសុខសង្គម ឬគ្មានរបៀបរៀបរយ គ្មានបទល្មើសកើតឡើង ប្រជាពលរដ្ឋក្នុងសង្គមបានយល់ដឹងពីច្បាប់ និងគោរពច្បាប់ ដែលរដ្ឋបង្កើតឡើង និងធ្វើឲ្យការដឹកនាំសង្គមមួយក្លាយទៅជាប្រទេសនីតិរដ្ឋ។ មួយវិញទៀត វានឹងក្លាយទៅជាប្រទេសមួយដែលធ្វើអ្វីមួយយកច្បាប់ជាធំ ដែលអាចទាក់ទាញអ្នកវិនិយោគទុនគ្រប់បណ្តាប្រទេសមកដាក់ទន់វិនិយោគនៅក្នុងប្រទេសរបស់ខ្លួន ហើយក៏បានរួមចំណែកក្នុងការផ្តល់ឱកាសការងារជាច្រើនដល់ពលរដ្ឋរបស់ខ្លួនមានការងារធ្វើ ដែលជាហេតុបានធ្វើឲ្យបទល្មើសមានការកាត់បន្ថយ ឬស្ទើរតែគ្មានបទល្មើសណាមួយកើតឡើងនោះទេ ដោយសារតែមានថវិកាសម្រាប់ចិញ្ចឹមខ្លួនឯងគ្រួសារជាដើម ហើយនឹងអាចធ្វើឲ្យសង្គមរបស់ខ្លួនមានអភិវឌ្ឍន៍លើគ្រប់វិស័យជាដរាប។

## ២. ចំណោទបញ្ហា

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន មានសារៈសំខាន់ណាស់ដោយសារតែវាតម្រូវឲ្យមានការដកហូតនូវសិទ្ធិសេរីភាព ឬមានវិធានការផ្សេងៗដល់បុគ្គលទាំងនោះ នៅក្នុងរយៈពេលណាមួយដែលច្បាប់បានកំណត់។ នៅពេលដែលអនីតិជននោះ ត្រូវបានគេដកហូតនូវសិទ្ធិសេរីភាព ដែលច្បាប់ជាតិ ក៏ដូចជាច្បាប់អន្តរជាតិ ដែលបានធ្វើការការពារបុគ្គលទាំងនោះ វានឹងធ្វើឲ្យតម្លៃនៃច្បាប់ទាំងនោះថយចុះ។ ក៏ប៉ុន្តែនេះមិនមែនមានន័យថា ច្បាប់មិនអនុញ្ញាតឲ្យមានការដកហូតនូវ

សិទ្ធិសេរីភាពរបស់អនីតិជននោះទេ។ នៅពេលដែលបុគ្គលទាំងអស់នោះ បានប្រព្រឹត្តអំពើណាមួយដែលបានប៉ះពាល់ដល់សមាជិកនៃសង្គមនោះ ឬច្បាប់នៃប្រទេសនោះ នឹងធ្វើឲ្យច្បាប់ជាតិ និងច្បាប់អន្តរជាតិអនុញ្ញាតអោយមានការដកហូតសិទ្ធិរបស់អនីតិជនទាំងនោះបានផងដែរ។ គោលបំណងនៃការដកហូតនោះ គឺដើម្បីយកបុគ្គលទាំងនោះទៅធ្វើការអប់រំ ណែនាំ និងបញ្ជូនឲ្យមកចូលរស់នៅក្នុងសង្គមវិញ និងដើម្បីឲ្យក្លាយទៅជាពលរដ្ឋល្អនៅក្នុងសង្គម ក្លាយទៅជាសិស្សល្អសម្រាប់លោកគ្រូអ្នកគ្រូ និងក្លាយខ្លួនជាកូនល្អសម្រាប់ឪពុកម្តាយ ឬអ្នកអាណាព្យាបាល។

ហេតុដូច្នេះ ប្រធានបទស្តីពី "**អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ**" ត្រូវបានជ្រើសរើស និងធ្វើការតាក់តែងឡើងដើម្បីបង្ហាញឲ្យសិស្ស និងនិស្សិតជំនាន់ក្រោយ ក៏ដូចជាសាធារណៈជន ដែលចង់ស្វែងយល់ អាចធ្វើការស្រាវជ្រាវបានកាន់តែយល់ច្បាស់លាស់ថែមទៀត ថាតើមានលក្ខខណ្ឌអ្វីខ្លះដែលអាចនាំឲ្យអនីតិជនទទួលខុសត្រូវព្រហ្មទណ្ឌ និងនីតិវិធីនៃការអនុវត្តចំពោះអនីតិជនមានអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវ រៀបចំតាក់តែងនូវឯកសារ និងធ្វើការចងក្រងនេះឡើង គឺក្នុងគោលបំណងដើម្បីជាការបកស្រាយនូវចម្ងល់, ធ្វើការពង្រីកនូវចំណេះដឹងបន្ថែម និងទុកជាស្នាដៃសម្រាប់ខ្លួនឯង និងជាពិសេសនោះគឺ ទុកជាឯកសារសម្រាប់ឲ្យសិស្ស និស្សិតជំនាន់ក្រោយ និងចំពោះសាធារណៈជនទាំងឡាយដែលមានបំណងចង់ធ្វើការសិក្សា និងស្វែងយល់អំពីប្រធានបទនេះ អាចយល់កាន់តែច្បាស់លាស់ថែមទៀត។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅនឹងប្រធានបទ ដែលបានលើកឡើងក្នុងចំណោទបញ្ហាខាងលើនេះ សារណានេះត្រូវបានធ្វើការសិក្សាស្រាវជ្រាវទៅលើឯកសារជាមូលដ្ឋានគឺ ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ និងឯកសាររួមផ្សំដែលពាក់ព័ន្ធទាំងឡាយ ដែលបានលើកឡើងនៅក្នុងឯកសារយោងស្រាប់ ដើម្បីសរសេរសារណានេះឡើង។

នៅក្នុងការសរសេរសារណានេះ គឺបានលើកឡើងតែពីការពាក់ព័ន្ធទាំងឡាយណា ដែលទាក់ទងជាមួយនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន នីតិវិធីដែលត្រូវយកមកអនុវត្តចំពោះអនីតិជន និងទោសដែលអនីតិជនត្រូវទទួលប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ការសរសេរសារណានេះ ត្រូវបានធ្វើការសិក្សាបែបពិពណ៌នា។ ហើយតាមរយៈនៃការសិក្សាស្រាវជ្រាវនេះដែរ គឺត្រូវបានធ្វើឡើងតាមរយៈការប្រមូលនូវទិន្នន័យ និងព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងប្រធានបទសារណានេះ ពីស្ថាប័នមានសមត្ថកិច្ច ដែលរួមមានដូចជា សាលាដំបូងរាជធានីភ្នំពេញ, តុលាការកំពូល និងក្រុមហ៊ុនមេធាវី ដើម្បីធ្វើឲ្យខ្លឹមសារនៃសារណានេះមានភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាពកាន់តែប្រសើរឡើង។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

សារណានេះ គឺអាចធ្វើឲ្យបងប្អូន ក៏ដូចជាសិស្សានុសិស្ស និស្សិត និងសាធារណៈជនដទៃទៀតទុកជាឯកសារជំនួយស្មារតី និងជាចំណេះដឹងបន្ថែម ដល់ការសិក្សាស្រាវជ្រាវរបស់ខ្លួន និងយល់ដឹងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ថាតើមានភាពដូចគ្នា ឬខុសគ្នាយ៉ាងដូចម្តេចទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន ក៏ដូចជាលក្ខខណ្ឌផ្សេងៗនៃការទទួលខុសត្រូវព្រហ្មទណ្ឌ របបនៃការប្រកាសទោសសម្រាប់អនុវត្តលើអនីតិជន និងនីតិវិធីនៃការអនុវត្តចាប់តាំងពីដំណាក់កាលនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលនៃការជំនុំជម្រះមានអ្វីខ្លះ?

សារណានេះក៏បានបញ្ចូលបន្ថែមនូវឯកសារផ្លូវការ ដែលមានអត្ថប្រយោជន៍ និងអាចជឿជាក់បានមួយចំនួន ដើម្បីទុកជាឧទាហរណ៍ជាក់ស្តែងឲ្យសាធារណៈជន ដែលមានចំណាប់អារម្មណ៍ចង់ធ្វើការស្រាវជ្រាវបន្ថែមងាយស្រួលយល់។ ឯកសារទាំងនោះ បានចងក្រងនៅផ្នែកឧបសម្ព័ន្ធ ដែលមានដូចជា ប្រភេទនៃកំណត់ហេតុ (ទទួលវត្ថុចាប់យក, សួរចម្លើយ និងស្តាប់ចម្លើយ), ប្រភេទនៃដីកាដែលចេញដោយព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ, សាលក្រមសាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាតុលាការកំពូល។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ ត្រូវបានធ្វើការបែងចែកជា ៣ ជំពូក៖

ជំពូកទី ១៖ ការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវរបស់អនីតិជន

ជំពូកទី ២៖ លំហូរនីតិវិធី ដែលត្រូវអនុវត្តចំពោះអនីតិជន

ជំពូកទី ៣៖ ការប្រកាសទោស និងការអនុវត្តទោសចំពោះអនីតិជន

# ជំពូកទី ១ ៖ ការទទួលខុសត្រូវ និងការមិនទទួលខុសត្រូវរបស់អនីតិជន

## ១. ១. លក្ខខណ្ឌគតិយុត្តនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

ដើម្បីឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើល្មើសណាមួយបាននោះ តម្រូវឲ្យមានច្បាប់ចែងយ៉ាងជាក់លាក់ថា អំពើនោះជាបទល្មើសហើយមានទណ្ឌកម្មដូចជាការដាក់ពន្ធនាគារ ឬការពិន័យជាប្រាក់ ឬមានទណ្ឌកម្មផ្សេងៗទៀត ដែលទាញចេញពីគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស។ ដូច្នេះ ដើម្បីអាចឲ្យអនីតិជនណាមួយ ទទួលខុសត្រូវចំពោះអំពើណាមួយបានលុះត្រាតែមាន ធាតុផ្សំនៃបទល្មើស (១.១.១) និងលក្ខខណ្ឌអាយុរបស់អនីតិជន (១.១.២) ត្រូវបានបំពេញ។

### ១. ១. ១. លក្ខខណ្ឌទាក់ទងនឹងធាតុផ្សំនៃបទល្មើស

មានមតិខ្លះបានលើកឡើងថា ធាតុផ្សំនៃបទល្មើសមានតែពីរប៉ុណ្ណោះ គឺធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័ត ចំណែកឯធាតុផ្សំនីត្យានុកូលស្ថិតនៅក្រៅបទល្មើសទេ។ ច្បាប់ពុំមែនជាធាតុផ្សំនៃបទល្មើសទេ គឺអង្គហេតុ និងចេតនារបស់ចារីដែលជាធាតុផ្សំនៃបទល្មើស[1]។ ជាគោលការណ៍បទល្មើសព្រហ្មទណ្ឌមួយកើតឡើងបាន លុះត្រាតែមានធាតុសំខាន់ៗដូចខាងក្រោម៖

#### ១. ១. ១. ១. ធាតុនីត្យានុកូល ឬ ធាតុច្បាប់

ដើម្បីអាចចាត់ទុកថាអំពើណាមួយជាបទល្មើស ដែលមានន័យថាជាអំពើប្រឆាំងនឹងរដ្ឋ អំពើដែលនាំឲ្យមានគ្រោះថ្នាក់ដល់សង្គម អំពើប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន និងត្រូវផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុនោះ លុះត្រាតែអំពើនោះមានចែងយ៉ាងជាក់លាក់នៅក្នុងច្បាប់ថាជាបទល្មើស បើមិនដូច្នេះទេតុលាការមិនអាចផ្តន្ទាទោសទៅលើបុគ្គលនោះបានឡើយ។ ហេតុនេះហើយបានជាគេមានគោលការណ៍មួយដែលនិយាយថា "គ្មានបទល្មើសណាមួយដែលច្បាប់មិនបានចែងនោះទេ[2]"។ ដោយច្បាប់បានប្បញ្ញត្តិថា អំពើខ្លះរបស់រូបវន្តបុគ្គល ដែលបង្កចលាចលដល់សង្គមជាបទល្មើស ហើយមានតែអំពើដែលបានបង្កើតជាបទល្មើស នៅពេលដែលអំពើនោះ មានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបអាចផ្តន្ទាទោសបាន[3]។

[1] រុន ពណ្ណារិទ្ធិ, ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០១២ ទំព័រ ៩៧

[2] ហ៊ាង ឡេង, នីតិព្រហ្មទណ្ឌទូទៅ ទំព័រ ១២

[3] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៧, លេខរាង ១០១ ៖ ច្បាប់ ឬវិធានទាំងឡាយដែលកំណត់ពីការទទួលខុសត្រូវលើបទល្មើសនឹងការដាក់ទោស

បន្ទាប់ពីមានច្បាប់ចែងថាអំពើណាមួយជាបទល្មើសហើយនោះ ដើម្បីយកទោសណាមួយទៅអនុវត្តចំពោះជនណាមួយបាន លុះត្រាតែមានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន (ដែលអាចអនុវត្តបាន) នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ បើមិនដូច្នេះទេគេមិនអាចយកទោសនោះមកអនុវត្តចំពោះបុគ្គលនោះបានឡើយ។ ហេតុនេះហើយបានជាគេឃើញមានគោលការណ៍មួយទៀតចែងថា "គ្មានទោសដែលច្បាប់មិនបានចែងនោះឡើយ[4]"។ ហេតុដូច្នេះហើយរាល់ការចោទប្រកាន់ណាមួយ និងការដាក់ទោសទាំងអស់ត្រូវផ្អែកទៅលើច្បាប់។ គ្មានទោសណាមួយដែលអាចយកមកអនុវត្តបាននោះឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការ។ លើសពីនេះទៅទៀត ចៅក្រមមិនអាចពង្រីកវិសាលភាពនៃការអនុវត្ត ឬប្រព្រឹត្តតាមសទិសភាព (ភាពស្របគ្នា ឬភាពស្រដៀងគ្នា) បានឡើយ។ ក្នុងរឿងព្រហ្មទណ្ឌច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។

ជាគោលការណ៍ បទប្បញ្ញត្តិព្រហ្មទណ្ឌត្រូវបានធ្វើ ឬបង្កើតឡើងដោយអង្គការនីតិប្បញ្ញត្តិ។ ប៉ុន្តែក្នុងករណីចាំបាច់ខ្លះ ច្បាប់អាចអនុញ្ញាតឲ្យអង្គការនីតិប្រតិបត្តិ ចេញនូវបទដ្ឋានគតិយុត្តមួយចំនួនដែលជាបទប្បញ្ញត្តិព្រហ្មទណ្ឌកម្រិតស្រាល (បទលហុ) ដែលទណ្ឌកម្មអាចកំណត់បានត្រឹមតែការពិន័យជាប្រាក់តែប៉ុណ្ណោះ[5] ដូចមានចែងនៅ មាត្រា១ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០។

### ១.១.១.២. ធាតុសត្យានុម័ត ឬ ធាតុសម្ភារៈ

ការកើតមានបទល្មើសណាមួយ តែងតែកើតឡើងនូវអំពើ ដែលបង្កការខូចខាតដល់សង្គម ឬបង្កឲ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ឬបង្កផលប៉ះពាល់ដល់សន្តិសុខ ផលប្រយោជន៍សង្គម និងសមាជិកនៃសង្គម។

ធាតុផ្សំសត្យានុម័ត គឺជាអំពើទាំងឡាយណាដែលអាចស្តែងជាអំពើសកម្ម ដែលមានន័យថាជាការបង្កើតនូវអំពើណាមួយដោយបុគ្គលណាម្នាក់ ឬច្រើននាក់ ឬអំពើអកម្ម ដែលស្តែងឡើងពីការមិនប្រព្រឹត្តអំពើណាមួយ សំដៅដល់ការមិនបានធ្វើអំពើណាមួយដែលច្បាប់តម្រូវជាកាតព្វកិច្ចដែលត្រូវធ្វើ[6] ឬជាអង្គហេតុ ឬជាហេតុការណ៍ទាំងឡាយណាដែលបង្កឲ្យកើតមាននូវអាកប្បកិរិយាណាមួយ[7]។ ធាតុនេះជាកត្តាមួយដ៏សំខាន់ ដែលមិនអាចខ្វះបាន។ ប្រសិនបើមនុស្ស មិនបានប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់នោះទេ វាក៏មិនមានលទ្ធផលអាក្រក់ កើតឡើងចំពោះសង្គម ឬសមាជិកសង្គមដែរ។

[4] ហ៊ាង ឡេង, នីតិព្រហ្មទណ្ឌទូទៅ, ទំព័រ ១២

[5] ប៊ុន ហ៊ុន, មេរៀនច្បាប់ព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩

[6] ប៊ុន ហ៊ុន, មេរៀនច្បាប់ព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩

[7] វុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០១២, ទំព័រ ១៤៨

ជាទូទៅ អំពើល្មើសតែងតែផុសចេញពីគំនិតជាមុន ហើយវាស្តែងឲ្យឃើញពីចេតនារបស់ជនល្មើសនៃការចង់បានអ្វីមួយពីសកម្មភាពរបស់ខ្លួន។ ដើម្បីសម្រេចនូវបំណងនេះ ជនល្មើសបានប្រើប្រាស់គ្រប់មធ្យោបាយ កលល្បិច និងជ្រើសរើសពេលវេលាណាមួយ ដែលអំណោយផលក្នុងការប្រព្រឹត្តបទល្មើស។

ដើម្បីចាត់ទុកថាអំពើណាមួយជាបទល្មើស លុះត្រាតែអំពើនោះស្តែងចេញ និងបង្កលក្ខណៈគ្រោះថ្នាក់ ផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌ និងការប្រព្រឹត្តអំពើដោយមានការយល់ដឹងចំពោះអំពើនោះ ឬមានកំហុសចេញមកខាងក្រៅតាមរយៈអំពើសត្យានុម័ត។ សូមគូសបញ្ជាក់ថា គំនិត ឬបំណងក្នុងការប្រព្រឹត្តបទល្មើស មិននាំឲ្យមានការផ្តន្ទាទោសព្រហ្មទណ្ឌឡើយ ដោយហេតុថាគំនិតនោះមិនទាន់លេចចេញជារូបរាងមកខាងក្រៅ និងពុំនាំឲ្យមានការអន្តរាយដល់សង្គមឡើយ[8]។ នេះជាវិធានដែលមានគោលបំណងការពារសិទ្ធិសេរីភាពរបស់បុគ្គលក្នុងការធ្វើសកម្មភាព។

- **ទំនាក់ទំនងហេតុ និងផលរវាងអំពើប្រព្រឹត្តជាមួយព្យសនកម្ម**

ព្យសនកម្ម គឺជាការខូតខាត ឬសេចក្តីវិនាសអន្តរាយ ខាងផ្លូវកាយក្តី ខាងផ្លូវចិត្តក្តី ឬសម្ភារៈ ដែលបណ្តាលមកពីបទល្មើសព្រហ្មទណ្ឌលើជនរងគ្រោះ ឬសង្គម ហើយត្រូវតែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតជាមួយនឹងអំពើដែលបានប្រព្រឹត្ត ឬអាចនិយាយបានម្យ៉ាងទៀតថា អំពើបង្កើតឲ្យមានព្យសនកម្ម ឬព្យសនកម្មកើតឡើងដោយសារតែអំពើ[9]។ បើទោះបីជាអំពើ ត្រូវបានប្រព្រឹត្តឡើងក្នុងទម្រង់បែបណាក៏ដោយ ប៉ុន្តែប្រសិនបើអំពើនោះមិនបង្កព្យសនកម្ម ឬការខូចខាតចំពោះជនរងគ្រោះ ឬសង្គមនោះទេ មិនអាចមានទណ្ឌកម្មណាមួយយកមកអនុវត្តចំពោះជនដែលបានប្រព្រឹត្តនោះ ឬគេមិនអាចចាប់បង្ខំឲ្យជនល្មើសទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ នេះគឺជាគោលការណ៍នៃទំនាក់ទំនងរវាងហេតុ និងផល[10] ពោលគឺទាល់តែមានការប៉ះពាល់ដល់សង្គម សន្តិសុខជាតិ ផលប្រយោជន៍របស់សង្គម របៀបរៀបរយសាធារណៈនៅក្នុងសង្គម ឬសមាជិកនៃសង្គម។

### ១.១.១.៣. ធាតុអត្តនោម័ត ឬ ធាតុចិត្តសាស្ត្រ

ប្រសិនបើមានការប្រព្រឹត្តអំពើមួយ ដែលបានប្រព្រឹត្តឡើងដោយមានតែ ធាតុនីត្យានុកូល និងធាតុសត្យានុម័ត គឺមិនទាន់គ្រប់គ្រាន់ដើម្បីចាត់អំពើនោះជាបទល្មើសបានឡើយ។ ហេតុនេះដាច់ខាតត្រូវតែមានធាតុអត្តនោម័ត ដែលស្តែងឲ្យឃើញពីឆន្ទៈ ឬគោលបំណងក្នុងការប្រព្រឹត្តអំពើនោះ

---

[8] រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០១២, ទំព័រ ១៤៨

[9] ប្រសាសន៍ឯកឧត្តម កើត រិទ្ធ, នាទីផ្សព្វផ្សាយក្រមព្រហ្មទណ្ឌ

[10] ហ៊ាង ឡេង, នីតិព្រហ្មទណ្ឌទូទៅ, ទំព័រ ២៣

ឡើង។ អ្នកប្រព្រឹត្ត ត្រូវតែមានចេតនាពិតប្រាកដ ជាពិសេសគឺមានការយល់ដឹងខុសត្រូវពីអំពើរបស់ខ្លួន ហើយបុគ្គលនោះដឹងច្បាស់ថាអំពើនោះ ត្រូវបានច្បាប់ហាមឃាត់ ឬជាអំពើខុសច្បាប់ តែខ្លួននៅតែប្រព្រឹត្តអំពើនោះ ឬអំពើនោះនឹងប៉ះពាល់ដល់ជនរងគ្រោះ ទ្រព្យសម្បត្តិ ឬផ្លូវចិត្ត ឬគ្រោះថ្នាក់ដល់សង្គមជាដើម។

ធាតុអត្តនោម័ត គឺជាកិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គម ដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ[11]។ ដូច្នេះដើម្បីបង្កើតបានជាបទល្មើស ជនល្មើសត្រូវតែប្រព្រឹត្តអំពើដោយមានកំហុស ដែលកំហុសនោះត្រូវបានកើតឡើងពីចេតនា ដែលមានន័យថា ចារីមានការតាំងចិត្តប្រព្រឹត្តបទល្មើសដោយមានចិត្តបំពានលើច្បាប់ និងចង់ឲ្យមានផលវិបាកកើតឡើងដោយសារអំពើរបស់ខ្លួន។ ប៉ុន្តែនៅពេលខ្លះ កំហុសទាំងនោះអាចកើតឡើងដោយអចេតនា មានន័យថា ចារីមិនមានចេតនាចង់បង្កឲ្យមាននូវផលវិបាកណាមួយ ឬមានព្យសនកម្មកើតឡើងចំពោះសង្គមនោះទេ។ ប៉ុន្តែអំពើទាំងនោះ អាចកើតមានឡើងដោយសារតែការមិនបានប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ដែលក្នុងករណីនេះច្បាប់បានបញ្ញត្តិទុកជាមុនថាអំពើនោះជាបទល្មើស។

### ១.១.២. លក្ខខណ្ឌទាក់ទងនឹងអាយុរបស់អនីតិជន

អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុទៅតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម ១៨ ឆ្នាំ[12] ឬជាជន ដែលច្បាប់មិនទាន់ឲ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត ឬជាជនដែលច្បាប់កំណត់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌមានកម្រិត[13]។ ដើម្បីឲ្យអនីតិជនទទួលខុសត្រូវព្រហ្មទណ្ឌ ច្បាប់បានកំណត់ពីអាយុរបស់បុគ្គលនេះ។ ដើម្បីឈានទៅដល់ការដាក់ទណ្ឌកម្មណាមួយយកទៅអនុវត្តលើអនីតិជន ច្បាប់កំណត់ពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានន័យថា ជាអាយុដែលច្បាប់កំណត់ឲ្យទទួលខុសត្រូវលើការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ[14]។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ ១៨ ឆ្នាំ ឡើងទៅ។ ប៉ុន្តែតុលាការអាចនឹងប្រកាសទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើង ប្រសិនបើកាលៈទេសៈតម្រូវ ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[15]។ ដូច្នេះបើអនីតិជនដែលប្រព្រឹត្តបទល្មើសមានអាយុចាប់ពី ១៤ ឆ្នាំឡើង ហើយ

[11] រុន ពណ្ណារិទ្ធ, ថាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០១២, ទំព័រ ១៩៣

[12] សន្ធានុក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, លេខរាង ១៨៧

[13] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២៣០

[14] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ៥៧

[15] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៧, វាក្យខណ្ឌទី ២; ក្រមព្រហ្មទណ្ឌឆ្នាំ ២០១០, មាត្រា ៣៩, កថាខណ្ឌទី ២; រុន ពណ្ណារិទ្ធិ, ថាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០១២, ទំព័រ ២៣៩ (ក្រមព្រហ្មទណ្ឌ ពុំបានកំណត់និយមន័យ ឬ

តុលាការយល់ឃើញថាជននោះមានភាពចាស់ទុំ ស្មារតីគ្រប់គ្រាន់ទៅតាមអាយុ អត្តចរិក និងកម្រិតយល់ដឹង ហើយការប្រព្រឹត្តបទល្មើសឧក្រិដ្ឋមានលក្ខណៈធ្ងន់ធ្ងរ ឬអនីតិជនបានប្រព្រឹត្តបទល្មើសជាច្រើនដងដោយមិនរាងចាល ក៏អាចតម្រូវឲ្យទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌរបស់ខ្លួនផងដែរ[16] លើកលែងតែករណីមានចែងពិសេសក្នុងច្បាប់ផ្សេងទៀត។

ចំពោះការកំណត់អាយុនេះ អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនត្រូវកំណត់យកអាយុនៅថ្ងៃដែលអនីតិជននោះប្រព្រឹត្តបទល្មើស។ ភស្តុតាងនៃអាយុរបស់អនីតិជននោះ ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត[17] ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានពីកំណើត។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាអត្ថប្រយោជន៍ដល់អនីតិជន ឬប្រសិនបើមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀត ដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន។ ហេតុដូច្នេះ ពេលខ្លះភាពលំបាកអាចកើតមានឡើងក្នុងការកំណត់ពីអាយុរបស់អនីតិជន ជាពិសេសគឺនៅដំណាក់កាលនគរបាលយុត្តិធម៌ ដែលជាដំណាក់កាលដំបូងនៅពេលដែលអនីតិជនណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីដែលអនីតិជនមិនបានដឹងអំពីកាលបរិច្ឆេទនៃកំណើត និងពុំមានសំបុត្រកំណើតផងនោះ នគរបាលយុត្តិធម៌ត្រូវប្រឹងប្រែងស្វែងរកព័ត៌មានពីក្រុមគ្រួសាររបស់អនីតិជន។ ហើយអនីតិជន ឬឪពុកម្តាយ ឬសមាជិកដទៃទៀតក្នុងគ្រួសារនឹងត្រូវតែបានគេសាកសួរថា តើអនីតិជននោះកើតឡើងក្នុងអំឡុងពេល ឬក្នុងរដូវកាលជាក់លាក់ណាមួយ។

នៅតាមបណ្តាប្រទេសផ្សេងៗមួយចំនួន ការកំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌមានភាពខុសៗគ្នា។

ឧទាហរណ៍ ៖

- ប្រទេសម៉ាឡេស៊ី ១០ ឆ្នាំ

ផ្តល់លក្ខណៈវិនិច្ឆ័យនៃកាលៈទេសៈ ឬបុគ្គលិកលក្ខណៈរបស់អនីតិជន ដែលជាលក្ខខណ្ឌនៃការប្រកាសទោសទៅលើអនីតិជនឡើយ)

[16] សេចក្តីព្រាងស្តីពី សៀវភៅមគ្គុទ្ទេសក៍សម្រាប់នគរបាលយុត្តិធម៌ ស្តីពីនីតិវិធីនគរបាលយុត្តិធម៌បែបកុមារមេត្រី ឆ្នាំ ២០១៧

[17] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០, មាត្រា ២, កថាខណ្ឌទី ២ និង៣៖ សំបុត្រកំណើត ជាប្រភេទនៃសំបុត្រអត្រា-នុកូលដ្ឋានសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែនសមត្ថកិច្ចកំណត់នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

- ប្រទេសវៀតណាម ១៤ ឆ្នាំ
- ប្រទេសអូស្ត្រាលី ១០ ឆ្នាំ[18]។

## ១.២. ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី

នៅពេលដែលចារី បានប្រព្រឹត្តបទល្មើសណាមួយ ដែលបានបំពានលើជនរងគ្រោះ ឬច្បាប់សង្គម ពេលនោះច្បាប់ដែលគ្រប់គ្រងសង្គមនឹងប្រតិកម្មតបទៅវិញ តាមរយៈការទាមទារឲ្យចារីនោះទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ។ ម៉្យាងវិញទៀតពេលខ្លះ បុគ្គលនោះទៀតសោតក៏អាចតម្រូវឲ្យមានការទទួលខុសត្រូវក្នុងការសងសំណងជម្ងឺចិត្ត ដែលខ្លួនបានប្រព្រឹត្តចំពោះសង្គម ឬជនរងគ្រោះមិនថាជាទ្រព្យសម្បត្តិ រូបកាយ ឬទៅលើផ្លូវចិត្តរបស់ជនរងគ្រោះនោះឡើយ។ រីឯការទាមទារឲ្យមានការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី មិនមែនមានន័យថាចារីដាច់ខាតត្រូវតែទទួលខុសត្រូវក្នុងការសងជម្ងឺចិត្តដល់ជនរងគ្រោះនោះទេ។ ប៉ុន្តែអាស្រ័យទៅលើសេរីភាព ឬការគោរពទៅតាមឆន្ទៈរបស់ជនរងគ្រោះដែលចង់ទាមទារសំណងនេះ ឬអត់។ មូលហេតុថានៅពេលខ្លះ បើទោះបីជាមានបទល្មើសកើតឡើងចំពោះខ្លួនពិតមែន ក៏ប៉ុន្តែជនរងគ្រោះខ្លះបែរជាមានភាពអាណិតអាសូរលើចារីនោះទៅវិញ ដោយមូលហេតុថាចារីបានជួបនូវវិបត្តិមួយចំនួនដូចជា ការខ្វះចំណេះដឹង ការមិនមានការយកចិត្តទុកដាក់ពីឪពុកម្តាយ ឬបញ្ហាកើតមាននៅក្នុងគ្រួសារតតឈប់ឈរ ហើយអ្វីដែលពិសេសនោះគឺបញ្ហាសេដ្ឋកិច្ច។ ហេតុនេះជនរងគ្រោះអាចមិនធ្វើការប្តឹងទាមទារនូវសំណងការខូចខាតដែលកើតចេញពីអំពើល្មើសនោះទេ។ ដូច្នេះ ចៅក្រមដែលទទួលបន្ទុកលើរឿងក្តីនេះ មិនអាចសម្រេចទៅលើបណ្តឹងរដ្ឋប្បវេណីដែលទាក់ទងទៅនឹងសំណងនៃការខូចខាតលើជនរងគ្រោះបាននោះឡើយ។

ដើម្បីអាចឲ្យជនរងគ្រោះក្នុងរឿងក្តី អាចមាននូវសិទ្ធិទាមទារនូវសំណងនៃការខូចខាតដែលកើតចេញពីអំពើល្មើសបាននោះ ច្បាប់បានតម្រូវឲ្យមានការគោរពនូវលក្ខខណ្ឌមួយចំនួន ដែលបានកំណត់ជាក់លាក់នៅក្នុងច្បាប់ (១.២.១) ហើយក៏បានកំណត់ពីបុគ្គលដែលត្រូវមានករណីយកិច្ចក្នុងការទទួលខុសត្រូវសងសំណងដល់ជនរងគ្រោះ (១.២.២) ដែលមានដូចខាងក្រោម ៖

### ១.២.១. លក្ខខណ្ឌនៃការទាមទារសំណងនៃការខូចខាត

បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឲ្យជនល្មើសជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ មានន័យថា ធ្វើឲ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធូនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល[19]។

[18] សេចក្តីព្រាងស្តីពី សៀវភៅមគ្គុទ្ទេសក៏សម្រាប់នគរបាលយុត្តិធម៌ ស្តីពីនីតិវិធីនគរបាលយុត្តិធម៌បែបកុមារមេត្រី ឆ្នាំ ២០១៧
[19] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ២, កថាខណ្ឌទី ២

បណ្តឹងទាមទារសំណងជម្ងឺចិត្តត្រូវតែអនុវត្ត ឬអាចត្រូវធ្វើឡើងដោយក្នុងនាមជនរងគ្រោះនៃបទល្មើស ឬដោយអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ(កាលណាជនរងគ្រោះនោះជាអនីតិជន ឬអសមត្ថជនដែលស្ថិតនៅក្រោមរបបច្បាប់ការពារ)។ បើទោះបីជាក្នុងករណី ដែលជនរងគ្រោះបានទទួលមរណភាពក៏ដោយ ក៏បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានផ្តើមធ្វើឡើង ឬបន្តធ្វើដោយសិទ្ធិវ័ន្ត[20]។ លើសពីនេះទៀតជនរងគ្រោះ ឬសិទ្ធិវ័ន្តរបស់ជនរងគ្រោះអាចធ្វើបណ្តឹងរដ្ឋប្បវេណីក្នុងពេលជាមួយនឹងបណ្តឹងអាជ្ញានៅតុលាការព្រហ្មទណ្ឌ។ ក៏ប៉ុន្តែក្នុងករណីដែលចិរវេលានៃបណ្តឹងអាជ្ញាបានរលត់ បណ្តឹងរដ្ឋប្បវេណីនេះក៏មិនអាចធ្វើនៅតុលាការព្រហ្មទណ្ឌបានទៀតដែរ។

បណ្តឹងរដ្ឋប្បវេណីអាចធ្វើបានផងដែរ នៅចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី លើកលែងតែផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី។ ក្នុងករណីនេះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវព្យួរសិនដរាបណាមិនទាន់មានសេចក្តីសម្រេចជាស្ថាពរមួយត្រូវបានប្រកាសលើបណ្តឹងអាជ្ញា។ ប៉ុន្តែដើម្បីឲ្យតុលាការព្រហ្មទណ្ឌអាចសម្រេចការជួសជុលព្យសនកម្មបាន លុះត្រាតែបានពិនិត្យជាមុនអំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ហើយត្រូវប្រកាសថាជនជាប់ចោទត្រូវមានពិរុទ្ធជាមុនសិន។ បើទោះបីជាជនជាប់ចោទបានទទួលមរណៈភាពនៅក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណី នៅតែអាចសុំឲ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវ័ន្តរបស់ជនជាប់ចោទបាន។ ថ្វីត្បិតតែបណ្តឹងអាជ្ញារលត់ តែតុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវ័ន្តទាំងនោះ។

ដើម្បីទទួលការជួសជុលព្យសនកម្មបាន លុះត្រាតែ៖

- ជាផលវិបាកផ្ទាល់នៃបទល្មើស មានន័យថាជនរងគ្រោះបានទទួលរងនូវការខូចខាតធ្ងន់ ឬស្រាលដោយផ្ទាល់ចេញពីបទល្មើសនោះ ដោយអាស្រ័យទៅលើសកម្មភាពនៃការប្រព្រឹត្តបទល្មើសរបស់ជនល្មើស។ ពេលខ្លះការខូចខាតនោះ អាចបណ្តាលឲ្យបាត់បង់នូវទ្រព្យសម្បត្តិ អាយុជីវិត ឬការខូចខាតខាងផ្លូវចិត្ត (កិត្តិយស ឬកេរឈ្មោះរបស់ជនរងគ្រោះ ជាដើម)។
- ជាព្យសនកម្មផ្ទាល់ខ្លួន មានន័យថាការខូចខាតបានកើតឡើងចំពោះជនរងគ្រោះ ហើយមានតែជនរងគ្រោះទេ ដែលជាអ្នកដាក់ពាក្យបណ្តឹងទាមទារសំណងជម្ងឺចិត្តដោយផ្ទាល់។ តតិយជន ឬបុគ្គលទាំងឡាយណាដែលមិនបានទទួលរងនូវព្យសនកម្មផ្ទាល់ពីបទល្មើសនោះ មិនអាចដាក់ពាក្យបណ្តឹងទាមទារនូវសំណងជំនួសជនរងគ្រោះនោះបានឡើយ។ ផ្ទុយទៅវិញក៏មានបញ្ញត្តិលើកលែងផងដែរ ដោយក្នុងករណីជនរងគ្រោះបានស្លាប់ ឬជនរងគ្រោះជាអនីតិជន ឬនីតិជនអសមត្ថភាពក្នុង

[20] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២១៩ ៖ អ្នកមានសិទ្ធិលើវត្ថុណាមួយ ឬលើអ្វីមួយ

ករណីនេះអ្នកតំណាងស្របច្បាប់ (អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ)[21] ឬសិទ្ធិវន្តរបស់ជនរងគ្រោះ អាចធ្វើការដាក់ពាក្យបណ្តឹងជំនួសបាន[22]។

- បានកើតឡើងក្នុងពេលបច្ចុប្បន្ន មានន័យថាបទល្មើស ដែលបានបង្កឡើងដោយជនល្មើសដែលបណ្តាលឲ្យមានការខូចខាតកើតឡើងដល់ជនរងគ្រោះក្នុងពេលបច្ចុប្បន្ន[23]។

### ១.២.២. បុគ្គលដែលត្រូវទទួលខុសត្រូវ

នៅពេលដែលតុលាការព្រហ្មទណ្ឌរកឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងស្ថាប័នអយ្យការ តុលាការអាចសម្រេចចាត់ឲ្យបុគ្គលមួយចំនួនត្រូវមកទទួលខុសត្រូវក្នុងការសងសំណងរដ្ឋប្បវេណី ដែលបានបង្កឡើងដោយជនជាប់ចោទ។ ករណីខ្លះជនល្មើស ឬឲ្យអ្នកទទួលបន្ទុកគ្រប់គ្រងជននោះជាអ្នកទទួលខុសត្រូវ (១.២.២.១) ឬពេលខ្លះអ្នកជាប់កាតព្វកិច្ចត្រូវសហការគ្នាសងនូវព្យសនកម្មនោះ (១.២.២.២) ដែលមានចែងដូចខាងក្រោម៖

#### ១.២.២.១. ភាតព្វកិច្ចរបស់តតិយជន

ជាគោលការណ៍ បុគ្គលណាដែលបានប្រព្រឹត្តបទល្មើស ហើយត្រូវបានតុលាការបង្គាប់ឲ្យធ្វើការសងការខូចខាតនោះ បុគ្គលនោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលបានបង្កឡើងដោយខ្លួនឯង (គោលការណ៍នៃការទទួលខុសត្រូវចំពោះកំហុស)[24]។ ប៉ុន្តែមានការលើកលែងផងដែរក្នុងករណីអនីតិជន ដែលមានអាយុក្រោម ១៤ ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើសនោះដោយចេតនាក្តី ឬដោយអចេតនាក្តី ដែលបានបង្កឲ្យមានការខូចខាតដល់ជនរងគ្រោះ មិនទទួលខុសត្រូវក្នុងការសងសំណងដល់ជនរងគ្រោះនោះទេ[25] ដោយសារតែបុគ្គលនោះនៅខ្វះសមត្ថភាពក្នុងការវិនិច្ឆ័យពីឆន្ទៈរបស់ខ្លួន ឬមានសមត្ថភាពក្នុងការវិនិច្ឆ័យដែរ ប៉ុន្តែមិនគ្រប់គ្រាន់ ដោយសារមូលហេតុអាយុ។ ប៉ុន្តែនេះមិនមែនមានន័យថា ជនរងគ្រោះមិនអាចប្តឹងទាមទារសំណងជម្ងឺចិត្តនោះបានឡើយ ដោយច្បាប់តម្រូវឲ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណី[26] ឬអ្នកមានករណីយកិច្ចត្រួតពិនិត្យអ្នកអសមត្ថភាពក្នុង

---

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ១៥

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ១៦

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ១៣, កថាខណ្ឌទី ២

[24] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៧៤៣, កថាខណ្ឌទី ១; និងសេចក្តីកំណត់ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, ទំព័រ ១៨៣

[25] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៧៤៥, កថាខណ្ឌទី ១; និងសេចក្តីកំណត់ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, ទំព័រ ១៨៤

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ២១, ចំនុចទី ៣; រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០១៥-២០១៦៖ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺជាជនទាំងឡាយណាដែលច្បាប់តម្រូវឲ្យទទួលខុសត្រូវអំពើរបស់អ្នកដទៃ ដែលជាជនជាប់ចោទនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ឬជាចុងចម្លើយនៃបណ្តឹងរដ្ឋប្បវេណីមានដូចជា ឪពុកម្តាយ អ្នកអាណាព្យាបាល ឬនិយោជក ។ល។

ការទទួលខុសត្រូវ ត្រូវទទួលសងនូវសំណងនោះជំនួសអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ[27] ទោះបីជាអំពើនោះមិនត្រូវបានប្រព្រឹត្តដោយអ្នកត្រួតពិនិត្យក៏ដោយ។

#### ១.២.២.២. ការទទួលខុសត្រូវដោយសាមគ្គីភាព

ក្នុងករណីខ្លះ ការសងសំណងរដ្ឋប្បវេណីឲ្យជនរងគ្រោះ ត្រូវធ្វើឡើងដោយបុគ្គលមួយក្រុមដែលមានទាំងជនបង្ក (អនីតិជនក្រោម ១៤ ឆ្នាំ) និងតតិយជន (អ្នកទទួលបន្ទុកគ្រប់គ្រងអនីតិជន) ដែលបានកំណត់ដោយច្បាប់។ ផ្ទុយទៅវិញបុគ្គល ដែលមានករណីយកិច្ចក្នុងការត្រួតពិនិត្យអាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតបាន ប្រសិនបើបានបញ្ជាក់ថាខ្លួនបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី[28]។

### ១.៣. ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

អនីតិជនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាតែនៅពេលដែលទង្វើរបស់អនីតិជននោះបានលើកលែងដោយច្បាប់ បើមិនដូច្នេះទេអនីតិជននោះនៅតែទទួលខុសត្រូវចំពោះអំពើនោះដដែល។ មានន័យថា អនីតិជននោះអាចនឹងត្រូវជាប់ពន្ធនាគារ ឬច្បាប់នឹងចាត់វិធានការផ្សេងៗដើម្បីអនុវត្តចំពោះបុគ្គលនោះ។ មូលហេតុ ដែលអាចនាំឲ្យអនីតិជនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរួមមាន អាយុរបស់ជនល្មើស (២.១.១) និងលក្ខខណ្ឌផ្សេងៗ (២.១.២)។

#### ១.៣.១. លក្ខខណ្ឌទាក់ទងនឹងអាយុ

អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុទៅតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម ១៨ ឆ្នាំ[29] ឬជាជនដែលច្បាប់មិនទាន់ឲ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត ឬជនដែលច្បាប់កំណត់ឲ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដោយមានកម្រិត[30]។ ជាគោលការណ៍អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ដោយហេតុថាជនទាំងនោះមិនទាន់យល់ដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួននោះទេ[31]។ ម៉្យាងទៀត គេគិតថាអនីតិជនក្រោម ១៤ ឆ្នាំ មិនមានសមត្ថភាពក្នុងការប្រព្រឹត្តបទល្មើសនោះទេ ហើយតាមផ្លូវច្បាប់មិនត្រូវបានចោទប្រកាន់លើ

---

[27] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៧៤៦, កថាខណ្ឌទី ១; និងសេចក្តីកំណត់ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, ទំព័រ ១៨៥

[28] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៧៤៥, កថាខណ្ឌទី ១ និងទី២; និងសេចក្តីកំណត់ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ទំព័រ ១៨៥

[29] សន្ទានុក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, លេខរាង ១៨៧

[30] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២៣០

[31] រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០១២, ទំព័រ ២៣១

អនីតិជនល្មើសពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាឡើយ[32]។ ដូច្នេះហើយ តុលាការអាចប្រកាសទោសព្រហ្មទណ្ឌលើអនីតិជនបាន លុះត្រាតែអនីតិជននោះមានអាយុ ១៤ ឆ្នាំឡើងទៅ ដោយគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស[33]។ ថ្វីត្បិតតែអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌក៏ពិតមែន ប៉ុន្តែពុំមែនមានន័យថា ច្បាប់មិនអើពើ ឬមិនយកចិត្តទុកដាក់ និងពុំមានវិធានការអ្វីមួយអនុវត្តចំពោះអនីតិជននោះឡើយ។ ជាក់ស្តែង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងពីវិធានការផ្សេងៗ ដើម្បីអាចយកមកអនុវត្តចំពោះអនីតិជនទាំងនោះ។ អនីតិជនដែលបានប្រព្រឹត្តបទល្មើសជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដោយប្រភេទនៃវិធានការនេះ មានដូចខាងក្រោម៖

១. ការប្រគល់អនីតិជនឲ្យឪពុកម្តាយ អាណាព្យាបាល ឬបុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសម។ បើទោះបីជាអនីតិជនស្ថិតនៅដំណាក់កាលនៃនីតិវិធីរបស់តុលាការក៏ដោយ បើអនីតិជនត្រូវបានរកឃើញថាមានអាយុក្រោម ១៤ ឆ្នាំ គិតចាប់ពីថ្ងៃដែលសង្ស័យថាប្រព្រឹត្តបទល្មើស អនីតិជនពុំអាចត្រូវបានគេឃាត់ខ្លួន[34] ឬត្រូវតម្កល់រឿងទុកឥតចាត់ការ[35] ឬមិនអាចឃុំខ្លួនបណ្តោះអាសន្នបានឡើយ[36] ហើយត្រូវប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់កំណត់វិញ។

២. ការប្រគល់អនីតិជនឲ្យសេវាសាធារណៈ ដែលទទួលបន្ទុកថែទាំអនីតិជន។

៣. ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជនដែលមាននីតិសម្បទា[37] ក្នុងការទទួលអនីតិជន។

៤. ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស[38]។ ក្នុងករណីអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅនឹងសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជន។ ក្រោយពីបានទទួលអនីតិជនហើយ ប្រសិនបើ

---

[32] សេចក្តីព្រាងស្តីពី សៀវភៅមគ្គុទ្ទេសក៍សម្រាប់នគរបាលយុត្តិធម៌ស្តីពីនីតិវិធីនគរបាលយុត្តិធម៌បែបកុមារមេត្រី ឆ្នាំ ២០១៧

[33] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៩, កថាខណ្ឌទី ១; ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ៣, កថាខណ្ឌទី ២

[34] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ១៤, កថាខណ្ឌទី ១

[35] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ២៧, កថាខណ្ឌទី ១

[36] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៣៩, កថាខណ្ឌទី ៣

[37] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ៦០ ៖ សមត្ថភាព ដែលច្បាប់បើកឲ្យជនម្នាក់ៗធ្វើកិច្ចអ្វីមួយ ឬលក្ខណៈនៃបុគ្គលដែលអាចធ្វើអ្វីមួយ ឬសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់

[38] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២២៧ ៖ អង្គភាពជំនាញខាងកិច្ចការអ្វីមួយច្បាស់លាស់

យល់ឃើញថាអនីតិជននោះត្រូវមានកិច្ចការពារ និងថែទាំនោះ មន្ទីរដែលបានទទួលអនីតិជនត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាលទូទៅ ក្នុងករណីដែលអនីតិជននោះមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីអាចឲ្យតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងអាណាព្យាបាលលើអនីតិជន។ ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។

៥. ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ តុលាការត្រូវចាត់តាំងបុគ្គលមួយរូបឲ្យទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឲ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មានជូនដល់ព្រះរាជអាជ្ញាអំពីព្រឹត្តការណ៍ទាំងអស់ដែលអាចនាំឲ្យមានការកែប្រែនូវវិធានការនេះ។

គួរគត់សម្គាល់៖ តុលាការជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការចាត់ចែងវិធានការដែលបានរៀបរាប់ខាងលើ។ ប៉ុន្តែ ក្រមព្រហ្មទណ្ឌ ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានចែងលម្អិតអំពីនីតិវិធីពិសេស សម្រាប់ការចាត់វិធានការទាំងអស់នេះឲ្យមានប្រសិទ្ធិភាពនោះទេ[39] ។ ផ្ទុយទៅវិញច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ បានប្បញ្ញត្តិពីយន្តការ និងនីតិវិធីយ៉ាងច្បាស់លាស់ក្នុងការប្រគល់អនីតិជនអាយុក្រោម ១៤ ឆ្នាំ ដែលបានសង្ស័យថាបានប្រព្រឹត្តបទល្មើស ទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ឬឲ្យទៅស្ថាប័នឯកទេសដែលបានទទួលនីតិសម្បទាក្នុងការថែរក្សាអនីតិជន ដែលបានប្រព្រឹត្តបទល្មើស[40]។

### **១.៣.២. លក្ខខណ្ឌផ្សេងៗ**

បន្ទាប់ពីធ្វើការសិក្សាទៅលើលក្ខខណ្ឌអាយុរបស់អនីតិជនខាងលើរួចមក ច្បាប់បានប្បញ្ញត្តិពីលក្ខខណ្ឌផ្សេងទៀត ដែលអាចឲ្យអនីតិជនល្មើសរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ។ លក្ខខណ្ឌទាំងអស់នោះមានដូចរៀបរាប់ខាងក្រោមនេះតទៅ៖

[39] រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ, ឆ្នាំ ២០១២, ទំព័រ ២៣៣

[40] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ១៩, កថាខណ្ឌទី ២ និង៣; មាត្រា ២៧, កថាខណ្ឌទី ២ និង៣; និងមាត្រា ៣៩, កថាខណ្ឌទី ៤, ៥ និង ៦

### ១. ៣. ២. ១. បទល្មើសអំពើអួសទាញ

បទល្មើសអំពើអួសទាញ គឺសំដៅទៅលើជនណា ដែលអួសទាញដោយចេតនានូវជនដទៃក្នុងទីសាធារណៈ ក្នុងគោលបំណងប្រព្រឹត្តអំពើពេស្យាចារផ្ទាល់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ថ្ងៃ ដល់ ៦ ថ្ងៃ និងពិន័យជាប្រាក់ពី ៣.០០០ (បីពាន់រៀល) ដល់ ១០.០០០ (មួយម៉ឺនរៀល)។

ដើម្បីអាចចាត់ទុកថាជាបទល្មើសអំពើអួសទាញបានតម្រូវឲ្យអ្នកប្រព្រឹត្តៈ

១. មានចេតនាអួសទាញអ្នកដទៃដោយស្ម័គ្រចិត្ត និងកើតចេញពីឆន្ទៈរបស់ខ្លួន

២. នៅក្នុងទីសាធារណៈមានន័យថា អំពើត្រូវតែធ្វើនៅកន្លែងទីសាធារណៈ។ ប៉ុន្តែអំពើអួសទាញ អាចត្រូវផ្តន្ទាទោសផងដែរ ប្រសិនបើអំពើនោះធ្វើឡើងនៅទីកន្លែងឯកជន ប៉ុន្តែជនណាម្នាក់ដែលស្ថិតក្នុងទីកន្លែងសាធារណៈអាចមើលឃើញ ឬស្តាប់ឮ

៣. ក្នុងគោលដៅប្រព្រឹត្តអំពើពេស្យាចារផ្ទាល់ខ្លួន មានន័យថាជនល្មើសមានចេតនាចង់ធ្វើសកម្មភាពរួមភេទក្នុងការផ្លាស់ប្តូរទៅនឹងវត្ថុមានតម្លៃ[41]

ប្បញ្ញត្តិនេះក៏បានបញ្ជាក់យ៉ាងច្បាស់ថា អនីតិជនត្រូវបានលើកលែងការផ្តន្ទាទោសចំពោះបទល្មើសអំពើអួសទាញ[42]។ គួរកត់សម្គាល់ថា ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់អោយអនីតិជនអាយុ ១៥ ឆ្នាំ និងលើសពី ១៥ ឆ្នាំ (ពោលគឺជនដែលមានអាយុយ៉ាងហោចណាស់ ១៥ ឆ្នាំ ប៉ុន្តែក្រោម ១៨ ឆ្នាំ[43] ) នូវសមត្ថភាពក្នុងការរួមភេទ។ ប៉ុន្តែច្បាប់នេះមិនបានផ្តល់ឲ្យអនីតិជនបែបនេះនូវសមត្ថភាពក្នុងការយល់ព្រមក្នុងការប្រព្រឹត្តអំពើពេស្យាចារ ដែលរួមមានអំពើអួសទាញនៅទីសាធារណៈដើម្បីប្រព្រឹត្តអំពើពេស្យាចារ។ រាល់អំពើពេស្យាចារទាំងអស់ដែលទាក់ទងនឹងអនីតិជន(ជនដែលមានអាយុក្រោម ១៨ ឆ្នាំ) ត្រូវចាត់ទុកថាជាអំពើពេស្យាចារកុមារ និងខុសច្បាប់ មូលហេតុគឺដោយសារតែអនីតិជនមិនមានសមត្ថភាពតាមផ្លូវច្បាប់ក្នុងការយល់ព្រមធ្វើពេស្យាចារទេ ដូច្នេះច្បាប់ក៏មិនអាចធ្វើការចោទប្តឹងអនីតិជនបានដែរ[44]។

ប្រសិនបើអនីតិជន ត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើអួសទាញក្នុងគោលដៅប្រព្រឹត្តអំពើពេស្យាចារ នគរបាល និងតុលាការគួរតែចាប់ខ្លួន ចោទប្រកាន់ និងកាត់ទោសសញ្ជារិក ឬសញ្ជារិកា

---

[41] ក្រសួងយុត្តិធម៌ កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០១៣

[42] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨, មាត្រា ២៤ កថាខណ្ឌទី ២

[43] អត្ថន័យនេះស្របនឹង ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ២៣៩ កថាខណ្ឌទី ៣

[44] ក្រសួងយុត្តិធម៌ កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០១៣

(បុរស ឬស្ត្រីដែលប្រព្រឹត្តសញ្ចារកម្ម)[45] ឬមេពេស្យាចារដែលបានដឹកនាំឲ្យអនីតិជនប្រព្រឹត្តអំពើនេះ។ អនីតិជនត្រូវបានចាត់ទុកថា ជាជនរងគ្រោះដោយអំពើពេស្យាចារកុមារ។

### ១.៣.២.២. បទល្មើសរួមភេទជាមួយអនីតិជនក្រោម ១៥ ឆ្នាំ

ជនណារួមភេទជាមួយជនដទៃ ដែលមានអាយុតិចជាង ១៥ ឆ្នាំ នឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ។ ជនណាដែលបានប្រព្រឹត្តបទល្មើសនេះ បើមិនរាងចាលទេត្រូវផ្តន្ទាទោសដាក់ពន្ធនាគារទ្វេរដង។

ដើម្បីអាចទុកជាបទល្មើសរួមភេទជាមួយអនីតិជនបានលុះត្រាតែជននោះ៖

១. បានរួមភេទជាមួយអនីតិជនដែលទម្រង់នៃការរួមភេទមានសញ្ញាណជាការដាក់បញ្ចូលគេរភេទ ទៅក្នុងគេរភេទ (លិង្គ ឬរន្ធយោនី) មាត់ រន្ធគូទរបស់ជនម្នាក់ទៀត ឬដាក់បញ្ចូលសម្ភារៈ ឬឧបករណ៍ (ម្រាមដៃ ឬផ្នែកដទៃទៀតនៃរាងកាយមនុស្ស) ទៅក្នុងគេរភេទរបស់ជនម្នាក់ទៀត[46]។

២. ដោយមិនមាន ការបង្ខិតបង្ខំ ការប្រើប្រាស់អំពើហឹង្សា ការគំរាមកំហែង ឬការឆ្មក់ឱកាស បើមិនដូច្នេះទេនឹងត្រូវចោទប្រកាន់ពីបទល្មើសរំលោភសេពសន្ថវៈទៅវិញ[47] ។

ប្បញ្ញត្តិនេះធ្វើការផ្តន្ទាទោសចំពោះជន (មិនថាឡើយបុរស ឬស្ត្រី) ដែលបានរួមភេទជាមួយអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ បើទោះបីអនីតិជននោះបានយល់ព្រមយ៉ាងពេញលេញក្នុងការរួមភេទបែបនេះក៏ដោយ មូលហេតុគឺដោយសារតែ ច្បាប់នេះមិនបានផ្តល់ឲ្យអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ នូវសមត្ថភាពក្នុងការយល់ព្រមរួមភេទនោះឡើយ។ ក្នុងន័យច្បាប់ ការព្រមព្រៀងបែបណាក៏មិនមែនជា " ការយល់ព្រម " នោះទេ[48]។

ប្បញ្ញត្តិនៃច្បាប់នេះបានប្បញ្ញត្តិយ៉ាងច្បាស់ថា អនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ ដែលមានទំនាក់ទំនងផ្លូវភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ មិនត្រូវទទួលខុសត្រូវចំពោះបទល្មើសនេះទេ[49]។ យោងតាមមាត្រា៣៨ និង៣៩ នៃក្រមព្រហ្មទណ្ឌ អនីតិជនដែលមានអាយុ ១៤ ឆ្នាំ អាចទទួលខុសត្រូវព្រហ្មទណ្ឌ។ ប៉ុន្តែនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និង

---

[45] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២១០

[46] និយមន័យនេះ ស្របទៅនឹងសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ លេខ ០១ កយ.សណន\ ០៩ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

[47] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ២៣៩, កថាខណ្ឌទី ១

[48] ក្រសួងយុត្តិធម៌ កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០១៣

[49] ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨, មាត្រា ៤៤

អំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០១៣ បានប្បញ្ញត្តិថា មានតែអនីតិជនដែលមានអាយុយ៉ាងតិច ១៥ ឆ្នាំ ប៉ុណ្ណោះដែលអាចទទួលទោសព្រហ្មទណ្ឌ[50]។

ការអនុវត្តជាក់ស្តែង នៅបណ្តាប្រទេសមួយចំនួនបានលើកលែងការចោទប្រកាន់ក្នុងករណីអនីតិជនខ្លះដែលមានអាយុប្រហាក់ប្រហែលគ្នា ឬអាយុខុសគ្នាបន្តិចបន្តួច ដែលបានស្ម័គ្រចិត្តមានទំនាក់ទំនងផ្លូវភេទជាមួយគ្នា ដោយពុំមានការប្រើប្រាស់អំពើហឹង្សា ឬការបង្ខិតបង្ខំ ឬគម្រាមកំហែង ឬឆ្លក់ឱកាស ឬបោកបញ្ឆោតនោះឡើយ។ នៅក្នុងសេចក្តីសម្រេចរបស់តុលាការជាន់ខ្ពស់ក្នុងបណ្តាប្រទេសទាំងនោះ ចាត់ទុកទំនាក់ទំនងផ្លូវភេទដែលមានការព្រមព្រៀងគ្នារវាងកុមារ និងកុមារដែលមានអាយុប្រហាក់ប្រហែលគ្នា ជាទំនាក់ទំនងគ្មានការទទួលខុសត្រូវព្រហ្មទណ្ឌ ឬជាបទល្មើសតូចតាចពីព្រោះថាប្រទេសទាំងនោះជឿជាក់ថាការផ្តន្ទាទោសកុមារចំពោះទំនាក់ទំនងផ្លូវភេទដែលមានការព្រមព្រៀងគ្នា ពុំបានផ្តល់ឧត្តមប្រយោជន៍ដល់កុមារឡើយ[51]។

គួរគត់សម្គាល់៖ អនីតិជន ដែលបានប្រព្រឹត្តបទល្មើសនេះហើយមិនរាងចាលក៏តុលាការមិនអាចយកបទប្បញ្ញត្តិនៃការមិនរាងចាលមកអនុវត្តចំពោះអនីតិជនឡើយ[52]។

### ១.៣.២.៣. បទល្មើសអាសប្រព្រឹត្តទៅលើអនីតិជនក្រោម ១៥ ឆ្នាំ

អំពើអាស ជាអំពើនៃការប៉ះពាល់ ឬការបង្ហាញកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬការឲ្យជនដទៃប៉ះពាល់កេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬរបស់តតិយជនក្នុងចេតនាធ្វើឲ្យរំជួល ឬរីករាលដាលដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។

ជនណាដែលប្រព្រឹត្តអំពើអាសទៅលើតតិយជនមានអាយុតិចជាង ១៥ ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ដល់ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ ដល់ ៦ លានរៀល។ ហើយជនណាដែលបានប្រព្រឹត្តបទល្មើសនេះ បើមិនរាងចាលទេត្រូវផ្តន្ទាទោសដាក់ពន្ធនាគារទ្វេរដង។

ដើម្បីអាចចាត់ទុកជាបទល្មើសនេះបាន តម្រូវឲ្យជនប្រព្រឹត្ត៖

១. មានការប៉ះពាល់ដែលសញ្ញាណនៃការប៉ះពាល់មានទម្រង់ដូចជា៖ ការប៉ះពាល់រាងកាយដែលរួមមាន ការត្រដុស ឬការបបោសអង្អែល ឬការថើប ហើយការប៉ះពាល់អាចធ្វើផ្ទាល់ស្បែកនឹងស្បែក ឬលើសំលៀកបំពាក់ជាមួយកេរភេទ ឬផ្នែកភេទផ្សេងទៀត។

[50] ក្រសួងយុត្តិធម៌ កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០១៣

[51] បណ្តាប្រទេសដូចជាប្រទេសអង់គ្លេសជាដើម នៅតែរក្សាច្បាប់ស្តីពីការរំលោភសេពសន្ថវៈលើអនីតិជនដដែល។ ប៉ុន្តែគេក៏នៅរក្សាទម្លាប់មិនចោទប្រកាន់បទល្មើសដែលជាអនីតិជននោះទេ ។

[52] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១៦៣

២. មានចេតនាធ្វើឲ្យមានការរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់អ្នកប្រព្រឹត្ត ហើយមិនសំខាន់ទេថាជនល្មើសបានប្រើវិធិសាស្ត្របែបណា ដើម្បីបំពេញចំណង់ផ្លូវភេទរបស់ខ្លួនឯងនោះទេ។ ជនល្មើសអាចធ្វើសកម្មភាពផ្ទាល់ទៅលើជនរងគ្រោះ ឲ្យជនរងគ្រោះធ្វើអំពើនោះមកដាក់លើខ្លួន ឬតតិយជន ឬឲ្យតតិយជនធ្វើអំពើនោះទៅលើជនរងគ្រោះ[53]។

បញ្ញត្តិនៃច្បាប់នេះបានបញ្ជាក់ថា អនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើសនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ[54]។ ទោះជាយ៉ាងណាក៏ដោយ ការលើកលែកពីទោសនេះអនុវត្តបានតែក្នុងករណីដែលអំពើផ្លូវភេទ ត្រូវបានប្រព្រឹត្តឡើងដោយមានការយល់ព្រមដោយស្ម័គ្រចិត្តពីអ្នកចូលរួមប៉ុណ្ណោះ។ ប្រសិនបើអ្នកប្រព្រឹត្តបានប្រើអំពើហឹង្សា ឬការបង្ខិតបង្ខំ ឬការគម្រាមកំហែង ឬការបំភិតបំភ័យដៃគូរបស់ខ្លួននោះ ជនល្មើសនឹងត្រូវចោទប្រកាន់ពីបទល្មើសផ្សេងទៅវិញ[55] ។

គួរគត់សម្គាល់៖ អនីតិជន ដែលបានប្រព្រឹត្តបទល្មើសនេះហើយមិនរាងចោលក៏តុលាការមិនអាចយកបទប្បញ្ញត្តិនៃការមិនរាងចាល មកអនុវត្តចំពោះអនីតិជនបានឡើយ[56]។

[53] ក្រសួងយុត្តិធម៌ កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០១៣

[54] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨, មាត្រា ៤៥

[55] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ២៤៦

[56] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១៦៣

## ជំពូកទី ២ ៖ លំហូរនីតិវិធី ដែលត្រូវអនុវត្តចំពោះអនីតិជន

នៅពេលដែលអនីតិជន ត្រូវបានរកឃើញថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នីតិវិធីដែលត្រូវយកមកអនុវត្តលើអនីតិជននោះ ត្រូវបានធ្វើឡើងទៅតាមដំណាក់កាលដែលច្បាប់បានកំណត់។ នៅគ្រប់ដំណាក់កាលទាំងអស់ ត្រូវបានអនុវត្តដោយយកចិត្តទុកដាក់ជាទីបំផុត ដោយភ្នាក់ងារមានសមត្ថកិច្ច និងត្រូវគិតគូរដល់ឧត្តមប្រយោជន៍របស់អនីតិជនជាមុន។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ បានចែងពីលំហូរនីតិវិធីតាមលំដាប់ដែលត្រូវយកមកអនុវត្តចំពោះអនីតិជន មុនពេលឈានទៅដល់ការសម្រេចដាក់ទោសអនីតិជន។ នៅដំណាក់កាលទាំងអស់នោះមានដូចជា ដំណាក់កាលនគរបាលយុត្តិធម៌ (២.១), ដំណាក់កាលអយ្យការ (២.២), ដំណាក់កាលចៅក្រមស៊ើបសួរ (២.៣), និងដំណាក់កាលសវនាការរបស់ចៅក្រមជំនុំជម្រះ (២.៤)។

### ២. ១. ដំណាក់កាលនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាភ្នាក់ងារដែលមានសមត្ថកិច្ចដំបូងគេបំផុត នៅពេលដែលអនីតិជនណាមួយបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម ឬបទលហុ។ ច្បាប់ក៏បានផ្តល់នូវសិទ្ធិអំណាច និងកាតព្វកិច្ចមួយចំនួនដល់នគរបាលយុត្តិធម៌ ដើម្បីអនុវត្តចំពោះអនីតិជនដែលបានប្រព្រឹត្តអំពើល្មើសខាងលើនេះ។ ដោយឡែកសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ មានវិសាលភាពត្រឹមតែលើព្រំប្រទល់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងតែប៉ុណ្ណោះ។ ដោយឡែកចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចចាត់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ដើម្បីចេញធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល។ ការអនុញ្ញាតនេះអាចត្រូវធ្វើដោយផ្ទាល់មាត់បាន ប៉ុន្តែត្រូវតែចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត។

#### ២. ១. ១. សិទ្ធិអំណាចនៅទីកន្លែងកើតហេតុ

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការ ចាប់ខ្លួន ឆែកឆេរខ្លួន ឬឃាត់ខ្លួន អនីតិជនណាមួយដែលបានសង្ស័យថាបានប្រព្រឹត្តបទល្មើសពីកន្លែងបង្កហេតុ មកអង្គភាពនគរបាលយុត្តិធម៌បាន។

##### ២. ១. ១. ១. ការចាប់ខ្លួនអនីតិជន

អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង អាចត្រូវបានចាប់ខ្លួនដោយនគរបាលយុត្តិធម៌។ ប៉ុន្តែការចាប់ខ្លួនអនីតិជនដែលបានប្រព្រឹត្តបទល្មើសមជ្ឈិមអាចធ្វើទៅបាន នៅក្នុងករណីដែលអនីតិជននោះបានប្រព្រឹត្តបទ

ល្មើសដោយចេតនា ហើយអនីតិជននោះត្រូវមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ។ រាល់ការចាប់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម[57]។

ចំពោះការអនុវត្តការចាប់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជៀសវាងការធ្វើឲ្យអាម៉ាស់មុខ និងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន។ អនីតិជនត្រូវបញ្ជូនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត។

ទោះបីជាយ៉ាងណាក៏ដោយ ការចាប់ខ្លួន គួរអនុវត្តសម្រាប់វិធានចុងក្រោយបំផុតប៉ុណ្ណោះ។ ការចាប់ខ្លួនត្រូវមានមូលហេតុត្រឹមត្រូវតាមច្បាប់ ទោះជាការចាប់ខ្លួននោះ ត្រូវធ្វើឡើងតាមដីកាចាប់ខ្លួនតាមភស្តុតាងស៊ីចង្វាក់ ឬតាមបទល្មើសជាក់ស្តែងក្តី [58]។

### ២.១.១.២. ការឆែកឆេរខ្លួនអនីតិជន

ការឆែកឆេរខ្លួនរបស់អនីតិជន អាចត្រូវបានធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ឬដោយបុគ្គលដែលមានភេទដូចគ្នានឹងអនីតិជន។ បុគ្គលដែលទទួលបន្ទុក ឬភារៈកិច្ចឆែកខ្លួនអនីតិជន មិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយអនីតិជននោះឡើយ លើកលែងតែក្នុងករណីមិនអាចជៀសវាងបានប៉ុណ្ណោះ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុ និងចុះនិទ្ទេសអំពីបញ្ហានេះ ។

### ២.១.១.៣. ការឃាត់ខ្លួនអនីតិជន

ជាគោលការណ៍ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់។

ប៉ុន្តែ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំឡើងបាន ប្រសិនបើជឿជាក់ថាអនីតិជនអាចរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ។ នៅក្នុងករណីដែលអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ការឃាត់ខ្លួនមិនអាចប្រព្រឹត្តទៅបានឡើយ ប្រសិនបើ

[57] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ១៥

[58] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣, មាត្រា ៣៨; សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨, មាត្រា ៩; អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ ១៩៨៩, មាត្រា ៣៧;វិធានគ្រប់គ្រងយុត្តិធម៌អនីតិជនក្រុងប៉េកាំង ឆ្នាំ ១៩៨៥; មាត្រា ១៣, ក្បួននីតិវិធីព្រហ្មទណ្ឌរបស់នគរបាល, ទំព័រ ៣ ដល់ ៩

អនីតិជននោះមិនមានចេតនាក្នុងការប្រព្រឹត្តបទល្មើស។ រាល់ការឃាត់ខ្លួនអនីតិជន ត្រូវរាយការណ៍ទៅព្រះរាជអាជ្ញាភ្លាម[59]។

លើសពីនេះទៅទៀត មន្ត្រីនគរបាលអាចធ្វើការឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើស ប៉ុនប៉ងប្រព្រឹត្តបទល្មើស ឬជួយឲ្យមានការប្រព្រឹត្តបទល្មើស ដោយត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ឬដោយមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា។ ការឃាត់ខ្លួន អនុញ្ញាតឲ្យនគរបាលយុត្តិធម៌រក្សាទុកជននោះឲ្យស្ថិតនៅក្រោមការចាត់ចែងរបស់ខ្លួនសម្រាប់ការស៊ើបអង្កេត និងស្តាប់ចម្លើយ[60] ។

រាល់ការឃាត់ខ្លួនអនីតិជន ត្រូវដាក់ដោយឡែកពីនីតិជន និងទៅតាមភេទ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធានាឲ្យបាននូវសុវត្ថិភាពរបស់អនីតិជន ដោយមិនត្រូវឲ្យអនីតិជនទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមគំហែង ការសម្លុត ការបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលអាចនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬអាចទទួលរងនូវអំពើអមនុស្សធម៌ណាមួយឡើយ។ ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ ចង់យកអនីតិជនមកដាក់បង្ហាញជាជួរ ត្រូវមានការយល់ព្រមពីសាមីខ្លួនផ្ទាល់ ឬការពិគ្រោះយោបល់ជាមួយមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនជាមុនសិន។ ករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ទទួលបន្ទុក ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងផ្តិតមេដៃ។

រយៈពេលនៃការឃាត់ខ្លួនអនីតិជនមិនអាចពន្យារពេលឡើយ ហើយការឃាត់ខ្លួននេះត្រូវតែអនុវត្តយ៉ាងជាក់លាក់តាមការកំណត់[61] ៖

- អនីតិជនដែលបានប្រព្រឹត្តបទមជ្ឈិម ដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ។ ប៉ុន្តែបើអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។

- អនីតិជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។ ប៉ុន្តែបើអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ បានប្រព្រឹត្តបទឧក្រិដ្ឋមិនអាចត្រូវបានឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ។

[59] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ១៧

[60] សេចក្តីព្រាងស្តីពី សៀវភៅមគ្គុទេសក៍សម្រាប់មន្ត្រីនគរបាលយុត្តិធម៌ ស្តីពីនីតិវិធីនគរបាលយុត្តិធម៌បែបកុមារមេត្រី ឆ្នាំ ២០១៧

[61] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ៩៦ កថាខណ្ឌទី ៥

ចិរវេលានៃការឃាត់ខ្លួនអនីតិជន ត្រូវចាប់គិតពីពេលដែលបានបញ្ជូនខ្លួនអនីតិជននោះមកដល់អង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ។

### ២.១.២. ភារកិច្ចរបស់នគរបាលយុត្តិធម៌នៅប៉ុស្តិ៍នគរបាល

បន្ទាប់ពីអនីតិជន ត្រូវបាននាំខ្លួនមកដល់អង្គភាពនគរបាលយុត្តិធម៌ មន្ត្រីទទួលបន្ទុកត្រូវជូនដំណឹងពីការបានចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជនទៅដល់បុគ្គល ដែលមានកាតព្វកិច្ចពាក់ព័ន្ធជាមួយនឹងអនីតិជនជាបន្ទាន់ ឬក្នុងពេលខ្លីបំផុត។ បុគ្គលទាំងនោះមានដូចជា៖

- អ្នកតំណាងរបស់អនីតិជនដែលច្បាប់បានកំណត់ ហើយក្នុងករណីមិនអាចទាក់ទងបាននោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រឹងប្រែងទាក់ទងនឹងអ្នកទំនុកបម្រុងផ្សេងទៀតដែលអនីតិជន ឬនគរបាលយុត្តិធម៌ជាអ្នកជ្រើសរើស ដោយមានការយល់ព្រមពីអនីតិជននោះ
- ភ្នាក់ងារសង្គមកិច្ច ដើម្បីផ្តល់សេវាគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននោះ
- មេធាវីរបស់អនីតិជន ដោយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានបញ្ជីឈ្មោះមេធាវី សម្រាប់ឲ្យអនីតិជនធ្វើការជ្រើសរើស ឬអាចជ្រើសតាំងមេធាវីឲ្យអនីតិជន ប្រសិនបើអនីតិជននោះគ្មានមេធាវី
- អ្នកបកប្រែភាសា ក្នុងករណីដែលអនីតិជនមិនមែនជាជនជាតិខ្មែរ ឬមិនចេះភាសាខ្មែរ។

ការជូនដំណឹងនេះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជាក់អំពីមូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន ប្រភេទនៃបទល្មើស ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ និងសិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុដោយឡែកអំពីការជូនដំណឹង ឬការព្យាយាមជូនដំណឹងទៅ អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវីរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច។

### ២.១.៣. សិទ្ធិជាមូលដ្ឋានរបស់អនីតិជន

ទោះបីជាអនីតិជន ត្រូវបានជាប់សង្ស័យថាបានប្រព្រឹត្ត ឬពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែរក្សានូវសិទ្ធិជាមូលដ្ឋានរបស់អនីតិជន ដែលមានចែងនៅក្នុងនីតិវិធីដូចខាងក្រោម៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន

- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួន ទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវី ដោយធ្វើការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលមានចែងដោយច្បាប់ស្តីពីលក្ខន្តិកមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើររឿងក្តីប្រសិនបើការចូលរួមនេះ មិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀត ដែលមានចែងក្នុងបទដ្ឋានគតិយុត្តជាធរមាន[62] ។

### ២. ១. ៤. នីតិវិធីនៃការស្តាប់ចម្លើយ

មុនចាប់ផ្តើមនីតិវិធីស្តាប់ចម្លើយ អនីតិជនទទួលបាននូវសិទ្ធិសន្ទនាជាលក្ខណៈឯកជន និងជាសម្ងាត់ជាមួយអ្នកតំណាង អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច ឬមេធាវី ប្រសិនបើមានការស្នើសុំ។

ពេលនីតិវិធីចាប់ផ្តើម មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តវិធាននៃការស្តាប់ចម្លើយតាម មាត្រា ២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ ដែលបានប្បញ្ញតិដូចតទៅ៖

- មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រាប់អនីតិជនអំពីសិទ្ធិមូលដ្ឋានរបស់អនីតិជន ដែលមានចែងនៅក្នុងច្បាប់
- ការស្តាប់ចម្លើយ ត្រូវប្រព្រឹត្តទៅដោយមានវត្តមានរបស់មេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រី ដោយមានលក្ខណៈជាឯកជន និងសម្ងាត់

[62] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៦

- អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ច ដែលមានសិទ្ធិ ហើយអាចផ្តល់ជំនួយដល់អនីតិជន ត្រូវបានផ្តល់សិទ្ធិចូលរួមក្នុងការស្តាប់ចម្លើយ
- ក្នុងករណីដែលវត្តមានរបស់អ្នកតំណាងដែលច្បាប់បានកំណត់អាចធ្វើឲ្យខូចឧត្តមប្រយោជន៍របស់អនីតិជន មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការហាមឃាត់បាន
- ក្នុងករណីដែលមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ច ដែលមានសិទ្ធិអវត្តមាននៅក្នុងពេលស្តាប់ចម្លើយនោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដោយបញ្ជាក់អំពីមូលហេតុនៃអវត្តមាន
- អនីតិជន មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច មានសិទ្ធិក្នុងការអានកំណត់ហេតុក្នុងការស្តាប់ចម្លើយ បន្ទាប់ពីការស្តាប់ចម្លើយបានបញ្ចប់
- អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុដោយចុះនិទ្ទេស
- អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច ដែលមានវត្តមាន ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ។

### ២. ១. ៥. បញ្ជី និងកំណត់ហេតុស្តីពីការឃាត់ខ្លួន

រាល់ការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវចុះបញ្ជីស្តីពីការឃាត់ខ្លួន និងកំណត់ហេតុសរុបនៃការឃាត់ខ្លួន។ នៅក្នុងករណីដែលមេធាវីរបស់អនីតិជននោះ បានធ្វើការស្នើសុំឲ្យមន្ត្រីនគរបាលយុត្តិធម៌ ត្រូវផ្តល់ច្បាប់ចម្លងនៃកំណត់ហេតុសរុបនៃការឃាត់ខ្លួនអនីតិជនឲ្យទៅមេធាវី ។

#### ២. ១. ៥. ១. បញ្ជីស្តីពីការឃាត់ខ្លួន

ជាទូទៅ នៅតាមអង្គភាពនគរបាលយុត្តិធម៌នីមួយៗ ត្រូវមានបញ្ជីដោយឡែកស្តីពីការឃាត់ខ្លួនអនីតិជន។ ចំនុចសំខាន់ៗ ដែលត្រូវចុះក្នុងបញ្ជីឃាត់ខ្លួនរួមមាន៖

- ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ ដែលបានបង្គាប់ឲ្យធ្វើការឃាត់ខ្លួន
- អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោង ដែលចាប់ផ្តើមធ្វើការឃាត់ខ្លួន
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឲ្យឃាត់ខ្លួន
- ឈ្មោះរបស់គ្រូពេទ្យ ដែលបានពិនិត្យបុគ្គលឃាត់ខ្លួន

- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការ ពេលផុតកំណត់ការឃាត់ខ្លួន។

បញ្ជីនេះ ត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ[63]។

### ២.១.៥.២. កំណត់ហេតុសរុបនៃការឃាត់ខ្លួន

រាល់ការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែមានកំណត់ហេតុសរុបនៃការឃាត់ខ្លួនដែលត្រូវចុះនិទ្ទេសដូចតទៅ ៖

- ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ ដែលបង្គាប់ឲ្យឃាត់ខ្លួន
- អត្តសញ្ញាណបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោង ដែលផ្តើមការឃាត់ខ្លួន
- បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា
- បែបបទនៃការជូនដំណឹង ដោយអនុវត្តតាម មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ឈ្មោះគ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន
- អត្តសញ្ញាណរបស់ជន ដែលត្រូវបានអនុញ្ញាតឲ្យសន្ទនាជាមួយបុគ្គល ដែលត្រូវបានឃាត់ខ្លួន
- ថិរវេលានៃការស្តាប់ចម្លើយ និងថិរវេលានៃការសម្រាក ដែលនៅចន្លោះការស្តាប់ចម្លើយ
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការ ពេលបញ្ចប់ការឃាត់ខ្លួន
- លក្ខខណ្ឌនៃការប្រព្រឹត្តទៅនៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ។

កំណត់ហេតុសរុបនៃការឃាត់ខ្លួន ត្រូវភ្ជាប់ជាមួយសំណុំរឿង[64]។

## ២.២. ដំណាក់កាលអយ្យការ

ចៅក្រមអយ្យការ និងចៅក្រមដែលត្រូវបានចាត់ឲ្យទទួលបន្ទុកលើរឿងក្តីអនីតិជន ទៅតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវទទួលបន្ទុកលើរឿងក្តីអនីតិជនរហូតដល់ពេលមានចៅក្រមជំនាញទាក់ទងនឹងអនីតិជនមកទទួលបន្ត។

យោងតាមការកំណត់នៃច្បាប់ តំណាងអយ្យការដែលទទួលបន្ទុករឿងក្តីអនីតិជនត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតទាក់ទង

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ១០១

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ១០២

នឹងយុត្តិធម៌អនីតិជន។ តំណាងអយ្យការជាអ្នកធ្វើការដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ក្នុងដំណើរការរឿងក្តី។

### ២.២.១. ការពិនិត្យអំពីអត្ថិភាព ឬនត្ថិភាពនៃអាយុរបស់អនីតិជន

នៅដំណាក់កាលអយ្យការ ការពិនិត្យអំពីអាយុរបស់អនីតិជន គឺជាចំនុចដំបូងដើម្បីបញ្ជាក់ថាជនសង្ស័យ ពិតជាមានអាយុគ្រប់ ឬលើសពី ១៤ ឆ្នាំ ដើម្បីអាចឲ្យទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត។ ដូច្នេះដើម្បីបញ្ជាក់ពីអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាអាចពិនិត្យមើលលើឯកសារផ្លូវការដែលអាចជឿទុកចិត្តបាន ដែលមានដូចជា សំបុត្រកំណើតរបស់អនីតិជន សៀវភៅស្នាក់នៅ ប័ណ្ណគ្រួសារ ឬការពិនិត្យលើកោសល្យវិច័យរបស់អ្នកបច្ចេកទេស។ល។ ក្នុងករណីដែលមានការសង្ស័យលើ ឬមិនអាចបញ្ជាក់បានពីអាយុពិតរបស់ជនជាប់សង្ស័យនោះទេ ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីធ្វើការស្វែងរកឲ្យឃើញពីអាយុពិតប្រាកដរបស់អនីតិជននោះ[65]។ ក៏ប៉ុន្តែបើការស៊ើបអង្កេតនោះ នៅតែមិនអាចបង្ហាញឲ្យឃើញពីអាយុពិតរបស់អនីតិជននោះ ព្រះរាជអាជ្ញានឹងត្រូវចេញដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ[66] ។

បើអយ្យការពិនិត្យមើលទៅឃើញថា អនីតិជននោះមានអាយុក្រោម ១៤ ឆ្នាំ គិតមកត្រឹមថ្ងៃដែលគេត្រូវបានសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជននោះ ទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញ[67]។

### ២.២.២. ការស្តាប់ចម្លើយ

បន្ទាប់ពីសន្និដ្ឋានពីអាយុពិតប្រាកដរបស់អនីតិជន (ស្មើ ឬលើស ១៤ ឆ្នាំ) ហើយ ព្រះរាជអាជ្ញាអាចធ្វើការស្តាប់ចម្លើយបាន។ មុនពេលស្តាប់ចម្លើយ ព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមស្តាប់ចម្លើយ អំពីសិទ្ធិដែលគេទទួលបានក្នុងនីតិវិធីដោយប្រើភាសា និងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជន។

ដំណាក់កាលនីតិវិធីនៃការស្តាប់ចម្លើយរួមមាន៖

- ត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី

[65] គោលការណ៍ណែនាំស្តីពី យុត្តិធម៌អនីតិជន របស់ក្រសួងយុត្តិធម៌ ឆ្នាំ ២០០៥, អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ឆ្នាំ ១៩៨៩, មាត្រា ៤០

[66] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ២៥

[67] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ២៧ កថាខណ្ឌ១

- ត្រូវមានវត្តមានមេធាវី ភ្នាក់ងារសង្គមកិច្ច ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន
- វត្តមានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ដែលនាំឲ្យខូចឧត្តមប្រយោជន៍អនីតិជនមិនត្រូវអនុញ្ញាតឲ្យចូលរួម
- អនីតិជន មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ចអាចអានកំណត់ហេតុស្តាប់ចម្លើយបាន
- អនីតិជន មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ចត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុ។

ព្រះរាជអាជ្ញា ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ[68]។

វិធានទាំងនេះមានលក្ខណៈដាច់ខាតដែលត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។

### ២.២.៣. ការបង្វែរ

ការបង្វែរ គឺជាការផ្ទេររឿងក្តីកម្រិតស្រាល ឬមិនធ្ងន់ធ្ងរ (បទលហុ - បទមជ្ឈឹម) ចេញពីនីតិវិធីតុលាការព្រហ្មទណ្ឌ ហើយបញ្ជូនអនីតិជនល្មើសទៅរកជំនួយគាំទ្រពីសហគមន៍[69] ក្នុងករណីដែលអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស។ ចំពោះអាជ្ញាធរដែលមាននូវសិទ្ធិអំណាចក្នុងការបង្វែរនោះរួមមានដូចជា តំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជំរះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍[70]។

នៅដំណាក់កាលអយ្យការ ក្រោយពីបានស្តាប់ចម្លើយហើយ ក្នុងករណីដែលពិនិត្យឃើញថាលក្ខខណ្ឌអប្បបរមានៃការបង្វែរ (២.២.៣.១) និងលក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ (២.២.៣.២) ត្រូវបានបំពេញ ព្រះរាជាអាជ្ញា អាចពិចារណាជាបឋមទៅលើការផ្ទេររឿងក្តីនេះចេញពីនីតិវិធីបាន ដោយត្រូវ

68 ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ២៦

69 ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៦០; បទបង្ហាញស្តីពី " ការបង្វែរ " របស់លោកមេធាវី អ៊ុប វិបុល ថ្ងៃទី១,២ ខែ កុម្ភៈ ឆ្នាំ ២០១៧, និងឯកសារយោងសម្រាប់ការបណ្តុះបណ្តាលស្តីពី "ការអនុវត្តសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌" ឆ្នាំ ២០១២ - ២០១៣

70 ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៦១

អនុវត្តតាមច្បាប់ដែលបានកំណត់ពីនីតិវិធីនៃការបង្វែរ (២.២.៣.៣) និងអ្នកទទួលបន្ទុកក្នុងការបង្វែរ (២.២.៣.៤) ផងដែរ។

### ២.២.៣.១. លក្ខខណ្ឌអប្បបរមានៃការបង្វែរ

លក្ខខណ្ឌអប្បបរមានៃការបង្វែរ ៖

- មានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន
- អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសលើជនរងគ្រោះ
- បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬមជ្ឈឹម
- អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយ ភ្នាក់ងារសង្គមកិច្ច ឬមេធាវី អំពីសិទ្ធិរបស់អនីតិជន និងពិចារណាអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានបង្វែរ[71]។

### ២.២.៣.២. លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ

ម៉្យាងវិញទៀត ក្នុងករណីដែលលក្ខខណ្ឌខាងលើត្រូវបានបំពេញហើយ អាជ្ញាធរទទួលបន្ទុកបង្វែរ មុននឹងសម្រេចបង្វែរ ឬមិនបង្វែរ ត្រូវពិចារណាលើកត្តាមួយចំនួនផ្សេងទៀតដែលច្បាប់បានកំណត់រួមមាន ៖

- កាលៈទេសៈនៃបទល្មើស
- ស្ថានភាពនៃបទល្មើស
- បុគ្គលិកលក្ខណៈរបស់អនីតិជនដូចជា អាយុ កម្រិតនៃការយល់ដឹង បញ្ញា អត្តចរិត
- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន
- ព្យសនកម្មរបស់ជនរងគ្រោះ
- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គម[72]។

[71] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៦៣

[72] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៦៥

### ២.២.៣.៣. នីតិវិធីនៃការបង្វែរ

ក្នុងករណីអនីតិជនមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម១៨ ឆ្នាំ ប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាក្នុងការបង្វែរជាមុន។ ក្នុងករណីដែលព្រះរាជអាជ្ញាសម្រេចបង្វែរ ឬផ្ទេររឿងក្តីអនីតិជនចេញពីនីតិវិធីតុលាការព្រហ្មទណ្ឌហើយ នីតិវិធីនៃការចោទប្រកាន់ទាំងអស់ត្រូវបានផ្អាកដោយដីកាសម្រេច ហើយព្រះរាជអាជ្ញានឹងធ្វើការជូនដំណឹងដល់ភាគីជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ និងមេធាវីរបស់ជនរងគ្រោះ អំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់នេះ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី។

ពេលរៀបចំផែនការបង្វែរ ព្រះរាជអាជ្ញា ត្រូវប្រគល់អនីតិជនឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រង និងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ។

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរ អាចសម្រេចជ្រើសរើសយកវិធានមួយ ឬច្រើន ដូចខាងក្រោមសម្រាប់ឲ្យអនីតិជនបំពេញជាកាតព្វកិច្ច ៖

- ចំនុចមួយ ឬច្រើនស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ
- ទៅសាលារៀនឲ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ ខែ
- ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ ខែ
- តម្រូវឲ្យចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងថិរវេលាមិនលើសពី ៦ ខែ
- ធ្វើការងារសហគមន៍មិនឲ្យលើសពី ១០០ ម៉ោង (ការងារសហគមន៍នេះសម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំឡើងទៅ ហើយការងារនេះត្រូវមានលក្ខណៈបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ជូនអនីតិជនទៅរស់នៅក្នុងសង្គម
- ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយអនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសសារជាថ្មី
- ឲ្យស្នាក់នៅកន្លែងណាមួយជាកំណត់ពេលវេលាជាក់លាក់
- ជួសជុលសំណងការខូចខាតដល់ជនរងគ្រោះ
- វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ។

ករណីដែលការបង្វែរបានជោគជ័យ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកបង្វែរ ព្រះរាជអាជ្ញាត្រូវចេញដីកាតម្កល់រឿងទុកឥតចាត់

ការ។ ប៉ុន្តែក្នុងករណីដែលការបង្វែរ មិនទទួលបានជោគជ័យ ព្រះរាជអាជ្ញាអាចសម្រេចចេញដីកាបង្វែរម្តងទៀត ឬបន្តនីតិវិធីចោទប្រកាន់[73]។

### ២.២.៣.៤. អ្នកទទួលបន្ទុកក្នុងការបង្វែរ

ក្រោយពីបានទទួលដីកាសម្រេចបង្វែរ ពីអាជ្ញាធរទទួលបន្ទុកក្នុងការបង្វែរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំផែនការបង្វែរ។ ផែនការបង្វែរ ត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចបង្វែរ លើកលែងតែមានស្ថានភាពពិសេស ដែលមិនអាចជម្នះបាន។

នៅក្នុងការធ្វើផែនការបង្វែរ ជាឯកត្តបុគ្គលសម្រាប់អនីតិជនណាម្នាក់ ភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាលើកត្តាដូចខាងក្រោម ៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស និងភាពសមស្របនៃការបង្វែរដែលត្រូវបានស្នើ
- សាវតារ វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសទៅនឹងស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម
- អាយុ និងតម្រូវការអភិវឌ្ឍ របស់អនីតិជន។

ផែនការបង្វែរសម្រាប់អនីតិជនត្រូវ ៖

- ផ្តល់នូវអត្ថប្រយោជន៍សម្រាប់អនីតិជន
- ធ្វើឲ្យអនីតិជន បានយល់អំពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនៃបទល្មើស និងជនដទៃទៀតដែលរងផលប៉ះពាល់
- កែប្រែនូវកំហុសឆ្គង ដែលបង្កឡើងដោយអំពើល្មើស ហើយអាចរួមបញ្ចូលទាំងសំណងការខូចខាត
- អនុវត្តនៅកន្លែងដែលអនីតិជនអាចអនុវត្តបាន
- ជៀសវាងការធ្វើអាជីវកម្មកេងប្រវ័ញ្ច ឬបណ្តាលឲ្យអន្តរាយ ឬធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់អនីតិជន
- មិនប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់អនីតិជន បើអនីតិជនកំពុងសិក្សា

[73] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ២៨

- និងមិនមានការពាក់ព័ន្ធនឹងការដកហូតសេរីភាព នៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ។

ក្រោយពីបានបង្កើតផែនការបង្វែររួចរាល់ចប់សព្វគ្រប់ហើយ ភ្នាក់ងារសង្គមកិច្ច ត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីពិនិត្យ និងសម្រេច។ ក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរយល់ស្របចំពោះផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរ ត្រូវចេញដីកាសម្រេចឲ្យអនុវត្តផែនការបង្វែរ ដែលមានអានុភាពធ្វើឲ្យភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកផែនការបង្វែរ ត្រូវអនុវត្តសេចក្តីសម្រេចក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជននោះ។ បុគ្គលទទួលបន្ទុកបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាននៅក្នុងផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះ រួមទាំងយោបល់របស់ខ្លួនទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច។

ផែនការបង្វែរ ត្រូវមាននិទ្ទេសដូចខាងក្រោម ៖

- វិធានការបង្វែរណាមួយ និងរយៈពេលនៃការអនុវត្តផែនការបង្វែរ[74]
- បញ្ជាក់លម្អិតអំពីសេវា និងជំនួយដែលត្រូវផ្តល់ឲ្យអនីតិជន
- បញ្ជាក់ឲ្យបានច្បាស់ពីបុគ្គល ឬអង្គការដែលផ្តល់សេវា និងជំនួយទាំងនោះ
- បញ្ជាក់ពីការទទួលខុសត្រូវរបស់អនីតិជន និងអ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ជាក់ពីគោលបំណងផ្ទាល់របស់អនីតិជន និងអ្នកតំណាងដែលច្បាប់បានកំណត់
- បញ្ចូលកម្មវិធីផ្សេងទៀតទាក់ទងនឹងការអប់រំ ការបម្រើការងារ ការកម្សាន្ត និងសុខុមាលភាពរបស់អនីតិជនទៅតាមស្ថានភាពដែលពាក់ព័ន្ធ
- បញ្ជាក់ពីអាជ្ញាធរ ឬជនសមស្របដែលទទួលបន្ទុកអនុវត្តផែនការបង្វែរ (អាជ្ញាធរ ឬជនសមស្របទាំងនេះអាចជា នគរបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ គ្រូបង្រៀន ឬសមាជិកសមស្របណាមួយនៃសហគមន៍)
- បញ្ជាក់ពីភ្នាក់ងារសង្គមកិច្ច ដែលទទួលបន្ទុកត្រួតពិនិត្យ តាមដាន និងអនុវត្តផែនការបង្វែរ
- បញ្ជាក់អំពីការយល់ព្រមរបស់អនីតិជនចំពោះផែនការបង្វែរ។

ផែនការបង្វែរត្រូវចុះ ៖

- អត្តសញ្ញាណ និងហត្ថលេខារបស់ភ្នាក់ងារសង្គមកិច្ច
- អត្តសញ្ញាណ និងស្នាមម្រាមដៃរបស់អនីតិជន

---

[74] សូមមើលទំព័រ ១២ និង ១៣ ស្តីពី នីតិវិធីនៃការបង្វែរ

- អត្តសញ្ញាណ ហត្ថលេខា ឬស្នាមមេដៃបុគ្គលដែលពាក់ព័ន្ធ។

ច្បាប់ចម្លងនៃផែនការបង្វែរ ត្រូវធ្វើការរក្សាទុកជាការសម្ងាត់នៅការិយាល័យរបស់ភ្នាក់ងារសង្គមកិច្ច ។

ប៉ុន្តែនៅក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរ មិនយល់ស្របចំពោះផែនការបង្វែរដែលរៀបចំដោយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរ ត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំឡើងវិញនូវផែនការបង្វែរថ្មី។ ផែនការបង្វែរត្រូវសម្រេចនៅក្នុងអំឡុងពេលមិនលើសពី ១ ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាបង្គាប់ លើកលែងតែមានស្ថានភាពដែលមិនអាចជម្នះបាន ។

នៅក្នុងអំឡុងពេលអនុវត្តផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរ អាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬទៅតាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍របស់អនីតិជនដោយត្រូវសម្រេចនៅក្នុងរយៈពេល ៥ ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច។ ក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនបានសម្រេចក្នុងថិរវេលានេះ ត្រូវចាត់ទុកថាយល់ស្របតាមការស្នើសុំ ។

ការកែប្រែផែនការបង្វែរ មិនត្រូវបានចាត់ទុកថាជាបរាជ័យក្នុងការអនុវត្តផែនការបង្វែរទេ។

## ២.៣. ដំណាក់កាលចៅក្រមស៊ើបសួរ

ក្រោយពេលដែលទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីតំណាងអយ្យការហើយ ចៅក្រមស៊ើបសួរ ត្រូវបើកការស៊ើបសួរភ្លាម។ ចៅក្រមស៊ើបសួរ ដែលទទួលបន្ទុកលើរឿងក្តីអនីតិជន ត្រូវតែជាចៅក្រម ដែលមានជំនាញទាក់ទងនឹងអនីតិជន។ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ និង ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ បានកំណត់អំពីតួនាទីរបស់ចៅក្រមស៊ើបសួរ (២.៣.១) និង អំណាចរបស់ចៅក្រមស៊ើបសួរ (២.៣.២) មានដូចខាងក្រោម ៖

### ២.៣.១. តួនាទីរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ គឺជាចៅក្រម ដែលមានតួនាទីក្នុងការស្វែងរកការពិត មានន័យថាចៅក្រមនេះស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។ ចៅក្រមនេះបំពេញកិច្ចស៊ើបសួរទាំងអស់ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញការពិត។

ជាទូទៅ ចៅក្រមស៊ើបសួរមានភារៈកិច្ចបើកការស៊ើបសួរ ដាក់ជនសង្ស័យឲ្យស្ថិតក្រោមការត្រួតពិនិត្យ និងស្តាប់ចម្លើយ។ ប៉ុន្តែចៅក្រមនេះក៏មានសិទ្ធិអំណាចជាច្រើនទៀត ដែលមានដូចខាងក្រោម ៖

### ២. ៣. ១. ១. សមត្ថកិច្ចនៃការស៊ើបសួរ

ចៅក្រមស៊ើបសួរ ដែលទទួលបានសមត្ថកិច្ចក្នុងការស៊ើបសួរលើករណី ដែលពាក់ព័ន្ធនឹង អនីតិជន ត្រូវតែជាចៅក្រមដែលមានជំនាញទាក់ទងនឹងអនីតិជន។

ការស៊ើបសួរត្រូវតែអនុវត្តភ្លាម ក្រោយពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពី តំណាងអយ្យការ។ នៅពេលបើកការស៊ើបសួរ អនីតិជនជាប់សង្ស័យត្រូវតែមានមេធាវីអមជានិច្ច[75]។ ក្នុងករណីគ្មានមេធាវី ចៅក្រមស៊ើបសួរ ត្រូវចាត់តាំងមេធាវីនៅក្នុងលក្ខខណ្ឌដែលមានចែងដោយ ច្បាប់លក្ខន្តិកមេធាវី ។

### ២. ៣. ១. ២. ការជូនដំណឹងអំពីការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ

ចៅក្រមស៊ើបសួរ ត្រូវតែធ្វើការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យនូវបុគ្គល ដែលមានឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងករណី ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីចង្វាក់គ្នាយ៉ាងខ្លាំង ដែលអាចជឿជាក់ថាជនសង្ស័យពិតជា បានចូលរួមប្រព្រឹត្តបទល្មើស។ ចៅក្រមស៊ើបសួរ អាចដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការពិនិត្យ ក្នុងឋានៈជា ចារី សហចារី ឬអ្នកផ្ដើមគំនិត ឬជាអ្នកសមគំនិត។ នៅពេលអនីតិជនបង្ហាញខ្លួនលើក ដំបូង ចៅក្រមស៊ើបសួរត្រូវត្រួតពិនិត្យពីអត្តសញ្ញាណអនីតិជន, ប្រាប់អនីតិជនឲ្យដឹងពីរឿងរ៉ាវដែល ត្រូវបានចោទប្រកាន់, អំពីឈ្មោះបទល្មើសដែលបានកំណត់ដោយច្បាប់ និងអំពីសិទ្ធិទាក់ទងនឹង ដំណាក់កាលស៊ើបសួរគឺ សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី[76] ។

ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឲ្យអ្នកតំណាងដែលច្បាប់បាន កំណត់ ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច អំពីការដាក់ជនជាប់សង្ស័យឲ្យស្ថិតនៅក្រោមការ ត្រួតពិនិត្យ[77]។

វិធានទាំងនេះ មានលក្ខណៈដាច់ខាតដែលត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមាន មោឃភាពនៃនីតិវិធី ។

### ២. ៣. ១. ៣. ការស្ដាប់ចម្លើយ

ការស្ដាប់ចម្លើយ ឬការសាកសួរអនីតិជនត្រូវ ៖

- ធ្វើជាសម្ងាត់ និងប្រើនីតិវិធីកុមារមេត្រី

---

[75] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ ១៩៦៦, មាត្រា ១៤

[76] សូមមើលទំព័រ ៥ ស្ដីពីសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

[77] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៣៣

- ត្រូវមានវត្តមានមេធាវីការពារ ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច (នៅក្នុងករណីលើកលែងចៅក្រម អាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមាននៃអ្នកទាំងនោះធ្វើឲ្យផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ដោយការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយ មេធាវី ភ្នាក់ងារសង្គមកិច្ច និងអនីតិជន)
- នៅក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអវត្តមាន ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុ
- ឲ្យអនីតិជនអានកំណត់ហេតុស្តាប់ចម្លើយ ឬឲ្យក្រឡាបញ្ជីអានឲ្យស្តាប់ ហើយអនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយ មុនពេលចុះហត្ថលេខា ឬផ្តិតមេដៃ
- មេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចត្រូវបានអនុញ្ញាតឲ្យអានកំណត់ហេតុស្តាប់ចម្លើយប្រសិនបើមានការស្នើសុំ
- ក្នុងករណីអនីតិជន ឬអ្នកចូលរួមណាមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុចៅក្រមត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ។

ចៅក្រមស៊ើបសួរ អាចពន្យារពេល ឬប្តូរកាលបរិច្ឆេទនៃការស្តាប់ចម្លើយបាន ក្នុងករណីដែលមេធាវីរបស់អនីតិជនអវត្តមាន និងរើសកាលបរិច្ឆេទដើម្បីស្តាប់ចម្លើយថ្មី ដោយត្រូវកោះហៅមេធាវីដើម្បីចូលរួមក្នុងការស្តាប់ចម្លើយ លើកលែងតែក្នុងករណីបន្ទាន់ ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបាត់បង់ភស្តុតាង។ ប្រភេទនៃការបន្ទាន់ ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។

វត្តមាន ឬអវត្តមានរបស់មេធាវី មិនរារាំងចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការឃុំខ្លួន ឬមិនឃុំខ្លួនបណ្តោះអាសន្នទេ[78] ។

### ២. ៣. ២. អំណាចរបស់ចៅក្រមស៊ើបសួរ

នៅពេលដែលអនីតិជន ត្រូវបានជាប់សង្ស័យ ឬពាក់ពន្ធ័នឹងការប្រព្រឹត្ត ឬការចូលរួមប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរ មានសិទ្ធិក្នុងការសម្រេចបង្គាប់ឲ្យមានការព្យួរការសិក្សា ឬការងាររបស់អនីតិជន, ការបង្វែររឿងក្តីអនីតិជនចេញពីនីតិវិធីរបស់តុលាការព្រហ្មទណ្ឌ, ការឃុំខ្លួនអនីតិជនបណ្តោះអាសន្ន ឬការដោះលែងអនីតិជនឲ្យនៅក្រៅឃុំ។

[78] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៣៦

### ២. ៣. ២. ១. ការព្យួរការសិក្សា ឬការងាររបស់អនីតិជន

ចៅក្រមស៊ើបសួរ អាចបង្គាប់គ្រឹះស្ថានសិក្សា ឬនិយោជក ព្យួរការសិក្សា ឬមិនឲ្យព្យួរការងាររបស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ។ នៅក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវបានអនុវត្តផែនការបង្វែរ គ្រឹះស្ថានដែលអនីតិជនកំពុងសិក្សា ឬនិយោជកដែលអនីតិជនបានបំពេញការងារ អាចព្យួរការសិក្សា ឬព្យួរការងារអនីតិជនរហូតដល់មានសេចក្តីសម្រេចរបស់តុលាការជាស្ថាពរ។ ក្នុងករណីតុលាការសម្រេចសេចក្តីថា អនីតិជនគ្មានទោសទេនោះ គ្រឹះស្ថានសិក្សា ឬនិយោជក ត្រូវអនុញ្ញាតឲ្យអនីតិជនចូលសិក្សា ឬធ្វើការធម្មតាឡើងវិញ។

### ២. ៣. ២. ២. អំណាចក្នុងការបង្វែរ

ដូចគ្នានឹងដំណាក់កាលអយ្យការដែរ ចៅក្រមស៊ើបសួរ មានសិទ្ធិអំណាចក្នុងការបង្វែររឿងក្តីរបស់អនីតិជនចេញពីនីតិវិធីព្រហ្មទណ្ឌបានផងដែរ[79]។

ជាទូទៅការបង្វែរ ជាចំនុចបឋមដែលត្រូវយកមកធ្វើការពិចារណា។ ការបង្វែរក្នុងដំណាក់កាលចៅក្រមស៊ើបសួរ អាចអនុវត្តបានតែចំពោះអនីតិជន ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈឹម ឬបទមជ្ឈឹមដែលមានស្ថានទម្ងន់ទោស។

ករណីដែលរឿងក្តីអនីតិជនត្រូវបង្វែរ ចៅក្រមស៊ើបសួរ ត្រូវផ្អាកនីតិវិធីដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជននោះ (ប្រសិនបើអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន)។ បើសិនជាផែនការបង្វែរត្រូវការពេលវេលារៀបចំ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រង និងថែទាំ។

នៅពេលដែលការបង្វែរទទួលបានជោគជ័យ ចៅក្រមស៊ើបសួរត្រូវតែចេញនូវដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ដោយផ្អែកលើរបាយការណ៍ ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ។ ប៉ុន្តែបើការបង្វែរមិនជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាលើមូលហេតុដែលបរាជ័យ ឬអាចបន្តនីតិវិធីស៊ើបសួរ[80]។

[79] សូមមើលទំព័រ ១១ ដល់ទំព័រ ១៦ ស្តីពី ការបង្វែរ

[80] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៣៨

### ២. ៣. ២. ៣. ការឃុំខ្លួនបណ្ដោះអាសន្ន

ប្រសិនបើលក្ខខណ្ឌអប្បបរមានៃការបង្វែរ និងលក្ខណវិនិច្ឆ័យសម្រាប់ការបង្វែរ មិនត្រូវបានបំពេញទេនោះ តែតុលាការបែរជាមានសំអាងហេតុគ្រប់គ្រាន់ ឬចាំបាច់ក្នុងការឃុំខ្លួននោះ តុលាការអាចនឹងសម្រេចឃុំខ្លួនអនីតិជនត្រូវចោទបណ្ដោះអាសន្នបាន ដោយចេញនូវដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន និងដីកាបង្គាប់ឲ្យឃុំខ្លួន។

ជាគោលការណ៍ ការឃុំខ្លួនបណ្ដោះអាសន្នអាចអនុវត្តបានតែក្នុងករណីដែលអនីតិជន មានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ ឆ្នាំប៉ុណ្ណោះ[81]។ ហើយការឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន ត្រូវធ្វើឡើងជាវិធានការចុងក្រោយប៉ុណ្ណោះ។ ការឃុំខ្លួននេះត្រូវធ្វើដោយផ្អែកទៅលើមូលហេតុនៃការឃុំខ្លួន (២.៣.២.៣.ក) និងថិរវេលានៃការឃុំខ្លួន (២.៣.២.៣.ខ) ៖

#### ២. ៣. ២. ៣. ក. មូលហេតុនៃការឃុំខ្លួន

ករណីចាំបាច់ចៅក្រមស៊ើបសួរ អាចបង្គាប់ឲ្យឃុំខ្លួនអនីតិជនបណ្ដោះអាសន្នបានដើម្បី ៖

- បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី
- រារាំងកុំឲ្យមានការគាបសង្កត់ទៅលើសាក្សី ជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- រក្សាភស្ដុតាង ឬតម្រុយជាសម្ភារៈ
- ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
- ការពារសន្តិសុខឲ្យជនត្រូវចោទ
- ធានារក្សាការពារសណ្ដាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស[82]។

#### ២. ៣. ២. ៣. ខ. ថិរវេលានៃការឃុំខ្លួន

ជាគោលការណ៍ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនត្រូវឃុំខ្លួនបណ្ដោះអាសន្នទេ។ ចៅក្រមស៊ើបសួរ អាចសម្រេចប្រគល់អនីតិជននេះឲ្យទៅ ឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុង

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ២០៤ និង មាត្រា ២១២
[82] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ២០៥

ករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្នដោយរង់ចាំសេចក្ដីសម្រេចរបស់តុលាការ ។

ប៉ុន្តែនៅក្នុងករណីអនីតិជន ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ បានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ចៅក្រមអាចសម្រេចឃុំខ្លួនបាន។ ថិរវេលានៃការឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន ដែលត្រូវយកមកអនុវត្តមានដូចតទៅ ៖

**អនីតិជនប្រព្រឹត្តបទឧក្រិដ្ឋ ៖**

- អនីតិជនអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចឃុំខ្លួនបណ្ដោះអាសន្នហួសពី ៤ ខែ
- អនីតិជនអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចឃុំខ្លួនបណ្ដោះអាសន្នហួសពី ៦ ខែ

**អនីតិជនប្រព្រឹត្តបទមជ្ឈិម ៖**

- អនីតិជនអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចឃុំខ្លួនបណ្ដោះអាសន្នហួសពី ២ ខែ
- អនីតិជនអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចឃុំខ្លួនបណ្ដោះអាសន្នហួសពី ៤ ខែ។

ចំពោះបទមជ្ឈិម ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននោះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោស ដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។

ដូចជាក្នុងករណី៖ អនីតិជនអាយុ ១៦ ឆ្នាំ បានប្រព្រឹត្តបទហិង្សាដោយចេតនា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ (មាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ)។ ក៏ប៉ុន្តែ ដោយយោងទៅលើមូលហេតុនៃអាយុ ជនត្រូវចោទ នាំឲ្យមូលទោសត្រូវបន្ថយមកត្រឹម ៦ ខែ ទៅ ១ ឆ្នាំ ៦ ខែ (យោងទៅតាម មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ)។ ដូច្នេះពាក់កណ្ដាលអប្បបរមានៃទោសគឺ ៣ ខែ ដែលជាហេតុនាំឲ្យការឃុំខ្លួន អនីតិជនបណ្ដោះអាសន្ន មិនអាចលើសពី ៣ខែ ទេ (ដោយគិតចាប់ពីថ្ងៃដែលអនីតិជនត្រូវបាននាំខ្លួនមកដល់ប៉ុស្តិ៍នគរបាល)។

### ២. ៣. ២. ៤. ការដោះលែងឲ្យនៅក្រៅឃុំ

ទោះបីជាជនត្រូវចោទ ត្រូវបានឃុំខ្លួនបណ្ដោះអាសន្នក៏ដោយ ប៉ុន្តែជនត្រូវចោទក៏អាចត្រូវបានដោះលែងឲ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា កាលបើមានមូលហេតុចាំបាច់ ឬអាចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជំនួសវិញ។ ការដោះលែងមុនពេលកំណត់នេះ អាចធ្វើទៅបានដោយអាស្រ័យទៅលើ ឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ (២.៣.២.៤.ក), បណ្ដឹងរបស់ព្រះរាជអាជ្ញា (២.៣.២.៤.ខ) ឬបណ្ដឹងរបស់ជនត្រូវចោទ (២.៣.២.៤.គ)។

### ២. ៣. ២. ៤. ក. ឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ អាចបង្គាប់ឲ្យដោះលែងអនីតិជនបានគ្រប់ពេលវេលាដោយគំនិតផ្តួចផ្តើមរបស់ខ្លួន។ ចៅក្រមស៊ើបសួរ ដែលមានបំណងដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ដោយភ្ជាប់ជាមួយនឹងសំណុំរឿង ជូនព្រះរាជអាជ្ញាតាមរយៈដីកាបញ្ជូនឲ្យឆ្លើយ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលខ្លីបំផុត។

ប៉ុន្តែនៅក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរ អាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាមដោយមិនបាច់រង់ចាំយោបល់របស់ព្រះរាជអាជ្ញា ឬទោះបីជាមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ។ ចៅក្រមស៊ើបសួរ ត្រូវធ្វើការចង្អុលបង្ហាញប្រាប់ពីមូលហេតុនៃការបន្ទាន់នោះ នៅក្នុងដីកាសម្រេចរបស់ខ្លួន[83]។

### ២. ៣. ២. ៤. ខ. បណ្តឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា អាចសុំឲ្យដោះលែងអនីតិជនត្រូវចោទបានគ្រប់ពេលវេលា ដោយធ្វើសេចក្តីសន្និដ្ឋានសុំឲ្យដោះលែងជនត្រូវចោទ។ ចៅក្រមស៊ើបសួរ ត្រូវសម្រេចនៅក្នុងរយៈពេល ៥ ថ្ងៃ ដោយចេញដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំ ឬដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ (ត្រូវមានសំអាងហេតុ)។

ប្រសិនបើ ចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេលកំណត់ទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរឲ្យសម្រេចជំនួស[84] ។

### ២. ៣. ២. ៤. គ. បណ្តឹងរបស់ជនត្រូវចោទ

អនីតិជនត្រូវចោទ ឬមេធាវីរបស់អនីតិជន អាចដាក់ពាក្យសុំឲ្យដោះលែងឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលាទៅចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរ ត្រូវបញ្ជូនពាក្យសុំនេះភ្ជាប់ជាមួយសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ និងផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។

ចៅក្រមស៊ើបសួរ ត្រូវចេញដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំ ឬដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ យ៉ាងយូរបំផុតក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ក្នុងករណីដែលចៅក្រមស៊ើបសួរ មិនព្រមសម្រេចក្នុងរយៈពេល ៥ ថ្ងៃទេ ជនត្រូវចោទអាចប្តឹងទៅសភាស៊ើបសួរឲ្យសម្រេចជំនួស។

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ២១៥; រុន ពណ្ណារិទ្ធិ, ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០១៥-២០១៦

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ២១៦; រុន ពណ្ណារិទ្ធិ, ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០១៥-២០១៦

ជនត្រូវចោទ អាចដាក់ពាក្យបណ្តឹងសុំឲ្យនៅក្រៅឃុំសារជាថ្មី ក្នុងរយៈពេល ១ ខែ បន្ទាប់ពីទទួលបានដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ (មានសំអាងហេតុ)។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ ត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ក្រោយពីទទួលបានពាក្យបណ្តឹង[85]។

### ២.៣.២.៥. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ជាគោលការណ៍ អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនអាចត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ[86]។

កាលណាចៅក្រមស៊ើបសួរ សម្រេចឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ចៅក្រមអាចដាក់ជននោះឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ បានគ្រប់ពេលវេលាទៅតាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ឬតាមរយៈសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញាជំនួសឲ្យការឃុំខ្លួនជាបណ្តោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ ចៅក្រមស៊ើបសួរ បញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីកាតព្វកិច្ច ដែលតម្រូវឲ្យជនត្រូវចោទនោះអនុវត្ត។

ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ឲ្យជនត្រូវចោទដែលនៅក្រៅឃុំ គោរពនូវកាតព្វកិច្ចមួយ ឬច្រើន ដែលមានដូចជា៖

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពី ឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប
- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀត ដែលតុលាការយល់ឃើញថាសមស្រប[87]។

ចៅក្រមស៊ើបសួរ អាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច ឬអាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មី ឬអាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ដោយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតទៅព្រះរាជអាជ្ញា និងជនត្រូវចោទ។ ក្នុងករណីមានបណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា ចៅក្រមត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ

[85] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ២១៧; រុន ពណ្ណារិទ្ធិ, ចាំង ស៊ីណាត, នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០១៥-២០១៦
[86] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ២២៤
[87] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ២២៣; ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៤០

ដោយដីកាសម្រេច (ដីសម្រេចយល់ព្រមតាមពាក្យសុំ ឬដីកាសម្រេចមិនព្រមធ្វើតាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញាដោយមានសំអាងហេតុ) ហើយត្រូវជូនដំណឹងទៅឲ្យព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមមិនបានសម្រេចនៅក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញាអាចដាក់ពាក្យសុំទៅសភាស៊ើបសួរដើម្បីឲ្យសម្រេចជំនួស។ ដោយឡែកក្នុងករណីជនត្រូវចោទ ស្នើសុំលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរ បញ្ជូនពាក្យសុំ និងសំណុំរឿងនេះទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ និងសុំយោបល់ដោយត្រូវសម្រេចយ៉ាងយូរបំផុតនៅក្នុងរយៈពេល ៥ ថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដោយដីកាសម្រេចហើយត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា និងជនត្រូវចោទនៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ។

កាលណាមានពាក្យសុំលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានធ្វើជាថ្មី មុនពេលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំពីមុននោះ រយៈពេលប្រាំថ្ងៃនេះត្រូវចាប់ផ្តើមគិតពីពេលចេញសេចក្តីសម្រេចលើពាក្យសុំពីមុន។ ដីកាសម្រេចមិនព្រមធ្វើតាមពាក្យសុំ ត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រម មិនបានសម្រេចក្នុងរយៈពេល ៥ ថ្ងៃនេះទេ ជនត្រូវចោទអាចធ្វើបណ្តឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

ប្រសិនបើជនត្រូវចោទបានគេចវេសដោយចេតនា ពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រម អាចសម្រេចឲ្យឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នបាន ទោះបីជាទោសជាប់ពន្ធនាគារដែលត្រូវទទួលរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ឬទោះបីជាជនត្រូវចោទ ត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមាប៉ុន្មានក៏ដោយ។ កាលណាចៅក្រម សម្រេចថានឹងឃុំខ្លួនជាបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមត្រូវជូនដំណឹងដល់ជនត្រូវចោទនោះ និងទទួលការកត់សម្គាល់របស់ជននោះ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវរកមធ្យោបាយការពារកូនក្តីរបស់ខ្លួន ។

ចៅក្រមស៊ើបសួរ សម្រេចឃុំខ្លួនជនត្រូវចោទតាមដីកាដែលមានសំអាងហេតុ និងត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

## ២.៤. ដំណាក់កាលសវនាការរបស់ចៅក្រមជំនុំជម្រះ

ជាទូទៅរឿងក្តីរបស់អនីតិជន ត្រូវបានច្បាប់ផ្តល់អាទិភាពឲ្យ ហេតុនេះនៅពេលដែលសំណុំរឿងរបស់អនីតិជនបានបញ្ជូនមកដល់តុលាការហើយ តុលាការដែលមានសមត្ថកិច្ចត្រូវយករឿងក្តីរបស់អនីតិជនមកចាត់ការភ្លាម ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន។ ចំពោះ

សមត្ថកិច្ចតុលាការ ដែលជាប់ពាក់ព័ន្ធរួមមានទាំង តុលាការជាន់ទាប (សាលាដំបូងរាជធានី-ខេត្ត) និងតុលាការជាន់ខ្ពស់ (សាលាឧទ្ធរណ៍ និងតុលាការកំពូល)។

### ២.៤.១. សមត្ថកិច្ចរបស់តុលាការជាន់ទាប

រាល់បទឧក្រិដ្ឋ បទមជ្ឈឹម និងបទលហុ ដែលមានជនជាប់ចោទជាអនីតិជន ត្រូវប្រគល់ឲ្យសាលាដំបូង ដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជន[88]។ ចំពោះសេចក្តីសម្រេច ត្រូវធ្វើជាក្រុមសមូហភាពដោយមានចៅក្រម ៣ រូប ចំពោះបទឧក្រិដ្ឋ និងមជ្ឈឹម និង ១ រូប ចំពោះបទលហុ។

#### ២.៤.១.១. នីតិវិធីមុនសវនាការ

ក្រៅពីនីតិវិធីទូទៅ ដែលត្រូវអនុវត្តមុនពេលសវនាការ ដែលត្រូវបានប្បញ្ញត្តិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក្នុងរឿងក្តីអនីតិជន តុលាការត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច។

ករណីដែលរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់បានរៀបចំ ហើយតុលាការត្រូវការព័ត៌មានបន្ថែម តុលាការត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះតាមតម្រូវការ។

#### ២.៤.១.២. នីតិវិធីសវនាការ

ចំពោះរឿងក្តីអនីតិជន ការពិភាក្សាដេញដោល និងការប្រកាសសាលក្រម ត្រូវធ្វើឡើងក្នុងសវនាការជាអសាធាណៈ ដោយមានតែបុគ្គលដែលមានសិទ្ធិ និងកាតព្វកិច្ច ឬផលប្រយោជន៍ពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះ ដែលមានសិទ្ធិចូលរួមក្នុងសវនាការ លើកលែងតែមានសំណូមពរពីអនីតិជនផ្ទុយពីនេះបើតុលាការយល់ឃើញថា ការចូលរួមរបស់បុគ្គលទាំងនោះ មិនបានបម្រើឧត្តមប្រយោជន៍របស់អនីតិជន។ អនីតិជន ត្រូវតែមានវត្តមានមេធាវីអមជានិច្ច។

នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនពីសិទ្ធិដែលខ្លួនមានដូចជា សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី[89] សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ សិទ្ធិប្តឹងជិតជិតចៅក្រមជំនុំជម្រះ សិទ្ធិធ្វើសំណូមពរចុងក្រោយ និងសិទ្ធិប្តឹងឧទ្ធរណ៍ ។

[88] គោលការណ៍ណែនាំស្តីពីវិធានការណ៍ទាក់ទងនឹងកុមារក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ឆ្នាំ ១៩៩៧, វិធាន ១៤ ចំនុច គ

[89] សូមមើលទំព័រ ៥ ស្តីពី សិទ្ធិជាមូលដ្ឋានរបស់អនីតិជន

រីឯនីតិវិធី ដែលត្រូវយកមកអនុវត្តនៅពេលសវនាការ គឺត្រូវប្រើនីតិវិធីកុមារមេត្រី។ លើសពីនេះទៅទៀត ក្នុងករណីចាំបាច់ ឬកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ឬភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឲ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ។ ចំពោះចម្លើយសារភាពរបស់អនីតិជននោះ តុលាការត្រូវផ្ទៀងផ្ទាត់ថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬការបង្ខិតបង្ខំ ហើយអនីតិជនបានយល់អំពីផលវិបាកនៃការសារភាពនេះ។ បន្ថែមពីលើនេះទៀត តុលាការត្រូវពិនិត្យពីភាពស៊ីចង្វាក់គ្នានៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើសផងដែរ។ បើមិនដូច្នោះទេនោះ ចម្លើយសារភាពដែលទទួលបានមិនអាចចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពឡើយ[90] ។

ប្រសិនបើតុលាការពិនិត្យឃើញថា អនីតិជនត្រូវចោទមានអាយុតិចជាង ១៤ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ឬអំពើរបស់អនីតិជនមិនមែនជាបទល្មើស នោះតុលាការត្រូវឲ្យអនីតិជនរួចផុតពីការចោទប្រកាន់ ហើយត្រូវដោះលែងជាបន្ទាន់ដោយប្រគល់អនីតិជនឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញ ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ[91] ។

ក្រោយពីការពិភាក្សាដេញដោលត្រូវបានបញ្ចប់ តុលាការ អាចប្រកាសសាលក្រម នៅពេលសវនាការ ឬនៅពេលសវនាការលើកក្រោយជាអសាធារណៈនៅចំពោះមុខអនីតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ឬភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍។ ប៉ុន្តែក្នុងករណីដែលការប្រកាសសាលក្រម អាចនាំឲ្យប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់អនីតិជន តុលាការអាចប្រកាសសាលក្រមកំបាំងមុខអនីតិជនបាន[92]។

ចំពោះអនីតិជនដែលបានប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ឬបទមជ្ឈិមមានស្ថានទម្ងន់ទោស តុលាការត្រូវពិចារណាជាបឋមក្នុងការបង្វែរ។ ចំពោះយន្តការ និងនីតិវិធីនៃការបង្វែររបស់តុលាការជាន់ទាប និងតុលាការជាន់ខ្ពស់ គឺមានលក្ខណៈដូចគ្នា[93]។

### ២.៤.២. សមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់

នៅក្នុងរឿងក្តីអនីតិជន ត្រូវជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ ដែលមានសមាសភាព ៣ រូប ឬ ៥ រូប ក្នុងករណីរឿងក្តីណា ដែលតុលាការកំពូលបានបង្វិលមកវិញ និងដោយ

[90] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៥៣

[91] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៤៩, កថាខណ្ឌទី១ និងទី ៣

[92] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៥៤

[93] សូមមើលទំព័រ ១១ ដល់ទំព័រ ១៦ ស្តីពី ការបង្វែរ

ក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល ដែលមានសមាសភាពចៅក្រមចំនួន ៥ រូប ឬ ៩ រូបក្នុងករណីមានបណ្ដឹងសាទុក្ខលើកទី២ ដែលក្នុងចំណោមនោះ តម្រូវឲ្យមានចៅក្រមដែលមានជំនាញទាក់ទងនឹងអនីតិជនយ៉ាងតិច ១ រូប[94] ។

### ២.៤.២.១. ការប្ដឹងទៅតុលាការជាន់ខ្ពស់

ការធ្វើបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសាទុក្ខ អាចធ្វើដោយព្រះរាជអាជ្ញានៃតុលាការជាន់ទាប អគ្គព្រះរាជអាជ្ញាអមតុលាការជាន់ខ្ពស់ ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី[95]។ រីឯការរៀបចំសំណុំរឿងបញ្ជូនបណ្ដឹង ជាតួនាទីរបស់ក្រឡាបញ្ជីនៃតុលាការ ដែលមានសមត្ថកិច្ច។

ចំពោះថិរវេលានៃការបញ្ជូនបណ្ដឹងគឺ ៖

- បណ្ដឹងឧទ្ធរណ៍ ៖ ត្រូវបញ្ជូនក្នុងរយៈពេលមិនលើស ១០ ថ្ងៃ ទៅសាលាឧទ្ធរណ៍
- បណ្ដឹងសាទុក្ខ ៖ ត្រូវបញ្ជូនក្នុងរយៈពេលមិនលើស ១០ ថ្ងៃ ទៅតុលាការកំពូល។

ថិរវេលានៃការបញ្ជូនបណ្ដឹង ត្រូវគិតចាប់តាំងពីថ្ងៃប្ដឹង (ឧទ្ធរណ៍ ឬសាទុក្ខ)។ ក្នុងករណីដែលមានកាលៈទេសៈមិនអាចជម្នះបាន ដែលនាំឲ្យមានការយឺតយ៉ាវដល់ការបញ្ជូនបណ្ដឹង ត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន[96] ។

### ២.៤.២.២. ការទទួលបានសិទ្ធិអាទិភាពជំនុំជម្រះមុន

ដោយគិតពីឧត្តមប្រយោជន៍របស់អនីតិជន ច្បាប់បានផ្ដល់សិទ្ធិអាទិភាពដល់អនីតិជនជាប់សង្ស័យ ឬអនីតិជនដែលជាប់ឃុំ ឲ្យទទួលបាននូវសិទ្ធិក្នុងការជំនុំជម្រះមុនជានិច្ច មិនថារឿងក្ដីស្ថិតនៅដំណាក់កាលសាលាដំបូង សាលាឧទ្ធរណ៍ ឬតុលាការកំពូលនោះទេ។

ចំពោះអនីតិជនដែលជាប់ឃុំ តុលាការនៃសាលាឧទ្ធរណ៍ ឬតុលាការកំពូល ត្រូវលើកយករឿងក្ដីនោះ មកជំនុំជម្រះក្នុងរយៈពេលមិនលើសពី ៣ ខែ (គិតពីថ្ងៃទទួលសំណុំរឿង) លើកលែងតែមានមូលហេតុសត្យានុម័តមិនអាចជម្នះបាន។ ទោះបីជាយ៉ាងណា ក្នុងពេលរង់ចាំការជំនុំជម្រះ ឬរឿងក្ដីត្រូវបានពន្យារពេលជំនុំជម្រះ តុលាការត្រូវគិតពិចារណាពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្ដោះអាសន្នឲ្យមានសេរីភាព[97] ។

[94] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៥៥; ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ឆ្នាំ ២០១៤, មាត្រា ៣៩, មាត្រា ៥៩ និងមាត្រា ៦២, កថាខណ្ឌទី ៥

[95] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ៣៧៥

[96] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៥៦

[97] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៥៧

ចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើស បទលហុ បទមជ្ឈឹម ឬបទមជ្ឈឹមដែលមានស្ថានទម្ងន់ទោស តុលាការ អាចពិចារណាក្នុងការបង្វែររឿងក្តីអនីតិជនចេញពីនីតិវិធីព្រហ្មទណ្ឌ។

# ជំពូកទី ៣៖ ការប្រកាសទោស និងការអនុវត្តទោសចំពោះអនីតិជន

## ៣. ១. របបនៃការប្រកាសទោស

បន្ទាប់ពីអនីតិជនត្រូវបានតុលាការវិនិច្ឆ័យសេចក្តី ដោយផ្អែកទៅលើ ធាតុផ្សំនៃបទល្មើស ឬភស្តុតាង[98] ឬចម្លើយសារភាពរបស់អនីតិជនហើយនោះ ដោយអាស្រ័យទៅលើអំពើនៃការប្រព្រឹត្តបទល្មើស ដែលអាចជាបទល្មើសឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ តុលាការអាចប្រកាសនូវទណ្ឌកម្ម[99] ព្រហ្មទណ្ឌលើអនីតិជន ដែលមានអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[100] ឬប្រើនូវទណ្ឌកម្មផ្សេងៗមួយចំនួនទៀត ដែលច្បាប់មានកំណត់យ៉ាងជាក់លាក់សម្រាប់អនុវត្តលើអនីតិជននោះ។ ប្រសិនបើតុលាការ ពិនិត្យឃើញថាមានពិរុទ្ធភាពលើជនជាប់ចោទ តុលាការប្រកាសផ្តន្ទាទោសតាមប្បញ្ញត្តិច្បាប់[101] ដូចខាងក្រោម ៖

### ៣. ១. ១. ការប្រកាសមូលទោស

ដើម្បីអាចយកទោសណាមួយទៅអនុវត្តចំពោះអនីតិជនបាននោះ លុះត្រាតែមានការប្រកាសដោយតុលាការនូវទោសនោះ[102] ហើយគ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ[103]។ តុលាការប្រកាសទោសណាមួយដោយផ្អែកទៅលើគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ[104] មានន័យថាបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនតែប៉ុណ្ណោះ មិនអាចឲ្យបុគ្គលណាមួយដែលមិនបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬដោយប្រយោលមកទទួលទោសជំនួសបុគ្គលនោះបានឡើយ។ រីឯគោលការណ៍ឯកត្តកម្មនៃទោស[105] សម្តៅដល់តុលាការប្រកាសទោស

[98] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ១៩៩ ៖ ព័ត៌មានគ្រប់ប្រភេទរួមមាន ឯកសារ ព្រឹត្តការណ៍ វត្ថុជាក់ស្តែងដែលដាក់បង្ហាញនៅពេលស៊ើបអង្កេត ស៊ើបសួរ ឬសវនាការដើម្បីបង្ហាញពីអត្ថិភាពនៃអង្គហេតុជាក់លាក់។

[99] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ១៩២ ៖ ការប្រកាសឲ្យសាធារណជនបានដឹងនូវទណ្ឌកម្មដែលត្រូវដាក់ចំពោះជនជាប់ចោទ ។

[100] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ៣៩, កថាខណ្ឌទី ២; ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៧, វាក្យខណ្ឌទី ២; រុន ពណ្ណារិទ្ធិ, ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅឆ្នាំ ២០១២, ទំព័រ ២៣៩ ៖ ក្រមព្រហ្មទណ្ឌ ពុំបានកំណត់និយមន័យ ឬផ្តល់នូវលក្ខណៈវិនិច្ឆ័យនៃពាក្យ កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន ដែលជាលក្ខខណ្ឌនៃការប្រកាសទោសទៅលើអនីតិជនឡើយ ។

[101] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ៣៥០, កថាខណ្ឌទី ២

[102] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ១១

[103] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ៦

[104] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ២៩, សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ៣៩

[105] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ៩៦ , សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២៩៧

ដោយផ្អែកទៅលើស្ថានទម្ងន់ទោស និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈ សភាពផ្លូវចិត្ត ឬធនធាន ឬមូលហេតុនៃការប្រព្រឹត្តបទល្មើស ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនជាប់សង្ស័យក្រោយពេលប្រព្រឹត្តបទល្មើស ចំពោះជនរងគ្រោះជាដើម។ ចំពោះការកំណត់អាយុ ១៤ ឆ្នាំសម្រាប់លទ្ធផលនៃការប្រកាសទណ្ឌកម្ម ដែលទណ្ឌកម្មនោះសម្តៅដល់ទោស គឺស្របទៅនឹងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុញ្ញាតឲ្យមានការឃុំខ្លួនជនត្រូវចោទ ឬជនជាប់ចោទជាបណ្ដោះអាសន្នចំពោះអនីតិជន អាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់ និងក្នុងថិរវេលាមួយ តិចជាងការឃុំខ្លួនបណ្ដោះអាសន្នលើនីតិជន[106] ។

កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ មូលទោស[107] លើបទល្មើសដែលចោទប្រកាន់ ត្រូវបន្ថយក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

១. អតិបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាល។

**ឧទាហរណ៍៖** លោក **ក** ជាអនីតិជនដែលមានអាយុ ១៧ ឆ្នាំ បានប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ យោងទៅតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។ ក្នុងប្បញ្ញត្តិនៃមាត្រានេះ តម្រូវឲ្យបន្ថយនូវមូលទោសពីបទល្មើស ដែលត្រូវចោទប្រកាន់ពោលគឺ អតិបរមានៃទោស ១០ (ដប់) ឆ្នាំ ត្រូវបន្ថយពាក់កណ្ដាលមកត្រឹម ៥ (ប្រាំ) ឆ្នាំ ចំណែកឯ អប្បបរមានៃទោសវិញគឺ ៥ (ប្រាំ) ឆ្នាំ ក៏ត្រូវបន្ថយពាក់កណ្ដាលផងដែរ គឺមកត្រឹម ២ (ពីរ) ឆ្នាំ ៦ (ប្រាំមួយ) ខែ។ ហេតុដូច្នេះ ទោសដែលលោក **ក** ត្រូវទទួលការផ្តន្ទាទោសនោះគឺ ២ (ពីរ) ឆ្នាំ ៦ (ប្រាំមួយ) ខែ ទៅ ៥ ឆ្នាំ សម្រាប់បទល្មើសរំលោភសេពសន្ថវៈ។ ឬអាចនិយាយបានម្យ៉ាងទៀតថា តុលាការមិនអាចដាក់ទោសលើជនល្មើសជាអនីតិជនលើសពី ៥ (ប្រាំ) ឆ្នាំ បានឡើយ ព្រោះនេះជាអតិបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់ជនជាប់ចោទជាអនីតិជន[108] ។

២. ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។

**ឧទាហរណ៍** ៖ **ក** ជាសិស្សនៃវិទ្យាមួយ ដែលមានអាយុ ១៦ ឆ្នាំ ហើយបានប្រព្រឹត្តបទល្មើស "ឃាតកម្មដោយមានទារុណកម្មអំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ" ដែលត្រូវផ្តន្ទាទោសដាក់

---

[106] រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ, ឆ្នាំ ២០១២, ទំព័រ ២៣៣; ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧, មាត្រា ២១៣ និងមាត្រា ២១៤

[107] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ៩៣; សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ១៩៥ ៖ ទោសដាក់ពន្ធនាគារ និងទោសពិន័យ

[108] រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ, ឆ្នាំ ២០១២, ទំព័រ ២៣៥

ពន្ធនាគារអស់មួយជីវិត យោងទៅតាមមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ។ ជនសង្ស័យខាងលើបាន ធ្វើសកម្មភាពរំលោភសិស្សនារី ខណៈពេលដែលនាងបានកំពុងធ្វើដំណើរទៅផ្ទះតែម្នាក់ឯង ដោយ បានចាប់នាងចូលកន្លែងស្ងាត់ ហើយបន្ទាប់មកក៏បានយកដៃច្របាច់.កនារីនោះរហូតដល់ស្លាប់ដើម្បី បំបាច់ភស្តុតាង។ ក្នុងករណីនេះ អតិបរមានៃទោសដាក់ពន្ធនាគារអស់មួយជីវិត ត្រូវបន្ថយមកត្រឹម ២០ (ម្ភៃ) ឆ្នាំ ដូច្នេះដោយយោងទៅលើមូលហេតុអាយុនៃជនល្មើស ហើយតុលាការមិនអាចប្រកាស ទោសលើសពីនេះបានទេ។

៣. អប្បបរមា នៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាល ប្រសិនបើអប្បបរមានោះ លើសពី ១ (មួយ) ថ្ងៃ។

៤. អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល។ នៅក្នុងករណី ចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះ មានអានុភាពបន្ថយអតិបរមានៃទោស ដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំនោះ បទល្មើសដែលចោទប្រកាន់នៅ តែជាបទឧក្រិដ្ឋដដែល។

**ឧទាហរណ៍៖** លោក **ក** បានប្រព្រឹត្តបទល្មើសលួច ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៦ (ប្រាំមួយ) ខែ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន)រៀល យោងតាមក្រមព្រហ្មទណ្ឌ។ នៅក្នុងករណីនេះទោសដែលត្រូវផ្តន្ទាទោសចំពោះ អនីតិជន ត្រូវបន្ថយទាំងអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ផងដែរ។ ដូច្នេះ ទោសដែលត្រូវយកមកអនុវត្តចំពោះអនីតិជនគឺ ទោសដាក់ពន្ធនាគារពី " បទលួច " គឺពី ៣ (បី) ខែ ទៅ ១ (មួយ) ឆ្នាំ ៦ (ប្រាំមួយខែ) និងពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន) រៀល ទៅ ៣.០០០.០០០ (បីលាន) រៀល ។

ករណីឧទាហរណ៍ ទី១ និងទី២ ខាងលើនេះ បើទោះបីជាមូលទោស ត្រូវបានបន្ថយក៏ដោយ ក៏បទល្មើសប្រព្រឹត្តដោយអនីតិជននោះ នៅតែជាបទល្មើសឧក្រិដ្ឋដដែល ពុំមែនជាបទមជ្ឈិមនោះ ទេ។

បន្ថែមលើសពីនេះទៅទៀត បទប្បញ្ញត្តិស្តីពីការមិនរាងចាល មិនអាចយកមកអនុវត្តចំពោះ អនីតិជន[109] បាននោះឡើយ ដែលសម្តៅដល់ថាបើទោះបីជាអនីតិជន បានប្រព្រឹត្តបទល្មើសនៅក្នុង

[109] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១៦៣

ស្ថានភាពនៃការមិនរាងចាលក៏ដោយ ក៏តុលាការមិនអាចយកស្ថានការទម្ងន់ទោស[110] ណាមួយយកមកអនុវត្តចំពោះអនីតិជននោះបានដែរ[111] ។

នៅក្នុងករណីបើកាលណា តុលាការបានសម្រេចឲ្យមានស្ថានសម្រាលទោស[112] អប្បបរមានៃមូលទោសលើអនីតិជនពីបទឧក្រិដ្ឋ ឬមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ ៖

១. ប្រសិនបើ អប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមាត្រូវបន្ថយមកត្រឹម ១ (មួយ) ឆ្នាំ ។

**ឧទាហរណ៍ ៖** បទឃាតកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ យោងទៅតាមមាត្រា ១៩៩ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើជនល្មើសជា អនីតិជន ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ផ្អែកតាមមាត្រា ១៦៤ តម្រូវឲ្យតុលាការបន្ថយនូវអប្បបរមានៃមូលទោសទៅលើបទល្មើសដែលត្រូវបានចោទប្រកាន់ មានន័យថាអប្បបរមានៃទោស ១០ (ដប់) ឆ្នាំ ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ចំណែកឯអតិបរមានៃមូលទោសគឺនៅដដែល។ ដូច្នេះ នៅពេលដែលជនល្មើសជាអនីតិជន ទោសដែលត្រូវផ្តន្ទាទោសគឺ ១ (មួយ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ សម្រាប់បទឃាតកម្ម។

២. ប្រសិនបើ អប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមាត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ។

**ឧទាហរណ៍៖** បទល្មើសរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ យោងទៅតាមមាត្រា ២៣៩ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើជនល្មើសជាអនីតិជន ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដោយយោងតាមមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ តម្រូវឲ្យតុលាការបន្ថយនូវអប្បបរមានៃមូលទោសលើបទល្មើស ដែលត្រូវបានចោទប្រកាន់។ មានន័យថា អប្បបរមានៃទោស ៥ (ប្រាំ) ឆ្នាំ ត្រូវបន្ថយមកនៅត្រឹម ៦ (ប្រាំមួយ) ខែ ចំណែកឯអតិបរមានៃមូលទោសគឺនៅដដែល។ ដូច្នេះ នៅពេលដែលជនល្មើសជាអនីតិជន ទោសដែលត្រូវផ្តន្ទាទោសគឺ ៦ (ប្រាំមួយ) ខែ ទៅ ១០ (ដប់) ឆ្នាំ សម្រាប់បទរំលោភសេពសន្ថវៈ។

[110] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ៩ ៖ ការតម្លើងស្ថានទម្ងន់ទោសឲ្យដល់កម្រិតអតិបរមាដាក់ទៅលើជនណាម្នាក់ ដែលច្បាប់បានកំណត់ ។

[111] វុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ, ឆ្នាំ ២០១២, ទំព័រ ២៣៧

[112] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២២៦, ២៤ ៖ កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ដែលញ៉ាំងឲ្យតុលាការសម្រេចឲ្យជនជាប់ចោទ បានទទួលនូវស្ថានសម្រាលទោស,ការបញ្ចុះទោសដល់ក្រោមអប្បបរមា ដែលដាក់ទៅលើជនណាម្នាក់ដែលច្បាប់បានកំណត់

៣. ប្រសិនបើ អប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមាត្រូវបន្ថយមកត្រឹម ៣ (បី) ខែ។

**ឧទាហរណ៍ ៖** បទគំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ទៅ ៥ (ប្រាំ) ឆ្នាំ យោងតាមមាត្រា ៣៦៣ និង៣៦៤ នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើជនល្មើសជាអនីតិជន ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ផ្អែកតាមមាត្រា ១៦៤ តម្រូវឲ្យតុលាការបន្ថយនូវអប្បបរមានៃមូលទោសទៅលើបទល្មើស ដែលត្រូវបានចោទប្រកាន់ មានន័យថា អប្បបរមានៃទោស ២ (ពីរ) ឆ្នាំ ត្រូវបន្ថយមកនៅត្រឹម ៣ (បី) ខែ ចំណែកឯអតិបរមានៃមូលទោសគឺ នៅដដែល។ ហេតុដូច្នេះនៅពេលដែលជនល្មើសជាអនីតិជន ទោសដែលត្រូវយកមកផ្តន្ទាទោសគឺ ៣ (បី) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ សម្រាប់បទគំហែងយក។

៤. ប្រសិនបើ អប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមាត្រូវបន្ថយមកត្រឹម ១ (មួយ) ថ្ងៃ។

**ឧទាហរណ៍៖** បទរំលោភលើលំនៅឋាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល យោងតាមមាត្រា ២៥៩ នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើជនល្មើសជាអនីតិជន ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ផ្អែកតាមមាត្រា ១៦៤ តម្រូវឲ្យតុលាការបន្ថយនូវអប្បបរមានៃមូលទោសទៅលើបទល្មើស ដែលត្រូវបានចោទប្រកាន់មានន័យថាអប្បបរមានៃទោស ១ (មួយ) ខែ ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ថ្ងៃ ចំណែកឯអតិបរមានៃមូលទោសគឺនៅដដែល។ ហេតុដូច្នេះនៅពេលដែលជនល្មើសជាអនីតិជន ទោសដែលត្រូវផ្តន្ទាទោសគឺ ១ (មួយ) ថ្ងៃ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់)រៀល ទៅ ២.០០០.០០០ (ពីរលាន)រៀល សម្រាប់បទរំលោភលើលំនៅឋាន[113]។

៥. អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។

**ឧទាហរណ៍៖** បទជេរប្រមាថ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល យោងតាមមាត្រា ៣០៧ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើជនល្មើសជាអនីតិជន ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ផ្អែកតាមមាត្រា ១៦៤ តម្រូវឲ្យតុលាការបន្ថយនូវអប្បបរមានៃទោសពិន័យជាប្រាក់ទៅលើបទល្មើស ដែលត្រូវបានចោទប្រកាន់។ មានន័យថា អប្បបរមានៃទោសពិន័យជាប្រាក់ ១០០.០០០ (មួយសែន) រៀល ត្រូវ

[113] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២០៣ ៖ កន្លែង ដែលជាទីតាំងនៃជីវភាពរស់នៅជាអចិន្ត្រៃយ៍របស់បុគ្គលម្នាក់ៗ ។

បន្ថយពាក់កណ្តាលគឺ ៥០.០០០ (ប្រាំម៉ឺន) រៀល ចំណែកឯអតិបរមានៃទោសពិន័យជាប្រាក់គឺនៅដដែល។ ហេតុដូច្នេះនៅពេលដែលជនល្មើសជាអនីតិជន ទោសដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់គឺពី ៥០.០០០ (ប្រាំម៉ឺន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល សម្រាប់បទល្មើសដេរប្រមាថជាសាធារណៈ។

ស្ថានសម្រាលទោស ត្រូវអនុវត្តទៅលើអនីតិជន[114]។

ការប្រកាសមូលទោស នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង តុលាការអាចប្រកាស[115] ៖

- ទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ជាមួយគ្នា
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ
- ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

### ៣. ១. ២. ការប្រកាសទោសបន្ថែម

ទោសបន្ថែម[116] គឺជាការប្រកាសទោសបន្ថែមលើមូលទោស ហើយបើកាលណាបទល្មើសមួយ ត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែនៅបទប្បញ្ញត្តិនៃមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ (ការជំនួសមូលទោស ដោយទោសបន្ថែម) នៃក្រមនេះ។

តុលាការអាចសម្រេចជំនួសមូលទោស[117] ដោយទោសបន្ថែមមួយ ឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម ៖

១. កាលណាជនជាប់ចោទ ទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២. កាលណាជនជាប់ចោទ ទទួលទោសដាក់ពន្ធនាគារ[118] ដែលមានអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ ។

[114] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១៦៤, កថាខណ្ឌទី ១
[115] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ៩៧
[116] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ៥០ ៖ អនុទោស ឬទោសបន្ទាប់បន្សំ
[117] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ១៩៥ ៖ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់
[118] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ៩៩ ៖ ទោសគុក ទោសដែលបំបាត់សេរីភាពមានកំណត់កាលដែលត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារ

កាលណាតុលាការ សម្រេចជំនួសមូលទោស ដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ។

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជនៈ

១. ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយ ដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

២. ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

៣. ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។

៤. ការរឹបអូសឧបភោគភណ្ឌ[119] សម្ភារៈ ឬចលនវត្ថុ នៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

៥. ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធ ឬគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

### ៣.១.៣. ការប្រកាសទោសជំនួស

ការប្រកាសទោសជំនួសរួមមាន ទោសការងារសហគមន៍ ឬការស្តីបន្ទោស ដែលត្រូវបានអនុវត្តជំនួសទោសដាក់ពន្ធនាគារ[120] ដែលមានដូចខាងក្រោម ៖

#### ៣.១.៣.១. ការប្រកាសទោសការងារសហគមន៍

កាលណាជនជាប់ចោទ ទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសការងារសហគមន៍[121]។ ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ ឆ្នាំ ប៉ុន្តែថិរវេលានៃការងារមិនអាចលើសពី ១០០ ម៉ោង។ ការងារសហគមន៍ ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈបណ្តុះបណ្តាល និងសម្របសម្រួលដល់ការបញ្ជូនខ្លួនទៅរស់ក្នុងសង្គមវិញ[122] ។

តុលាការអាចប្រកាសទោសការងារសហគមន៍ជំនួសឲ្យមូលទោសបាន ហើយក្នុងករណីនេះ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ។ ក៏ប៉ុន្តែទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមាន

[119] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២៥០ ៖ ឧបករណ៍ប្រើប្រាស់ប្រចាំជីវភាពធម្មតា របស់ ឬអីវ៉ាន់សម្រាប់ប្រើប្រាស់ជិតៗខ្លួន

[120] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ៥៨

[121] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ៧២, កថាខណ្ឌទី ១

[122] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១៦២; ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៦៥, ចំនុចទី ៥

វត្តមាននៅពេលសវនាការ[123] ហើយយល់ព្រមធ្វើការងារនេះ។ នៅមុនពេលដែលតុលាការប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា។

ចំពោះបែបបទនៃការអនុវត្តទោសការងារសហគមន៍ត្រូវ កំណត់ដោយអាជ្ញាធរ ដែលទទួលបន្ទុកក្នុងការបង្វែររួមមាន តំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍[124] ដែលផ្ទុយពីការអនុវត្តចំពោះនីតិជន ដែលមានតែព្រះរាជអាជ្ញាទេ ជាអ្នកកំណត់ពីការងារនោះ ហើយចង្អុលបង្ហាញប្រាប់ឈ្មោះនីតិបុគ្គលដែលត្រូវទទួលប្រយោជន៍ពីការងារនេះ និងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា[125]។

ការងារសហគមន៍ ឬរាល់វិធានការបង្វែរដែលទាក់ទងនឹងការងារ ត្រូវស្ថិតនៅក្រោម ឬត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារដែលកម្ពុជាបានទទួលស្គាល់[126]។

#### ៣.១.៣.២. ការប្រកាសទោសស្តីបន្ទោស

កាលណាជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើលក្ខខណ្ឌទាំងបីត្រូវបានបំពេញៈ

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាត ត្រូវបានជួលជួលរួចហើយ
- ជនជាប់ចោទ បានបង្ហាញការធានាក្នុងការចូលទៅរួមរស់ក្នុងសង្គមវិញ។

តុលាការ ក៏អាចប្រកាសការស្តីបន្ទោសជំនួសឲ្យមូលទោសបានផងដែរ។ តុលាការដែលបានប្រកាសការស្តីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ឡើយ[127] ។

### ៣.១.៤. ការប្រកាសទោសព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បង មានន័យថា ជាការព្យួរទោសដែលតុលាការអាចផ្តល់ទៅឲ្យទណ្ឌិតដែលត្រូវទទួលរងទោស ដាក់ពន្ធនាគារមានរយៈពេលពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ ដោយដាក់

[123] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២១៧ ៖ ការបើកកិច្ចជំនុំជម្រះ ដែលក្នុងឱកាសនេះចៅក្រមសួរដេញដោល និងស្តាប់ការចោទប្រកាន់របស់ក្រុមអយ្យការហើយវិនិច្ឆ័យសេចក្តី

[124] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៦១ និង ៦៥ ចំនុចទី ៥

[125] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១០៣

[126] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ៧៩; ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៦៥ កថាខណ្ឌទី ២

[127] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ៩៨, កថាខណ្ឌទី ២

ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង ដែលមិនអាចតិចជាង ១ (មួយ ) ឆ្នាំ នឹងមិនលើសពី ៣ (បី) ឆ្នាំ ហើយតុលាការជាអ្នកកំណត់រយៈពេលនៃការសាកល្បងនេះ[128]។

តុលាការ ដែលបានដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពកាតព្វកិច្ចដោយឡែកមួយ ឬច្រើន ទណ្ឌិតនោះ ត្រូវតែគោរពទៅតាមការកំណត់របស់តុលាការ ដែលវិធានការត្រួតពិនិត្យទាំងនោះ ដែលតម្រូវឲ្យទណ្ឌិតអនុវត្តដូចតទៅ[129] ៖

១. ទណ្ឌិត ត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ ។
២. ទណ្ឌិត ត្រូវតែមកទទួលនូវការពិនិត្យមើលរបស់បុគ្គល ដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។
៣. ទណ្ឌិត ត្រូវប្រគល់ឲ្យដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យនូវគ្រប់ឯកសារ សម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឲ្យរស់នៅក្នុងសង្គមវិញ។
៤. ទណ្ឌិត ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។
៥. ទណ្ឌិត ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន ។
៦. ទណ្ឌិត ត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស។

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តចំពោះអនីតិជន[130] ៖

១. ទទួលបង្ហាត់បង្រៀន ឬបណ្តុះបណ្តាលវិជ្ជាជីវៈ។
២. ស្ថិតនៅកន្លែងណាមួយជាកំណត់។
៣. ដាក់ខ្លួនឲ្យពេទ្យពិនិត្យ ឬព្យាបាល។
៤. ជួសជុលសព្យសនកម្ម ដែលបណ្តាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន។
៥. បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្តន្ទាទោស។

[128] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១១៧ និង ១១៨; សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ១៧
[129] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១១៩
[130] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១៦៥

៦. មិនត្រូវបង្ហាញមុខនៅកន្លែងខ្លះ។

៧. មិនត្រូវសេពគប់ទីកន្លែងលក់ភេសជ្ជៈស្រវឹង។

៨. មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះដែលមាន សហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះ។

៩. មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

នៅគ្រប់កាលៈទេសៈណាក៏ដោយ តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែក ដែលតម្រូវទៅលើទណ្ឌិតបាន[131]។ តុលាការ បានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ហើយនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត ។

ការព្យួរទោសសាកល្បង អាចត្រូវបានដកហូតដោយតុលាការ នៅក្នុងករណីដូចខាងក្រោមនេះ[132]៖

១. ប្រសិនបើនៅក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនបានគោរពតាមវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកទេ។

២. បើនៅក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាថ្មីទៀត។

តុលាការ អាចបង្គាប់ឲ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក។ នៅក្នុងករណីនេះ ទោសត្រូវយកមកអនុវត្តទាំងមូល ឬមួយផ្នែក ហើយតុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ផ្ទុយទៅវិញ ប្រសិនបើទណ្ឌិតបានគោរពទៅតាមការកំណត់របស់តុលាការបានយ៉ាងខ្ជាប់ខ្ជួន ហើយមិនបានប្រព្រឹត្តបទល្មើសថ្មីទៀតទេ ការផ្ដន្ទាទោសត្រូវចាត់ទុកជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលសាកល្បង[133] ការផ្ដន្ទាទោសមិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូត ដែលមានសេចក្ដីសម្រេចដកហូតទេ[134]។

[131] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១២១

[132] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១២២

[133] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១, លេខរាង ២១៨ ៖ សាកល្បង ៖ ការដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវលក្ខខណ្ឌដោយឡែកមួយ ឬច្រើនក្នុងរយៈពេលព្យួរទោសសាកល្បង។

[134] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១២៣

## ៣.២. ការអនុវត្តទោសក្នុងពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា

ក្រោយពីយុត្តាធិការជំនុំជម្រះ បានបញ្ចប់ការពិភាក្សាដេញដោល និងវិនិច្ឆ័យទៅលើអង្គហេតុ ដោយផ្អែកទៅលើភស្តុតាង សាក្សី ឬចម្លើយសារភាពរបស់អនីតិជន ហើយបានពិនិត្យទៅលើធាតុផ្សំនៃបទល្មើស និងបានប្រកាសថាមានពិរុទ្ធភាពចំពោះបទល្មើសនោះ ហើយក៏បានឈានទៅដល់ការប្រកាសទោសណាមួយ ដែលសមស្របទៅនឹងអំពើនៃការប្រព្រឹត្តបទល្មើសរបស់អនីតិជននោះ តុលាការ អាចជ្រើសរើសទោសមួយក្នុងចំណោមទោសជាច្រើន ដែលអាចអនុវត្តចំពោះអនីតិជន គឺការប្រកាសទោសដាក់ពន្ធនាគារ។ ច្បាប់បានកំណត់ពីលក្ខខណ្ឌមួយចំនួនក្នុងការដាក់អនីតិជនក្នុងពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា និងបានផ្ដល់នូវសិទ្ធិជាច្រើនក្នុងពេលដែលអនីតិជន កំពុងតែអនុវត្តទោសនោះ ដូចមានខាងក្រោម៖

### ៣.២.១. លក្ខខណ្ឌនៃការឃុំខ្លួន

អនីតិជនជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅកន្លែងពិសេស ដាច់ពីនីតិជន។ អនីតិជនត្រូវស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែងសម្រាប់អប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ របបឃុំឃាំង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[135]។ ចំពោះគោលបំណងនៃការឃុំខ្លួនអនីតិជនធ្វើឡើងគឺ ដើម្បីស្ដារនីតិសម្បទា ឬការបណ្ដុះបណ្ដាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្ដល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ[136]។

ផ្ទុយទៅនឹងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០ ដែលជាច្បាប់ទាក់ទងទៅនឹងការឃុំខ្លួនអនីតិជន ដែលតម្រូវឲ្យដាក់អនីតិជន ដែលបានប្រព្រឹត្តបទល្មើសនៅក្នុងពន្ធនាគារ ក៏ប៉ុន្តែច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ គឺជាច្បាប់ពិសេស ដែលមានអាទិភាពជាងច្បាប់ទូទៅ ដែលតម្រូវឲ្យយកច្បាប់ពិសេសមកអនុវត្ត នៅក្នុងករណីដែលច្បាប់ទូទៅផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ពិសេស។ ដោយយោងតាមច្បាប់នេះ អនីតិជនដែលបានប្រព្រឹត្តបទល្មើសតម្រូវឲ្យអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទាដូចខាងក្រោម[137] ៖

- អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន[138]

[135] ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១៦៦

[136] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៧៩

[137] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៨២

[138] ច្បាប់ស្ដីពីពន្ធនាគារ ឆ្នាំ ២០១១ , មាត្រា ២៦; ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៨២ ចំនុចទី ១

- នៅក្នុងអគារដាច់ដោយឡែកតាមភេទផ្សេងគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន។ អនីតិជនភេទស្រី ត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលភេទស្រីដូចគ្នា

- ដាក់នៅក្នុងអគារ ដាច់ដោយឡែក និងត្រូវដឹកជញ្ជូន តាមមធ្យោបាយដាច់ដោយឡែកសម្រាប់អនីតិជនដែលមានជម្ងឺឆ្លង។

ប្រសិនបើទណ្ឌិត ជាអនីតិជនឈានចូលអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលបាន និងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះ ត្រូវបានរក្សាទុកនៅក្នុងមណ្ឌលយុវនីតិសម្បទាបន្តរហូតដល់អាយុក្រោម ២៤ (ម្ភៃបួន) ឆ្នាំ។ ពេលទណ្ឌិតឈានចូលអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះ ត្រូវបានផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន។

បែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### ៣. ២. ២. សិទ្ធិរបស់អនីតិជនក្នុងអំឡុងពេលអនុវត្តទោស

អនីតិជនដែលជាប់ឃុំទាំងអស់ ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចតទៅ[139] ៖

- សិទ្ធិទទួលបានការសិក្សាអប់រំ[140]

- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្មរួមមាន ការដាក់ឲ្យនៅឯកា ការដាក់កំហិត ឬបដិសេធមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ

- សិទ្ធិ ទទួលបានវិធានការដាក់ពិន័យ ដែលស្របតាមសេចក្ដីថ្លៃថ្នូររបស់អនីតិជន

- សិទ្ធិ ទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុងអំពីសិទ្ធិ និងកាតព្វកិច្ច

- សិទ្ធិ ផ្ដល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ឬការដោះលែង ទៅអោយអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី

- សិទ្ធិ ទទួលបានការការពារ ការពិនិត្យសុខភាព និងព្យាបាលជម្ងឺ ឬរបួស និងផ្ដល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី

[139] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៨០

[140] ច្បាប់ស្ដីពីពន្ធនាគារ ឆ្នាំ ២០១១, មាត្រា ៦៧ កថាខណ្ឌទី ៣

- សិទ្ធិ ទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខលក្ខណៈឯកជន ពីសមាជិកគ្រួសារ ឬមិត្តភក្តិ[141]

- សិទ្ធិ ទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធិភាព និងការរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន

- សិទ្ធិផ្សេងទៀត ដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន។

លើសពីនេះទៅទៀត អនីតិជនដែលកំពុងជាប់ឃុំ ក៏ត្រូវបានទទួលនូវសេវា ដែលផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកនៅមណ្ឌលយុវនីតិសម្បទាទាំងអស់ដូចខាងក្រោម[142] ៖

- ការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួន ដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន

- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល

- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាកពីការងារ

- សុខភាពផ្លូវកាយ និងផ្លូវចិត្តសមស្រប

- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ ដោយត្រូវចុះក្នុងសំណុំរឿងរបស់អនីតិជនជាប់ឃុំនៃព័ត៌មានអំពីស្នាមរបួស ជម្ងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត[143]

- សេវាផ្សេងទៀត ដែលលើកស្ទួយសុខភាព និងមោទនភាពចំពោះខ្លួនឯង និងលើកទឹកចិត្តឲ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឲ្យមានអាកប្បកិរិយា និងជំនាញដែលនឹងជួយអនីតិជនក្នុងការអភិវឌ្ឍសក្តានុពលរបស់ខ្លួន ក្លាយទៅជាពលរដ្ឋល្អនៅក្នុងសង្គម និងអាចជួយឲ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញ បន្ទាប់ពីបានដោះលែង។

## ៣. ៣. ការផ្តល់ និងការស្តារនីតិសម្បទា

បន្ទាប់ពីអនីតិជន បានអនុវត្តទោសរួចរាល់ចប់សព្វគ្រប់ហើយនោះ ឬពេលអាជ្ញាយុកាលនៃទោសត្រូវបានផុត ច្បាប់បានតម្រូវឲ្យមានលក្ខខណ្ឌនៃការផ្តល់ និងការស្តារនីតិសម្បទាឡើងវិញចំពោះអនីតិជន ដែលបានប្រព្រឹត្តបទល្មើសដែលមានដូចតទៅ ៖

141 ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ ២០១១, មាត្រា ៥៥

142 ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៨១

143 ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ ២០១១ , មាត្រា ២៤, វាក្យខណ្ឌទី ២

### ៣. ៣. ១. ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ការផ្តល់ឲ្យមាននីតិសម្បទាឡើងវិញតាមផ្លូវតុលាការ អាចត្រូវបានផ្តល់ឲ្យ ឬមិនព្រមផ្តល់ឲ្យ ដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានការប្រកាសផ្តន្ទាទោសដោយតុលាការនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍នេះ។

ពាក្យសុំអាចធ្វើឡើងដោយ[144] ៖

- ទណ្ឌិតជានីតិជន ដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន
- អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន

ពាក្យសុំឲ្យមាននីតិសម្បទាឡើងវិញ អាចនឹងត្រូវដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ៖

- ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម
- ១ (មួយ) ខែ ចំពោះបទលហុ

រយៈពេលនេះ ត្រូវចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬទោសត្រូវបានផុតអាជ្ញាយុកាល[145]។

អនីតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវធ្វើពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញជូនទៅព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដី។ ហើយត្រូវចង្អុលបង្ហាញប្រភេទនៃទណ្ឌកម្មដែលខ្លួនបានរង និងបញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅ តាំងពីពេលដែលខ្លួនត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញ។ បន្ទាប់ពីបានទទួលពាក្យសុំហើយនោះ ព្រះរាជអាជ្ញាចាត់ធ្វើការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែងដែលទណ្ឌិតធ្លាប់បានរស់នៅ តាំងពីពេលដែលខ្លួនត្រូវបានដោះលែង។

ព្រះរាជអាជ្ញា សុំឲ្យគេប្រគល់មកខ្លួននូវ៖

- លិខិតចម្លង នៃសេចក្តីសម្រេចផ្តន្ទាទោស
- លិខិតជូនដំណឹង អំពីកាលបរិច្ឆេទនៃការអនុវត្តទោសរួចហើយ
- ព្រឹត្តបត្រលេខ ១ នៃបញ្ជីថ្កោលទោស។

[144] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៧៤

[145] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៧៤, កថាខណ្ឌទី ២; ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០, មាត្រា ១៤៤, ១៤៥ និង មាត្រា ១៤២ ៖ នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ ។

ព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿង ដោយមានយោបល់ដែលមានសំអាងហេតុរបស់ខ្លួនភ្ជាប់ជាមួយទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

បន្ទាប់ពីអគ្គព្រះរាជអាជ្ញា បានទទួលការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញាហើយនោះ អគ្គព្រះរាជអាជ្ញា ប្ដឹងទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ហើយជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់អ្នកប្ដឹង និងមេធាវី។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងពីអគ្គព្រះរាជអាជ្ញា តុលាការត្រូវសម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់ទណ្ឌិត មេធាវី និងអគ្គព្រះរាជអាជ្ញា។

នៅក្នុងករណីដែលតុលាការបដិសេធពាក្យសុំ សាមីជនមិនអាចជូនពាក្យសុំថ្មីទៀតទេ មុនផុតរយៈពេល ២ (ពីរ) ឆ្នាំ បានឡើយ។ ប៉ុន្តែប្រសិនបើពាក្យសុំលើកទី ១ ត្រូវបានតុលាការបដិសេធមកពីមិនគោរពរយៈពេលដែលមានក្នុង មាត្រា ៧៤ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ពាក្យសុំថ្មី អាចធ្វើបានចាប់ពីផុតរយៈពេលនោះ។

### ៣. ៣. ២. ការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

នីតិសម្បទា ត្រូវមានឡើងវិញ ដោយពេញលក្ខណៈច្បាប់នៅពេលផុតរយៈពេល[146] ៖

- ៣ (បី) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

ដូចក្នុងករណី ៖ អនីតិជន បានប្រព្រឹត្តបទឃាតកម្ម នៅថ្ងៃ ១ ខែ មករា ឆ្នាំ ២០១៧ ហើយត្រូវបានតុលាការប្រកាសឲ្យអនុវត្តទោស ២ឆ្នាំ ៦ខែ នៅថ្ងៃ ទី១ ខែមីនា ឆ្នាំ២០១៧ ហើយអនីតិជនបានអនុវត្តទោសចប់សព្វគ្រប់ នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៩។ ដូច្នេះ ការទទួលបាននីតិសម្បទាឡើងដោយតាមលក្ខណៈច្បាប់ មិនតម្រូវឲ្យអនីតិជននោះ ឬអ្នកតំណាងដែលច្បាប់កំណត់ដាក់ពាក្យសុំទៅសភាព្រហ្មទណ្ឌនោះទេ ដោយគ្រាន់តែទុកឲ្យផុតរយៈពេល ៣ ឆ្នាំ, ១ ឆ្នាំ, ៣ ខែ ចំពោះបទល្មើសដែលអនីតិជនបានប្រព្រឹត្ត គិតចាប់ពីថ្ងៃអនុវត្តទោសរួច ឬពេលទោសផុតអាជ្ញាយុកាល។

- ១ (មួយ) ឆ្នាំ ចំពោះបទមជ្ឈិម
- ៣ (បី) ខែ ចំពោះបទលហុ

រយៈពេលនេះ ចាប់ផ្ដើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល។

### ៣. ៣. ៣. សមត្ថកិច្ចគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា

មណ្ឌលយុវនីតិសម្បទាត្រូវបង្កើតនៅតាម រាជធានី ខេត្ត សម្រាប់ធ្វើការគ្រប់គ្រងអនីតិជន។ មណ្ឌលយុវនីតិសម្បទានេះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច

[146] ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៧៥

ហើយការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទាត្រូវកំណត់ដោយអនុក្រឹត្យ។ ហើយចំពោះការបែងចែកការគ្រប់គ្រង អនីតិជន ក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបែងចែកជា ៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នា[147] ៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជន បណ្តោះអាសន្ន
- ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជន ដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា[148]
- ផ្នែកសម្រាប់តៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម។

គ្រប់មណ្ឌលយុវនីតិសម្បទា ត្រូវមានបញ្ជី និងនីតិវិធីដោយឡែក សម្រាប់ការចុះឈ្មោះ និងគ្រប់គ្រងអនីតិជនព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាសុវត្ថិភាព។ បន្ថែមពីនេះ បញ្ជីនិងនីតិវិធីដោយឡែកនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

បែបបទនៃការគ្រប់គ្រងអនីតិជន ក្នុងមណ្ឌលយុវនីតិសម្បទាដែលជាប់ឃុំ និងនីតិវិធីនៃការផ្ទេរ ឬការប្រគល់ និងការទទួលអនីតិជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[149]។

គួរកត់សម្គាល់ថា ក្នុងករណីមិនទាន់មានមណ្ឌលយុវនីតិសម្បទា វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជន ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលយុវនីតិសម្បទា[150]។

#### ៣. ៣. ៣. ១. ភ្នាក់ងារក្នុងមណ្ឌលយុវនីតិសម្បទា

ភ្នាក់ងារ ដែលធ្វើការជាមួយអនីតិជន នៅក្នុងមណ្ឌលយុវនីតិសម្បទា មន្ត្រីយុវនីតិសម្បទាភ្នាក់ងារសង្គមកិច្ចអ្នកជំនាញផ្នែកអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អ្នកពិគ្រោះយោបល់ និងបំណិនជីវិត និងអ្នកចិត្តសាស្ត្រ ឬគ្រូពេទ្យព្យាបាលផ្លូវចិត្ត ត្រូវតែទទួលបាននូវការបណ្តុះបណ្តាលត្រឹមត្រូវអំពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ និងការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

---

147 ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៧៧

148 ប្រកាសស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការទទួលគ្រប់គ្រង និងស្តារនីតិសម្បទា កុមារ យុវកុមារ នៅយុវនីតិសម្បទាចោមចៅ ឆ្នាំ ២០០៦, ប្រការ ៥ ៖ ការស្តារនីតិសម្បទា គឺជាដំណើរការអប់រំ កែប្រែឲ្យល្អប្រសើរឡើងវិញនូវស្មារតី សតិអារម្មណ៍ ចិត្តគំនិត អាកប្បកិរិយា ផ្តល់ការប្រឹក្សា ព្រមទាំងបណ្តុះបណ្តាលបំណិនជីវិត និងមុខជំនាញវិជ្ជាជីវៈរយៈពេលខ្លី មុននឹងធ្វើសមាហរណកម្មទៅគ្រួសារ ឬសហគមន៍វិញ ។

149 ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៨៨ កថាខណ្ឌទី ២

150 ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៨៨ កថាខណ្ឌទី ១

មន្ត្រី ឬបុគ្គលិក មណ្ឌលយុវនីតិសម្បទា មិនត្រូវប្រើ ឬបញ្ជាជនដែលកំពុងជាប់ឃុំឲ្យដាក់ពិន័យទៅលើអនីតិជន ឬធ្វើកិច្ចការជំនួសខ្លួនឡើយ។

#### ៣.៣.៣.២. ការធ្វើអធិការកិច្ចមណ្ឌលយុវនីតិសម្បទា

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ច ជាប្រចាំលើមណ្ឌលយុវនីតិសម្បទា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចខ្លួន និងធានាថាលក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួន ត្រូវបានអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ[151]។

យន្តការបង្ការថ្នាក់ជាតិ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់មានសិទ្ធិធ្វើទស្សនកិច្ចមណ្ឌលយុវនីតិសម្បទានានា បានគ្រប់ពេលវេលា។

## ៣.៤. ការដោះលែងដោយមានលក្ខខណ្ឌ

ដើម្បីអាចឲ្យមានការដោះលែងដោយមានលក្ខខណ្ឌអាចយកមកអនុវត្តបាននោះ ច្បាប់បានកំណត់អំពីលក្ខខណ្ឌ និងអាជ្ញាធរដែលមានសមត្ថកិច្ច ដូចតទៅនេះ៖

### ៣.៤.១. លក្ខខណ្ឌទាក់ទងនឹងបុគ្គល

បុគ្គល ដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជន ដោយមានលក្ខខណ្ឌរួមមាន ៖

- ទណ្ឌិត ដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
- អ្នកតំណាងដែលច្បាប់បានកំណត់
- ប្រធានមណ្ឌលយុវនីតិសម្បទា
- ភ្នាក់ងារសង្គមកិច្ច ដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជននោះ
- បេសសកម្មការទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស។

### ៣.៤.២. លក្ខខណ្ឌទាក់ទងនឹងគំនិត មារយាទ និងការទទួលរងទោស

គ្រប់ទណ្ឌិត ដែលត្រូវទទួលរងទោសដាក់ពន្ធនាគារមួយ ឬច្រើន អាចត្រូវដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមាននីតិសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន។ លើសពីនេះ ការដោះលែងដែលមានលក្ខខណ្ឌអាចផ្តល់ទៅឲ្យទណ្ឌិតជាអនីតិជន ដែលបានទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា ៖

[151] ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ ២០១១ , មាត្រា ៥៤ កថាខណ្ឌទី ១; ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦, មាត្រា ៨៥

- ចំនួនមួយភាគបីនៃទោស ប្រសិនបើទោស តិចជាង ឬស្មើ ១ ឆ្នាំ
- ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត។

### ៣.៤.៣. អាជ្ញាធរមានសមត្ថកិច្ច ដែលផ្តល់ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ ត្រូវផ្តល់ដោយប្រធានតុលាការជាន់ដំបូងនៃទីកន្លែងឃុំខ្លួន។ ក្រោយពីបានទទួលពាក្យសុំដោះលែងដោយមានលក្ខខណ្ឌ ប្រធានតុលាការជាន់ដំបូងត្រូវបញ្ជូនទៅគណៈកម្មការជាតិនូវ ៖

- ពាក្យសុំ
- សាលក្រម ឬសាលដីកាផ្តន្ទាទោស
- ជាយថាហេតុ សាលក្រម និងសាលដីកាទាំងឡាយ ប្រសិនបើទណ្ឌិតទទួលទោសច្រើន
- ព្រឹត្តប័ត្រលេខ ១ នៃបញ្ជីថ្កោលទោស
- យោបល់ព្រះរាជអាជ្ញា
- គ្រប់លិខិតទាំងអស់ដែលមានប្រយោជន៍។

គណៈកម្មការជាតិ បញ្ចេញយោបល់របស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត។ យោបល់នេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវផ្ញើជូនទៅប្រធានតុលាការជាន់ដំបូងភ្លាម។

សមាជិកគណៈកម្មការជាតិរួមមាន ៖

- សមាជិក ២ រូប ចាត់តាំងដោយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ១ រូបជាប្រធាន
- ប្រធានពន្ធនាគារ ឬតំណាងជាសមាជិក។

ប្រធានតុលាការនេះ ត្រូវសម្រេចក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌។ សេចក្តីសម្រេចដោះលែងដោយមានលក្ខខណ្ឌ ត្រូវសម្រេចទៅតាមដីកាដោយមានសំអាងហេតុ ដោយមិនត្រូវឲ្យជាប់ជំពាក់នឹងយោបល់គណៈកម្មការនេះទេ។ រាល់សេចក្តីសម្រេចរបស់ប្រធានតុលាការនេះ អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បាន ក្នុងរយៈពេល ៥ ថ្ងៃ ដោយបណ្តឹងតវ៉ានេះអាចធ្វើបានដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាសាមីតែប៉ុណ្ណោះ។ សេចក្តីសម្រេចនេះ មិនមានអានុភាពទេនៅក្នុងរយៈពេល ៥ ថ្ងៃ ឬរហូតដល់មានដីកាដែលមានសំអាងហេតុរបស់ប្រធានសាលាឧទ្ធរណ៍ និងមិនអាចតវ៉ាបានឡើយ។

កាលណាប្រធានតុលាការជាន់ដំបូង បង្គាប់ឲ្យដោះលែងដោយមានលក្ខខណ្ឌ ត្រូវកំណត់ពីបែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងទណ្ឌិត ដោយកំណត់រយៈសាកល្បង ដែលមិន

អាចលើសពីថិរវេលានៃទោស ដែលនៅសល់មិនទាន់បានទទួលរងឡើយ។ ផ្ទុយទៅវិញ ប្រសិនបើនៅក្នុងករណីមានការផ្តន្ទាទោសសារជាថ្មី ឬការមិនគោរពលក្ខខណ្ឌ ដែលបានកំណត់ដោយដីកាទេ ប្រធានតុលាការជាន់ដំបូង អាចដកហូតសេចក្តីសម្រេចរបស់ខ្លួនមកវិញបាន។ ការដកហូតនោះនាំឲ្យទណ្ឌិត ត្រូវទទួលទោសដែលនៅសល់។ រយៈពេលសល់ ត្រូវគិតចាប់ពីពេលដែលទណ្ឌិតបានទទួលសេចក្តីសម្រេចឲ្យដោះលែងដោយមានលក្ខខណ្ឌ។ ប្រសិនបើទណ្ឌិត ត្រូវបានចាប់ខ្លួននៅក្នុងករណីបន្ទាន់ដោយព្រះរាជអាជ្ញា រយៈពេលឃុំខ្លួនរហូតមកទល់នឹងសេចក្តីសម្រេចដកហូតការដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវយកមកគិតក្នុងថិរវេលានៃទោសដែលនៅសេសសល់។

ប្រសិនបើទណ្ឌិត បានគោរពទៅតាមដីកា ឬមិនបានផ្តន្ទាទោស ចំពោះបទល្មើសថ្មីទេ ហើយមិនត្រូវបានដកហូត សេចក្តីសម្រេចក្នុងរយៈពេលសាកល្បងទេ លុះផុតរយៈពេលកំណត់នោះ ការដោះលែងនឹងក្លាយទៅជាស្ថាពរ។ នៅក្នុងករណីនេះ ទោសត្រូវចាត់ទុកថាបានទទួលតាំងពីថ្ងៃដោះលែងដោយមានលក្ខខណ្ឌមកម្ល៉េះ។ ម្យ៉ាងទៀត ចំពោះបែបបទនៃការឃ្លាំមើល តាមដាន ត្រួតពិនិត្យ និងការបញ្ជូនទៅក្នុងសង្គមវិញ នៃទណ្ឌិតដែលដោះលែងដោយមានលក្ខខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ហើយអាចប្រគល់ទៅឲ្យស្ថាប័នសាធារណៈ ឬឯកជន នូវការយកចិត្តទុកដាក់ធានារ៉ាប់រងលើការបញ្ចូលទណ្ឌិតនៅក្នុងសង្គមវិញ ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវយ៉ាងល្អិតល្អន់រួចមកហើយ ចំណុចសំខាន់ៗជាច្រើន ដែលទាក់ទងជាមួយអនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ ត្រូវបានស្រាយបំភ្លឺកាន់តែច្បាស់។ នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ច្បាប់តម្រូវឲ្យអាជ្ញាធរមានសមត្ថកិច្ច ត្រូវតែអនុវត្តយ៉ាងដាច់ខាតទៅតាមនីតិវិធីទាំងឡាយ និងត្រូវគោរពតាមឲ្យបានហ្មត់ចត់ ក្នុងគោលបំណងដើម្បីធ្វើការពិនិត្យ ស្រាវជ្រាវឲ្យឃើញពីនត្ថិភាព ឬអត្ថិភាព ឬការកើតមានឡើងនូវបទល្មើសដែលប្រព្រឹត្តឡើងដោយអនីតិជន។ ក៏ប៉ុន្តែប្រសិនបើអាជ្ញាធរមានសមត្ថកិច្ច មិនបានអនុវត្តទៅតាមនីតិវិធីទាំងនោះឲ្យបានត្រឹមត្រូវនោះទេ ជាហេតុដែលនាំឲ្យមានមោឃភាពនៃនីតិវិធីទាំងនោះកើតឡើង។ ជាងនេះទៅទៀត ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានផ្តល់អាទិភាព និងការពារអនីតិជនយ៉ាងខ្លាំងក្លាបំផុតដែលក្នុងនោះរួមមានជាអាទិ៍ សិទ្ធិជាមូលដ្ឋានក្នុងកិច្ចនៃនីតិវិធី នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសតាំងពីដំណាក់កាលនគរបាលយុត្តិធម៌រហូតដល់ដំណាក់កាលជំនុំជម្រះ ដែលមានដូចជា សិទ្ធិមានមេធាវីក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់ខ្លួន និងការសន្មត់ជាមុនថាគ្មានទោស ដរាបណាមិនទាន់មានការប្រកាសទោសដោយតុលាការនោះទេ។ បន្ថែមពីនេះទៀត បើទោះបីជាអនីតិជនពិតជាបានប្រព្រឹត្តបទល្មើសពិតមែនក៏ដោយ តែច្បាប់បានផ្តល់នូវសិទ្ធិអំណាចដល់អនីតិជននោះយ៉ាងធំទូលាយ ដូចជាយន្តការនៃការបង្វែរអនីតិជនចេញពីនីតិវិធីរបស់តុលាការព្រហ្មទណ្ឌ ដោយការប្រគល់អនីតិជនទៅអ្នកមានអំណាចមេបា ឬអ្នកដែលមាននីតិសម្បទាក្នុងការគ្រប់គ្រងអនីតិជន នៅក្នុងករណីអនីតិជននោះមិនទាន់គ្រប់អាយុដើម្បីទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។ លើសពីនេះទៅទៀត យន្តការនៃការបង្វែរនេះបាននូវផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់អនីតិជនដូចជា បានធ្វើឲ្យអនីតិជននោះបានយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះនៃបទល្មើស ធ្វើការកែប្រែកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអ្វីដែលសំខាន់នោះគឺមិនមានការធ្វើការដកហូតនូវសិទ្ធិសេរីភាព ឬឃុំឃាំងអនីតិជនក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ។

ពិសេសជាងនេះទៅទៀត ប្រសិនបើអនីតិជននោះ បានដល់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌហើយនោះ មានយន្តការផ្សេងទៀតដូចជា ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការដោះលែងឲ្យនៅក្រៅឃុំដែលនីតិវិធីទាំងនេះបានផ្តល់សិទ្ធិដល់អនីតិជនយ៉ាងខ្លាំង។ មានន័យថាទោះបីជាបានប្រព្រឹត្តបទល្មើសមែនក៏ដោយ ក៏ខ្លួនមិនត្រូវបានដកហូតនូវសិទ្ធិសេរីភាពនោះទេ ហើយខ្លួនអាចប្រើប្រាស់នូវសិទ្ធិដែលខ្លួនធ្លាប់មានពីមុនបាន ប៉ុន្តែអាចមានករណីខ្លះមានសិទ្ធិមួយចំនួនមិនអាចត្រូវបានអនុញ្ញាតឲ្យប្រើផងដែរ នៅពេលដែលមានការបង្គាប់បញ្ជាពីអាជ្ញាធរមាន

សមត្ថកិច្ច ក្នុងគោលបំណងដើម្បីការពារនូវផលប្រយោជន៍របស់អនីតិជន ឬបង្ការកុំឲ្យមានបទល្មើសថ្មីកើតមានឡើងទៀត និងជាពិសេសនោះគឺការពារផលប្រយោជន៍សង្គមទាំងមូល។ ដោយសារតែមូលហេតុទាំងអស់នេះហើយ ប្រសិនបើអនីតិជនមិនបានអនុវត្តតាម ឬប្រតិបត្តិតាមឲ្យបានត្រឹមត្រូវទៅតាមការបង្គាប់បញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ចនោះទេ មានទណ្ឌកម្មផ្សេងទៀតៗនឹងត្រូវយកមកអនុវត្តចំពោះខ្លួនដូចជា ការយកមកឃុំខ្លួនបណ្តោះអាសន្ន ជាដើម។

ចំពោះការអនុវត្តទោសរបស់អនីតិជន មានលក្ខណៈពិសេសខុសពីនីតិជនផងដែរ នៅពេលដែលតុលាការប្រកាសទោសឲ្យជាប់ពន្ធនាគារ ទោសរបស់អនីតិជនស្ថិតនៅក្រោមអប្បបរមាដែលទាបបំផុតខុសពីនីតិជន។ លើសពីនេះទៅទៀត អនីតិជនមិនត្រូវបានដាក់នៅក្នុងពន្ធនាគារនោះទេ ដែលផ្ទុយពីច្បាប់ស្តីពីពន្ធនាគារ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ មានន័យថា រាល់បុគ្គលគ្រប់រូបៗដែលមានសាលក្រម ឬសាលដីកា ដែលត្រូវបានតុលាការធ្វើការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារជាស្ថាពរ នឹងត្រូវយកមកអនុវត្តទោសនៅក្នុងពន្ធនាគារទាំងអស់។ ប៉ុន្តែផ្ទុយទៅវិញ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ យកអនីតិជនដែលបានប្រព្រឹត្តបទល្មើស យកមកធ្វើការរក្សាទុកនៅក្នុងមណ្ឌលយុវនីតិសម្បទាដោយត្រូវដាក់អនីតិជននោះដាច់ដោយឡែកពីនីតិជន ហើយនៅក្នុងអគារដាច់ដោយឡែកទៅតាម ភេទ ប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន។

# អនុសាសន៍

បើទោះបីជាអនីតិជន ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានតុលាការធ្វើការផ្តន្ទាទោសតាមរយៈការដាក់ក្នុងពន្ធនាគារ ឬក្នុងមណ្ឌលយុវនីតិសម្បទា ឬមានទណ្ឌកម្មផ្សេងទៀត ត្រូវបានច្បាប់ជាតិ ក៏ដូចជាច្បាប់អន្តរជាតិ បានផ្តល់ឲ្យនូវសិទ្ធិឲ្យយ៉ាងច្រើនសន្ធឹកសន្ធាប់ក៏ពិតមែន (ដូចជាក្រមព្រហ្មទណ្ឌ ២០១០, ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧, អនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់ផ្សេងទៀតៗ ជាពិសេសនោះគឺ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលជាច្បាប់ពិសេសដែលអនុវត្តចំពោះតែអនីតិជនដែលបានប្រព្រឹត្តអំពើណាមួយដែលជាបទល្មើសតែប៉ុណ្ណោះ)។ ប៉ុន្តែផ្ទុយទៅវិញភាពខ្វះចន្លោះមួយចំនួននៅតែមានផងដែរ។ បើទោះបីជា អនីតិជនជាប់សង្ស័យថាបាន ឬមិនបានប្រព្រឹត្តអំពើល្មើសមែន ច្បាប់ស្តីពីយុត្តិធម៌អនីតិជន តម្រូវឲ្យស្ថាប័នមានសមត្ថកិច្ច ត្រូវគោរពតាមនីតិវិធីទាំងឡាយដែលបានចែង និងអនុវត្តតាមឲ្យបានហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់លាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ដែលប្រព្រឹត្តដោយអនីតិជន។ ដោយហេតុថា អំពើទាំងនោះអាចនាំឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ កិត្តិយស សេចក្តីថ្លៃថ្នូរ ខាតបង់ពេលវេលា និងការសិក្សា។ បន្ថែមពីលើនេះទៀត ដោយគោរពទៅតាមច្បាប់កំពូលគឺ រដ្ឋធម្មនុញ្ញដែលបានកំណត់ទុកជាមុននូវគោលការណ៍មួយដ៏សំខាន់ គឺគោលការណ៍សច្ចធារណ៍នៃនិរទោស ឬគោលការណ៍សន្មត់ជាមុនថាគ្មានទោស ដរាបណាមិនទាន់មានការប្រកាសទោសដោយតុលាការនោះទេ។

ការបង្ក្រាបបទល្មើស ឬបង្ការកុំឲ្យមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជននោះ រដ្ឋគួរគប្បីមានវិធានការណ៍ឲ្យបានច្បាស់លាស់ និងយ៉ាងជាក់លាក់បំផុត ដែលតម្រូវឲ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធមួយចំនួនដែលរួមមាន រាជរដ្ឋាភិបាល ស្ថាប័នមានសមត្ថកិច្ច តុលាការ និងប្រជាពលរដ្ឋដោយផ្ទាល់តែម្តង។ ជាដំបូងរាជរដ្ឋាភិបាល ដែលជាស្ថាប័នមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងដឹកនាំប្រទេសជាតិ ដែលមានក្រសួង ឬស្ថាប័នផ្សេងៗទៀតជាសេនាធិការត្រូវផ្សព្វផ្សាយ និងអប់រំអំពីសិទ្ធិរបស់កុមារក្នុងប្រព័ន្ធអប់រំ ដោយហេតុថានៅពេលដែលអនីតិជនទាំងអស់បានយល់ពីសិទ្ធិរបស់ខ្លួន ថាតើអាចប្រើប្រាស់សិទ្ធិនោះបានកម្រិតណានោះ អំពើល្មើសនឹងមិនកើតមានឡើងនោះទេ។ មានន័យថា បុគ្គលទាំងនោះនឹងមានភាពខ្លាចរអារនូវទណ្ឌកម្មដែលពួកគេអាចនឹងទទួលនៅពេលដែលគេប្រើប្រាស់សិទ្ធិនោះហួសដែនកំណត់។ បន្ថែមពីនេះទៀត ត្រូវមានការអប់រំអំពីបញ្ហាផ្លូវច្បាប់អោយបានច្រើន ដែលជាហេតុនាំអោយប្រជាជនបានយល់ដឹងពីច្បាប់ និងអាចទប់ស្កាត់មិនអោយមានការកើនឡើងនៃចំនួនបទល្មើស។

គួរកត់សម្គាល់ថា នៅក្នុងសង្គមជាក់ស្តែង មិនថាអនីតិជនបានប្រព្រឹត្តអំពើ ឬមិនបានប្រព្រឹត្តអំពើល្មើសនោះទេ សារព័ត៌មាននៅក្នុងស្រុកជាច្រើនមានដូចជា ការសែត ទស្សនាវដ្តី ទូរទស្សន៍ និងបណ្តាញសង្គមហ្វេសប៊ុកមួយចំនួន តែងតែផ្សព្វផ្សាយពីអត្តសញ្ញាណរបស់អនីតិជននោះ ដែលជាហេតុនាំឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់ កិត្តិយស សេចក្តីថ្លៃថ្នូររបស់គ្រួសារ និងឧត្តមប្រយោជន៍របស់អនីតិជនផ្ទាល់តែម្តង។ ដូច្នេះ ក្រសួងដែលពាក់ព័ន្ធ ត្រូវមានវិធានការណ៍ឲ្យបានច្បាស់លាស់ដើម្បីចាត់វិធានការណ៍ធ្វើយ៉ាងណាកុំឲ្យមានការបង្ហាញពីអត្តសញ្ញាណឬការសង្ងាត់របស់អនីតិជនជាសាធារណៈ។ លើសពីនេះទៅទៀត ត្រូវធ្វើការផ្សព្វផ្សាយអំពីបញ្ហាផ្លូវច្បាប់ជូនដល់ពលរដ្ឋនៅក្នុងសង្គម ជាពិសេសអនីតិជនដែលជាទំពាំងស្នងឬស្សី ជាអ្នកដឹកនាំសង្គមបន្ត ឬជាអ្នកអភិវឌ្ឍន៍សង្គមបន្តទៀត។ រាជរដ្ឋាភិបាល គួរតែបង្កើតវេទិកា ឬសិក្ខាថ្នាក់ជាតិ ឬអន្តរជាតិ ដែលមានលក្ខណៈណែនាំ អប់រំផ្នែកច្បាប់ និងតម្រូវឲ្យមានការចូលរួមពីអនីតិជន ដោយមានការពិភាក្សាដេញដោលអំពីច្បាប់ ហើយគួរជ្រើសរើសភាសាក្នុងកម្រិតមួយដែលអាចឲ្យអនីតិជនស្តាប់យល់។

យ៉ាងណាកត្តាគ្រួសារ ក៏ជាចំណែកមួយក្នុងការទប់ស្កាត់អនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសផងដែរ មានន័យថានៅពេលដែលគ្រួសារមិនដែលបានបង្ហាត់បង្រៀនកូន និងពន្យល់បន្ថែមពីបញ្ហាផ្លូវច្បាប់ចំពោះកូន ថែមទាំងតែងតែមានទំនាស់នៅក្នុងគ្រួសារច្រើននោះ ជាហេតុនាំអោយកូនយកគំរូតាម។ ដូច្នេះសមាជិកនៅក្នុងគ្រួសារ ត្រូវតែមានភាពស្និតស្នាលចំពោះកូន ហើយពួកគាត់ត្រូវតែបង្ហាត់បង្រៀនអោយកូនធ្វើជា កូនល្អ សិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គម និងត្រូវធ្វើការពន្យល់បន្ថែមពីបញ្ហាផ្លូវច្បាប់ចំពោះកូនរបស់ខ្លួនផងដែរ ថាតើអំពើនេះ ឬអំពើនោះត្រូវបានច្បាប់ហាមឃាត់ ហើយបើសិនបានធ្វើខុសនោះនឹងត្រូវមានទណ្ឌកម្មយកមកអនុវត្តចំពោះខ្លួន។

ចំនុចសំខាន់ជាងគេនេះគឺ ស្ថាប័នតុលាការ ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការកំណត់ថាអំពើណាមួយជាបទល្មើស ជាស្ថាប័ន ដែលមានសិទ្ធិអំណាចក្នុងការសម្រេចសេចក្តីថាបុគ្គលណាមួយមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាព តាមនីតិវិធីទាំងឡាយដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ និងក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០ រួមទាំងច្បាប់ដោយឡែកផ្សេងទៀត ជាពិសេសច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ បើទោះបីជា ច្បាប់ស្តីពីយុត្តិធម៌អនីតិជនតម្រូវឲ្យស្ថាប័នដែលទទួលបន្ទុកចាត់ការរឿងក្តីចំពោះអនីតិជន ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់នេះក៏ពិតមែន តែដោយសារតែច្បាប់នេះទើបតែត្រូវបានបង្កើតឡើង ហើយការអនុវត្តក៏មិនទាន់បានធ្វើឲ្យបានពេញលេញ ដែលជាហេតុនាំឲ្យច្បាប់នេះបែរជាគ្មានប្រសិទ្ធិភាពទៅវិញ។ លើសពីនេះ

ទៀត ស្ថាប័នដែលត្រូវទទួលបន្ទុកក្នុងការស្តារនីតិសម្បទាក៏មិនទាន់ត្រូវបានបង្កើតឡើងនៅឡើយផងដែរ ។ ដូច្នេះ នៅពេលដែលតុលាការបានសម្រេចឲ្យអនីតិជនទទួលទោស គឺត្រូវយកទៅធ្វើការស្តារនីតិសម្បទានៅក្នុងពន្ធនាគារ គឺមិនមែនធ្វើនៅក្នុងមណ្ឌលយុវនីតិសម្បទា ដែលបានគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទានោះទេ ។

គួរគត់សម្គាល់ថានៅក្នុងការអនុវត្តជាក់ស្តែង នៅក្នុងស្ថាប័នដែលទទួលបន្ទុកចាត់ការរឿងក្តីអនីតិជននេះ ក៏ឃើញមាននូវចំនុចគួរគប្បីធ្វើការកែតម្រូវមួយចំនួន ដូចជា ការជំនុំជម្រះអនីតិជនជាសាធារណៈ, រាល់ការបង្វែរមិនទាន់អាចអនុវត្តឲ្យបានពេញលេញនៅឡើយ, ករណីខ្លះមិនមានការបំបែកសំណុំរឿងនៅឡើយនោះទេ គឺធ្វើការជំនុំជម្រះអនីតិជនជាមួយនឹងនីតិជនតែម្តង, ហើយនៅតាមអង្គភាពនគរបាលខ្លះ ពិសេសនៅតាមបណ្តាខេត្ត ឬស្រុកមួយចំនួនមិនទាន់មានការិយាល័យមេធាវី ឬអង្គការជំនួយផ្នែកច្បាប់ ដើម្បីចាំផ្តល់ជំនួយផ្នែកច្បាប់តាមរយៈមេធាវីដោយមិនយកកម្រៃនោះទេ។ ចំពោះមេធាវី ដែលត្រូវបានចាត់តាំងដោយគណៈមេធាវី គួរត្រូវតែចាត់ការរឿងក្តីតាំងពីដំណាក់កាលតុលាការជាន់ទាប រហូតដល់តុលាការជាន់ខ្ពស់ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាតុលាការជាន់ទាប ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

ចំនុចដូចបានរៀបរាប់ខាងលើនេះ ភាគីពាក់ព័ន្ធមានដូចជា រាជរដ្ឋាភិបាល ស្ថាប័នដែលមានសមត្ថកិច្ច ស្ថាប័នតុលាការ គ្រួសារ និងតតិយជនពាក់ព័ន្ធផ្សេងទៀត គួរគប្បីមាន ឬអនុវត្តនូវវិធានការណ៍ទាំងអស់នេះ ក្នុងគោលបំណងធ្វើយ៉ាងណាដើម្បីបង្ក្រាប ឬបង្ការកុំឲ្យមានការប្រព្រឹត្តអំពើដែលជាបទល្មើសព្រហ្មទណ្ឌដោយអនីតិជន។ រាល់ការស្តារនីតិសម្បទា ត្រូវបានធ្វើឡើងដើម្បីអាចឲ្យអនីតិជនបានចូលទៅរស់នៅក្នុងសង្គមវិញ នៅពេលដែលបានអនុវត្តទោសចប់សព្វគ្រប់។

## ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្តជាតិ

**១**. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ និងច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤

**២**. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦

**៣**. ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ប្រកាសឲ្យប្រើនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

**៤**. ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១

**៥**. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

**៦**. ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រកាសឲ្យប្រើនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១២

**៧**. អនុក្រឹត្យស្តីពី អគ្រានុកូលដ្ឋាន ឆ្នាំ ២០០០

**៨**. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស /រកម/១១០៩/០២ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ២០០៩

**៩**. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ និងច្បាប់ស្តីពីវិសោធនកម្ម ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣

**១០**. ក្រមរដ្ឋប្បវេណី ឆ្នាំ ប្រកាសឲ្យប្រើ នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

**១១**. ប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការគ្រប់គ្រង និងស្តារនីតិសម្បទា កុមារ យុវកុមារ នៅយុវនីតិសម្បទា ចោមចៅ លេខ ៤៧០ ស.អ.យ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**១២**. សេចក្តីប្រកាសស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលយុវនីតិសម្បទា ឆ្នាំ ២០០០

១៣. ក្រសួងយុត្តិធម៌កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បោះពុម្ពលើកទីពីរ នៅរាជធានីភ្នំពេញ ឆ្នាំ ២០១៣

១៤. សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

១៥. គោលការណ៍ស្តីពីយុត្តិធម៌អនីតិជន លេខ ០១\ កយ\ សណាន\ ២០០៥ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៥ របស់ក្រសួងយុត្តិធម៌

១៦. សេចក្តីព្រាងស្តីពី សៀវភៅមគ្គុទេសក៍សម្រាប់នគរបាលយុត្តិធម៌ស្តីពីនីតិវិធីនគរបាលយុត្តិ - ធម៌បែបកុមារមេត្រី ឆ្នាំ ២០១៧

១៧. បញ្ជីផ្ទៀងផ្ទាត់សម្រាប់អនុវត្តនីតិវិធីក្នុងរឿងក្តីកុមារនៃក្រសួងយុត្តិធម៌

១៨. ឯកសារយោងនៃកម្មវិធីបណ្តុះបណ្តាលស្តីពី ការអនុវត្តសិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ ឆ្នាំ ២០១២ -២០១៣

១៩. ក្បួននីតិវិធីប្រតិបត្តិការរបស់នគរបាលយុត្តិធម៌

២០. សៀវភៅនីតិព្រហ្មទណ្ឌ, ហ៊ាង ឡេង

២១. វីដេអូបកស្រាយក្រមនីតិវិធីព្រហ្មទណ្ឌ

២២. មេរៀនក្រមព្រហ្មទណ្ឌលោក ប៊ុន ហ៊ុន ឆ្នាំ ២០០៩

២៣. នីតិព្រហ្មទណ្ឌទូទៅ រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត ឆ្នាំ ២០១២

២៤. នីតិវិធីព្រហ្មទណ្ឌ រុន ពណ្ណារិទ្ធ, ចាំង ស៊ីណាត ឆ្នាំ ២០១៥-២០១៦

២៥. បទបង្ហាញស្តីពី ការបង្វែរ របស់លោកមេធាវី អុប វិបុល ថ្ងៃទី ១ និងទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៧

## លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

២៦. សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨

២៧. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦

**២៨**. គោលការណ៍ណែនាំស្តីពីវិធានការណ៍ទាក់ទងនឹងកុមារក្នុងប្រព័ន្ធយុត្តធម៌ព្រហ្មទណ្ឌ ផ្តល់អនុសាសន៍ដោយសេចក្តីសម្រេចលេខ ១៩៩៧\៣០ នៃ ២១ កក្កដា ១៩៩៧ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម

**២៩**. គោលការណ៍ណែនាំនៃអង្គការសហប្រជាជាតិសម្រាប់បង្ការអនីតិជនប្រព្រឹត្តបទល្មើស ឆ្នាំ ១៩៩០ ( គោលការណ៍ណែនាំទីក្រុងរីយ៉ាត )

**៣០**. វិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព

**៣១**. វិធានជាបទដ្ឋានអប្បបរមានៃអង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជនឆ្នាំ ១៩៨៥ វិធានក្រុងប៉េកាំង

**៣២**. អនុសញ្ញាអន្តរជាតិស្តីពីកុមារ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩

## សទ្ទានុក្រម ឬវចនានុក្រម

**៣៣**. សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ - អង់គ្លេស - បារាំង ផ្នែកក្រមព្រហ្មទណ្ឌ នៃទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ ២០១១

**៣៤**. សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ - អង់គ្លេស - បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី នៃទីស្តីការគណៈរដ្ឋមន្ត្រី បោះពុម្ពលើកទី១ ឆ្នាំ ២០០៧

## ឧបសម្ព័ន្ធ

១. កំណត់ហេតុចាប់យកវត្ថុ

២. កំណត់ហេតុសួរចម្លើយ

៣. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

៤. ដីកាសន្និដ្ឋានស្ថាពរ

៥. ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្ន

៦. ដីកាលើកលែងចោទប្រកាន់

៧. ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

៨. កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

៩. សាលក្រមព្រហ្មទណ្ឌសាលាដំបូងរាជធានីភ្នំពេញ

១០. សាលដីកាព្រហ្មទណ្ឌតុលាការកំពូល

2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
++++++

ត-1292|02-12-2015

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ 1324 អ.យ.ទ

## កំណត់ហេតុទទួលវត្ថុចាប់យក

ពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោង ប្រាំបី និងសាមសិប នាទី។

យើង ក្រឡាបញ្ជីនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជាអ្នកទទួល។

លោក ជាមន្ត្រីនគរបាល នៃអធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ រួមជាមួយឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ និងឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាជនសង្ស័យ។

បានពិនិត្យកិនកាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងព្រហ្មលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ឃើញដូចខាងក្រោម៖

√១- ម៉ូតូមួយគ្រឿងម៉ាក CITY ១០០ Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន០១៧៤៤៦ (ម៉ូតូចាស់ ហើយមានតែតួ)

២- ញញួរចំនួន០២, ដែកដាប់ចំនួន០៣, ដែកគាស់ចំនួន០១, កន្ត្រៃចំនួន០៦, កូនកាំបិតចំនួន០២, កាំបិតប៉ុងតោចំនួន០៤, ដាវចំនួន០១ និងដបសម្រាប់ដក់គ្រឿងញៀនចំនួន០១។

៣- អង្គចងចាំចំនួន០១។

យើងធ្វើកំណត់ហេតុនេះ ទុកជាភស្តុតាង ដើម្បីសំអាងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ តាមផ្លូវច្បាប់តទៅ។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ប្រាំបី និងសែសិបប្រាំ នាទី នាថ្ងៃ ខែ ឆ្នាំ ដូចខាងលើ។

| ជនជាប់សង្ស័យ | អ្នកប្រគល់ | អ្នកទទួល |
|---|---|---|

បានឃើញ
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥
ជ.ព្រះរាជអាជ្ញា

បានទទួលវត្ថុតាងចាប់យក (ម៉ូតូ)
ចុះថ្ងៃទី 02-12-2015

ព្រះរាជអាជ្ញារង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**********

អយ្យការអម
**សាលាដំបូងរាជធានីភ្នំពេញ**

# កំណត់ហេតុសួរចម្លើយ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** **ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ** ដោយមាន លោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ មុខរបរជីកអេតចាយ មានទីលំនៅកំណើត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (ស្លាប់) ជាអនីតិជន ទោសពីមុនគ្មាន។ ដោយមានបងស្រីបង្កើត ឈ្មោះ ចូលរួមស្តាប់ចម្លើយ ។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៥ល្ងាច ថ្ងៃទី ០៨-១០-២០១៥ ខ្ញុំបាទពិតជាបានអោយម៉ូតូមួយគ្រឿងម៉ាក C100 ភូរ៉េ ផ្លើស ពណ៌ក្រហម ទៅឈ្មោះ ខ្ចីយកជិះទៅធ្វើសកម្មភាពគាស់ទ្វាផ្ទះគេចូលលួចទូដែកប្រាកដមែន។ ប៉ុន្តែខ្ញុំបាទពុំបានចូលរួមទៅធ្វើសកម្មភាពលួចជាមួយពួកគាត់ទេ។ លុះព្រឹកឡើងថ្ងៃទី ០៩-១០-២០១៥ វេលាម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ បានទូរសព្ទ័ហៅខ្ញុំទៅផ្ទះគាត់នៅខាងក្រោយវត្តច្បារអំពៅ មកយកម៉ូតូវិញ និងបានអោយប្រាក់មកខ្ញុំចំនួន ០១លានរៀល រួចខ្ញុំក៏វិលមកផ្ទះវិញ។

សួរ.ចម្លើយ៖ រហូតដល់ស្អែកឡើងថ្ងៃទី ១០-១០-២០១៥ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខណៈពេលខ្ញុំបាទកំពុងមើលឈ្មោះ និងឈ្មោះ លេងហ្គេម ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនខ្ញុំបាទ និងឈ្មោះ តែម្តង ចំនែកឈ្មោះ បានរត់គេចខ្លួនបាត់។

សួរ.ចម្លើយ៖ ខ្ញុំបាទប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

សួរ.ចម្លើយ៖ ដូច្នេះខ្ញុំបាទសុំសំណូមពរដល់តុលាការមេត្តាជួយរកយុត្តធម៌ដល់រូមខ្ញុំបាទផង ព្រោះខ្ញុំបាទពុំបានចូលរួមធ្វើសកម្មភាពលួចជាមួយគេទេ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្តាប់ សាមីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្តិតម្រាមដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុសួរចម្លើយ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** **ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ** ដោយមាន លោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស <u>អាយុ ១៨ឆ្នាំ</u> ជនជាតិខ្មែរ មុខរបររើសអេតចាយ មានទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (ស្លាប់) ម្ដាយឈ្មោះ (រស់) ជា<u>អនីតិជន</u> ទោសពីមុនគ្មាន។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៣ និង ១៥ នាទីយប់រំលងអាធ្រាតចូលថ្ងៃទី ០៩-១០-២០១៥ ខ្ញុំបាទ និងបក្ខពួកបួននាក់ទៀតមានឈ្មោះ បង បង បង ជិះម៉ូតូរ៉ឺម៉ក់អេតចាយ ទៅធ្វើសកម្មភាព គាស់សោរទ្វាក្រុមហ៊ុននៅម្ដុំទួលស្វាយព្រៃប្រាកដមែន។ ហើយពួកខ្ញុំលួចបានទូដែកមួយមានប្រាក់ជាច្រើនមិនដឹងប៉ុន្មានទេ ហើយឈ្មោះ បានចែកប្រាក់អោយខ្ញុំបាទ ៦០០០ដុល្លារអាមេរិក ខ្ញុំបាទក៏បានផ្ញើទៅប្រពន្ធគាត់ ៤០០០ដុល្លារ ហើយទុក២០០០ដុល្លារចែកអ្នកជិតខាងផ្ទះ។ ចំពោះឯកសារនៅក្នុងទូដែកឈ្មោះ ចយ បានច្រកបាវ ដុតចោលអស់ហើយ ចំនែកទូដែក ខ្ញុំបាទពុំដឹងថានៅទីណាទេ។ រីឯអ្នកផ្សេងទៀត បានចំនែកម្នាក់[redacted]០០០ដុល្លារ នៅប៉ុន្មានគឺឈ្មោះ យកទាំងអស់។

សួរ.ចម្លើយ៖ បក្ខពួករបស់ខ្ញុំខាងលើបានរត់គេចខ្លួនអស់ហើយ ខ្ញុំបាទពុំដឹងថាទៅទីណាទេ។

សួរ.ចម្លើយ៖ កន្លងមកខ្ញុំបាទធ្លាប់វាយសមត្ថកិច្ចប៉ូលីស ហើយត្រូវបានបញ្ជូនមកសាលាដំបូងរាជធានីភ្នំពេញ និងប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្ដាប់ សាមីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្ដិតស្រាមដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥
លេខ ៤៥៩៤ អ.យ.ទ

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ របាយការណ៍សំយោគលេខ ២០៩/១៥ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់[1] អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្មតបានថា៖

១- នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ១៤ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រើសអេតចាយ នៅលីវ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "រ" ទោសពីមុន "គ្មាន" ជា-នីតិជន។

២- ឈ្មោះ ហៅ ភេទប្រុស ប្រពន្ធឈ្មោះ (គេចខ្លួន)

៣- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៤- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៥- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៦- នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅលីវ ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "ស" ទោសពីមុន "គ្មាន" ជា-នីតិជន។

៧- ឈ្មោះ ភេទស្រី ប្តីឈ្មោះ ហៅ (គេចខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ[2] ÷**

កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣និង១៥នាទី ទាបភ្លឺ ជនសង្ស័យឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោះ . . . . . ហៅ ឈ្មោះ ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY ១០០ Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្តោងរ៉ឺម៉ក

---

[1] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌

[2] សេចក្តីសង្ខេបអង្គហេតុ

ដែលជាកម្មសិទ្ធិរបស់ឈ្មោះ          ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> មកឈប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ហើយជនសង្ស័យឈ្មោះ          បានធ្វើសកម្មភាពយកទួរឡឺវីសឆ្កឹះសោទ្វារខាងមុខ ចំណែកជនសង្ស័យឈ្មោះ          បានឆ្កឹះសោទ្វារខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ដុល្លារចំនួន៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនសង្ស័យបានគេចខ្លួនទៅផ្ទះរបស់ជនសង្ស័យឈ្មោះ          ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ          បានទទួលប្រាក់ចំនួន ១លានរៀល។ ក្រោយមកជនសង្ស័យឈ្មោះ          បានយកប្រាក់ចំនួន ៤ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ          ត្រូវជាប្រពន្ធរបស់ជនសង្ស័យឈ្មោះ          ។ ចំណែកជនសង្ស័យឈ្មោះ          បានឲ្យប្រាក់ទៅប្រពន្ធចំនួន ១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ ហើយឃាត់ខ្លួនជនសង្ស័យពីរនាក់មានឈ្មោះ          និងឈ្មោះ          ព្រមទាំងដកហូតវត្ថុតាងដូចមានក្នុងកំណត់ហេតុ ដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។

អំពើរបស់ឈ្មោះ          ឈ្មោះ          ហៅចយ ឈ្មោះ          ឈ្មោះ          និងឈ្មោះ          ជាបទល្មើសលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ          ជាបទល្មើស សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ          ជាបទល្មើស ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>**ហេតុដូច្នេះសម្រេច**</u>

- បើកការស៊ើបសួរលើរង្គហេតុខាងលើ និង

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើឈ្មោះ[៣]

១-          ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន)

២-          ហៅ          ភេទប្រុស (គេចខ្លួន)

៣-          ភេទប្រុស (គេចខ្លួន)

៤-          ភេទប្រុស (គេចខ្លួន)

៥-          ភេទប្រុស (គេចខ្លួន)

---

[៣] ឈ្មោះជនត្រូវចោទ

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលេទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE$_0$ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦- ហៅ ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន)

ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE$_0$ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៧- ភេទស្រី

ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE$_0$ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

☐ ដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៤]: ......................................................។

☑ ដាក់អោយស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន[៥]:

១- ភេទប្រុស អាយុ១៤ឆ្នាំ (ឃាត់ខ្លួន)

២- ហៅ ភេទប្រុស (គេចខ្លួន)

៣- ភេទប្រុស (គេចខ្លួន)

៤- ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៦- ហៅ ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន)

ពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៧- ភេទស្រី ពីបទ ទទួលផលចោរកម្ម

• ដោយហេតុថា ការឃុំខ្លួនបណ្ដោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី ៖

- បញ្ឈប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតជាថ្មី
- រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
- ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
- រារាំងការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងបក្ខពួក។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៥

ជ.ព្រះរាជអាជ្ញា

---

[៤] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា២២៣

[៥] មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលបានចែងនៅក្នុងមាត្រា២០៥

**ព្រះរាជអាជ្ញារង**

1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

++++++

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥

# ដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្តោះអាសន្ន

យើង .. ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ .៦៥៩៤. អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ ដែលបើកការស៊ើបសួរពីបទៈ សមគំនិត និងលួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តហិង្សា។
- បានឃើញដីកាបញ្ជូនឲ្យឆ្លើយរបស់ចៅក្រមស៊ើបសួរចុះថ្ងៃទី ........ ខែ........... ឆ្នាំ...............
- បានឃើញមាត្រា ២០៣, ២០៥, និង២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ដោយហេតុថា ការឃុំខ្លួនបណ្តោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី**

☐ បញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី

☐ រារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការ ត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

☐ រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

☐ ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

☐ ការពារសន្តិសុខឲ្យជនត្រូវចោទ

☐ ធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស

**យល់ឃើញថា ÷**

ការឃុំខ្លួនបណ្តោះអាសន្នជាមធ្យោបាយសំរាប់បញ្ឈប់ភាពចលាចលធ្ងន់ធ្ងរ និងយូរអង្វែងចំពោះ សណ្តាប់ធ្នាប់សាធារណៈ ដោយមូលហេតុៈ

☐ ភាពធ្ងន់ធ្ងរនៃបទល្មើស

☐ កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស

☐ ទំហំនៃព្យសនកម្មដែលបង្កឡើងដោយបទល្មើស

**ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្នលើ**

១- នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ១៨ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រើសអេតចាយ នៅលីវ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "រ" ទោសពីមុន "គ្មាន" ជា-នីតិជន។

២- នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅលីវ ឪពុកឈ្មោះ "វ" ម្តាយឈ្មោះ "ស" ទោសពីមុន "គ្មាន" ជា-នីតិជន។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៥

ជ.ព្រះរាជអាជ្ញា

**ព្រះរាជអាជ្ញារង**

37

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥
លេខ ៖ ៦៣ អ.យ.ទ

# ដីកាសន្និដ្ឋានស្ថាពរ

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។
- បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខ២១១៦៩ ត.ព្រ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញថា

១. គោត្តនាម-នាម ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ(ឃាត់ខ្លួន) កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅ លីវ ឪពុកឈ្មោះ "ស្លាប់"ម្ដាយឈ្មោះ "រស់"ទោសពីមុន "គ្មាន"ជាអនីតិជន។

២.គោត្តនាម-នាម ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ (ឃាត់ខ្លួន) កើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន ភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ (រ) កូនគ្មាន ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ជានីតិជន ទោសពីមុនគ្មាន។

៣.ឈ្មោះ ភេទប្រុស(គេចខ្លួន)

៤.ឈ្មោះ ភេទប្រុស(គេចខ្លួន)

៥.ឈ្មោះ ភេទប្រុស(គេចខ្លួន)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៦.គោត្តនាម-នាម ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ(ឃាត់ខ្លួន) កើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្វាយតាអុក សង្កាត់រាលស្ប៉ូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរសើសអេតចាយ នៅ លីវ ឪពុកឈ្មោះ រស់ ម្តាយឈ្មោះ ស្លាប់ ទោសពីមុន គ្មាន ជាអនីតិជន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, ៣៥៣ និង មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៧. ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្តីឈ្មោះ ហៅ (រ) កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

**ឃើញថា**

កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣ម១៥នាទី ទាបភ្លឺជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ, ឈ្មោះ ហៅ , ឈ្មោះ ឈ្មោះ និង ឈ្មោះ បានជិះម៉ូតូម៉ាក CITY 100PLUS ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្តោងរ៉ឺម៉ក ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ មកឈប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានជនត្រូវចោទឈ្មោះ បានធ្វើសកម្មភាពយកទូឡឺវីសឆ្កឹះសោរទ្វារខាងមុខ ចំណែកជនត្រូវចោទឈ្មោះ បានឆ្កឹះសោរទ្វាខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ចំនួនប្រាំម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនត្រូវចោទបានគេចខ្លួនទៅផ្ទះរបស់ជនត្រូវចោទឈ្មោះ ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ បានទទួលប្រាក់ចំនួន១លានរៀល។ ក្រោយមកជនត្រូវចោទឈ្មោះ បានយកប្រាក់ចំនួន៤ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ ត្រូវជាប្រពន្ធរបស់ជនត្រូវចោទឈ្មោះ ។ ចំណែកជនត្រូវចោទឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការ

ស្រាវជ្រាវ ហើយឃាត់ខ្លួនជនត្រូវចោទពីរនាក់មានឈ្មោះ និង ឈ្មោះ ព្រមទាំងដកហូតវត្ថុតាងដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។

បានឃើញរបាយការណ៍សំយោគលេខ ២០៩/១៥ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថាៈ ជនត្រូវចោទឈ្មោះ (ឃាត់ខ្លួន) និងបក្ខពួកឈ្មោះ ,ឈ្មោះ , ឈ្មោះ និង ឈ្មោះ (គេចខ្លួន) ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស កាលពីវេលាម៉ោង ០៣ម១៥នាទី រំលងអាធ្រាតឈានចូលថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនស៊ីហ្គាទេសចរណ៍ និង ពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពិតប្រាកដមែន។ ចំណែកជនត្រូវចោទឈ្មោះ (ឃាត់ ខ្លួន) ពិជាបានសមគំនិត ផ្តល់ជាមធ្យោបាយធ្វើសកម្មភាព និង ទទួលផលចោរកម្ម ក្នុងករណីនេះប្រាកដមែន រីឯឈ្មោះ (គេចខ្លួន) ដែលជាប្រពន្ធរបស់ជនត្រូវចោទឈ្មោះ ក៏ជាអ្នកទទួលផលចោរកម្ម ក្នុងករណីនេះផងដែរ។

បានឃើញចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយនៅសមត្ថកិច្ចថា ៖កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានចេញពីក្រុមហ៊ុនរបស់ខ្លួន មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅសំរាកនៅផ្ទះ។ លុះដល់ម៉ោងប្រហែល ០៤ម០០នាទី ទៀបភ្លឺចូលថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ពេលខ្លួនកំពុងសំរាក ក៏ហេនសមត្ថកិច្ចទូរស័ព្ទមកប្រាប់ខ្លួនថា ក្រុមហ៊ុនរបស់ខ្លួនត្រូវបានចោរគាស់ទ្វារ ពេលនោះ ខ្លួនក៏បានមកមើល ទើបដឹងថា បាត់ទូដែកចំនួន០១ ហើយក្នុងទូដែកនោះមានប្រាក់ចំនួន ៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន ២លានរៀល ឯកសារប្លង់ដីមួយចំនួន សៀវភៅធនាគារចំនួន០៣ក្បាល និង បាត់ម៉ាស៊ីនស្កេនចំនួន០១គ្រឿងផងដែរ។

បានឃើញចម្លើយរបស់សាក្សីឈ្មោះ /បានឆ្លើយនៅសមត្ថកិច្ចថាៈ កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានចេញពីក្រុមហ៊ុន ត្រលប់ទៅផ្ទះសំរាក ដោយខ្លួនបានចាក់សោរទ្វាក្រុមហ៊ុនត្រឹមត្រូវ។ លុះទៀបភ្លឺថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ប្រធានក្រុមហ៊ុនរបស់ខ្លួនបានទូរស័ព្ទមកប្រាប់ខ្លួនថា នៅក្រុមហ៊ុនមានចោរចូលគាស់ទ្វា ពេលនោះខ្លួនក៏ប្រញ៉ាប់មកក្រុមហ៊ុន រួចទើបដឹងថាចោរលួចយកទូរដែក០១ នៅក្នុងបន្ទប់របស់ប្រធានក្រុមហ៊ុន។

បានឃើញចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ច និង នៅអយ្យការ ប្រហាក់ប្រហែលទៅនឹងចម្លើយនៅចៅក្រមស៊ើបសួរថាៈ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ០៣ម ១៥នាទី ខ្លួនពិតជាបានធ្វើសកម្មភាពគាស់ទ្វារក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃ ដោយលួចបានទូរដែកប្រាកដមែន។ មុនដំបូងឈ្មោះ ( ) បានយកម៉ូតូ០១គ្រឿងម៉ាកសេ១០០គូរ៉េឆ្អើសពណ៌ក្រហម គ្មានស្លាកលេខ ពីឈ្មោះ ( ) មកគកន្ទុយរ៉ឺម៉ក ដឹករូបខ្លួន និង បក្ខពួកផ្សេងទៀត ឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ។ ពេលពួកខ្លួនធ្វើដំណើរមកដល់ម្តុំទួលស្វាយព្រៃ ក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោរនៅខាងក្រៅ ពេលនោះពួកខ្លួនក៏បានឈប់ម៉ូតូ ហើយខ្លួនក៏បានយកទុលឡឺវីសមកឆ្កិះសោរសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ឆ្កិះសោរទ្វាខាងក្នុង រួចនាំគ្នាចូលទៅក្នុងក្រុមហ៊ុនរើកកាយ និងលួចយកបានទូរដែក០១នៅជាន់ខាងលើ ហើយក៏នាំគ្នាដឹកតាមរ៉ឺម៉ក ទៅផ្ទះរបស់ឈ្មោះ ដើម្បីគាស់ បានឃើញលុយដុល្លារជាច្រើន និង ឯកសារផ្សេងទៀត ហើយចែកលុយគ្នា ដោយខ្លួនទទួលបានប្រាំមួយពាន់ដុល្លារ រីឯឯកសារទាំងនោះត្រូវបានដុតចោល។ បន្ទាប់មកខ្លួនបានយកលុយចំនួនបួនពាន់

ដុល្លារទៅផ្ញើរនិងឈ្មោះ ហើយសល់ប៉ុន្មានខ្លួនទៅចាយវាយនិងចែកអ្នកជិតខាងនៅស្វាយរៀង។ លុះដល់ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣ម០០នាទី រសៀល ពេលខ្លួនកំពុងអង្គុយលេង ជាមួយឈ្មោះ និង ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួន។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ច និងនៅអយ្យការ ប្រហាក់ប្រហែលទៅនឹងចម្លើយនៅចៅក្រមស៊ើបសួរថាៈ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ ខ្លួនពិតជាបានអោយម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែក ប្រាកដមែន។ មុនដំបូងនៅល្ងាចថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ឈ្មោះ បានទូរសព្ទមកខ្លួនអោយទៅយកគេនៅម៉ុប្បារអំពៅ ពេលនោះខ្លួនក៏បានជិះម៉ូតូម៉ាក ១០០ កូរ៉េផ្លើស ពណ៌ក្រហម គ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូរបស់ខ្លួនជិះ រួចខ្លួនក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញ។ មូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរបស់ខ្លួន គឺម៉ូតូរបស់ខ្លួនមានប្រដាប់សណ្តោងរ៉ឺម៉កស្រាប់។ លុះព្រឹកឡើងថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល៧ម០០នាទី ឈ្មោះ បានទូរស័ព្ទមកខ្លួនអោយយកមកម៉ូតូ និង បានឲ្យលុយមកខ្លួនចំនួនមួយលានរៀល។ រហូតដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣ម០០នាទី ខ្លួនបានជិះម៉ូតូមកអង្គុយលេងជាមួយឈ្មោះ និង ឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់មានសមត្ថកិច្ចមកឃាត់រូបខ្លួន និង ឈ្មោះ នាំមកកាន់អធិការដ្ឋាននគរបាលចំការមនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស បានឆ្លើយនៅចៅក្រមស៊ើបសួរថាៈ ខ្លួនពិតជាបានចូលរួមប្រព្រឹត្តអំពើលួចគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ ក្នុងនោះមានឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ ហៅ ។ ពេលនោះពួកខ្លួនលួចបាន ទូដែក១ យកទៅបើកនៅផ្ទះរបស់ខ្លួន ក្នុងនោះមានលុយចំនួន៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិកគត់) ហើយក៏បានចែកគ្នា ដោយរូបខ្លួនបានចំណែកចំនួន ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិកគត់) លុយសល់ពីនោះ ទុកឲ្យបក្ខពួក៤នាក់ទៀតចែកគ្នា។ ចំណែកទូរដែកនោះ បានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បារអំពៅ។

- ដីកាបង្គាប់ឲ្យចូលខ្លួនលេខ ១៨៤៨៦ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យនាំខ្លួនលេខ ៨០៦ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៥១៦៣ ត.ព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥២៦ ត.ព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៤១២៤ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៤ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៤១២៣ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៩ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបញ្ជូនឲ្យឆ្លើយលេខ ២០៩១២ តព្រ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៥ របសចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៨១៣ តព្រ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាចាត់ឲ្យស៊ើបសួរជំនួសលេខ ១៨៤៨៩ តព្រ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស។

- របាយការណ៍របស់នគរបាលប៉ុស្តិ៍ទួលស្វាយព្រៃទី១ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ តាមការចុះស្រាវជ្រាវរកឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ពុំមានស្ថិតិស្នាក់នៅនិងសាវតាជាតិនៅក្នុងមូលដ្ឋានមណ្ឌលទី៨នោះទេ។

- លិខិតជូនដំណឹង ឬជូនព័ត៌មានដល់តំណាងអយ្យការលេខ ២០៧៣៧ ត.ព្រ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

- ឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធសំណុំរឿង ។

## <u>យល់ឃើញថា</u>

- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងចម្លើយសារភាពរបស់ជនត្រូវចោទ រោនភាពស៊ីសង្វាក់ទៅនឹងភស្តុតាងអាចបង្ហាញឲ្យឃើញថា ៖ ជនត្រូវចោទឈ្មោះ ភេទប្រុស ងាយុ២៧ឆ្នាំ, ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> និង ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ពិតជាបានប្រព្រឹត្តអំពើគ្គឹះសោរទ្វារក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ដើម្បីលួចយកប្រាក់របស់ជនរងគ្រោះឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពិតប្រាកដមែន ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ, ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u>, ឈ្មោះ ភេទប្រុស (គេចខ្លួន), ឈ្មោះ ភេទប្រុស (គេចខ្លួន) និង ឈ្មោះ ភេទប្រុស (គេចខ្លួន) គឺអំពើដកហូតទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត តាមមធ្យោបាយគ្គឹះសោទ្វារក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ ដើម្បីមកធ្វើជាកម្មសិទ្ធរបស់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសលួចមានស្ថានទម្ងន់ទោស និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> គឺជាអំពើសំរបសំរួលដើម្បីសម្រេចបាននូវសកម្មភាពក្នុងអំពើលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិតតាមមធ្យោបាយគ្គឹះសោទ្វារក្រុមហ៊ុន

ស៊ីហ្គាទេសចរណ៍ដើម្បីយកប្រាក់ធ្វើជាកម្មសិទ្ធរបស់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ២២ឆ្នាំ គឺជាអ្នកទទួលផលក្នុងអំពើលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសទទួលផលចោរកម្ម និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

- ឈ្មោះ ភេទប្រុស អាយុ២៧ ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជានីតិជនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។

- ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និង ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជា អនីតិជន ប៉ុន្តែមានលក្ខណៈសម្បត្តិយល់ដឹងធនល្មមក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។

- មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើឈ្មោះ និង ឈ្មោះ ពីបទះលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា, ឈ្មោះ ភេទប្រុស ពីបទះសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងឈ្មោះ ភេទស្រី ពីបទះ ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ។

- តាមលទ្ធផលស្រាវជ្រាវរបស់នគរបាលប៉ុស្តិ៍ទួលស្វាយព្រៃទី១ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ រកពុំឃើញឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ស្ថិតិស្នាក់នៅនិងសាវតាជាតិនៅក្នុងមូលដ្ឋានមណ្ឌលទី៤ ទេ។

- យោងតាមមាត្រា ២៤៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧១ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីចៅក្រមលើកលែងចោទប្រកាន់លើឈ្មោះ ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ដោយហេតុជនត្រូវចោទនេះពុំសាវតាជាតិពិតប្រាកដ។

## ហេតុដូច្នេះ

ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច ៖

☑ បញ្ជូនជនត្រូវចោទឈ្មោះ

១. ...... ភេទប្រុស អាយុ២៧ឆ្នាំ (ឃាត់ខ្លួន)

២. ...... ភេទប្រុស អាយុ១៤ឆ្នាំ(ឃាត់ខ្លួន) ទៅជំនុំជម្រះ។

ពីបទ ះលួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី

១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣. ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន) ទៅជំនុំជម្រះ

ពីបទ ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, មាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤. ភេទស្រី អាយុ២២ឆ្នាំ (គេចខ្លួន) ទៅជំនុំជម្រះ

ពីបទ ៖ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និង មាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

☑ លើកលែងចោទប្រកាន់

- ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស

ពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១..ខែ មករា ឆ្នាំ២០១៦

ព្រះរាជអាជ្ញា

**ព្រះរាជអាជ្ញារង**

(២០/៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ (ព)
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ៤០៣៩ ចុះថ្ងៃទី ១៣
ខែ តុលា ឆ្នាំ ២០១៥
លេខស៊ើបសួរ ២៦០៥
ចុះថ្ងៃទី ១៥ ខែ តុលាឆ្នាំ
២០១៥ ។

## កំណត់ហេតុស្តីពី
## ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

**(មាត្រា ១៥០ និង មាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ)**

ឆ្នាំពីរពាន់ដប់ប្រាំ ខែ ធ្នូ ថ្ងៃទី មួយ វេលាម៉ោង ៨ និងសាមសិបនាទីព្រឹក

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានមកបង្ហាញខ្លួនក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងមន្ទីរស៊ើបសួរចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោមៈ

នាមត្រកូល នាមខ្លួន ភេទប្រុស អាយុ ៤២ ឆ្នាំ ជាតិខ្មែរ មានទីលំនៅកំណើតនៅឃុំ កំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខៈ២៧៩ BE₀ ផ្លូវលេខ ១៨២ ភូមិទី ៨ សង្កាត់ទឹកល្អក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរ ប្រធានក្រុមហ៊ុន កំរិតវប្បធម៌ ថ្នាក់ទី១២ ប្រពន្ធឈ្មោះ (រ) កូន ០៣ នាក់ ឳពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ជានីតិជន ។

**-ជននេះ ចេះនិយាយ ចេះអាន ចេះសរសេរអក្សរខ្មែរ**

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ**២៥៩៤ អ.យ.ទ** ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**យើងបានសួរ និងស្តាប់ចម្លើយដូចខាងក្រោមថាៈ**

**ស.ឆៈ** ពាក្យបណ្តឹងចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ ពិតជាពាក្យបណ្តឹងដែលខ្ញុំបាទបានធ្វើនៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ទួលស្វាយព្រៃទី១ ដោយសមត្ថកិច្ចជាអ្នកសរសេរឲ្យ ហើយខ្ញុំបាទបានផ្តិតមេដៃប្រាកដមែន ។

**ស.ឆៈ** ខ្ញុំបាទសូមបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះ នៅម៉ោងប្រហែល ៤ ទាបភ្លឺ សមត្ថកិច្ចប៉ុស្តិ៍នគរបាល បានទូរស័ព្ទមកសួរខ្ញុំបាទបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្ញុំថាតើខ្ញុំបាទពិតជាអ្នកធ្វើការនៅក្នុងក្រុមហ៊ុននោះមែនឬអត់ ? ដោយគាត់បញ្ជាក់ប្រាប់ថា ឃើញក្រុមហ៊ុនរបស់ខ្ញុំបានត្រូវបើកទ្វារនិងបែកទ្វារកញ្ចក់ និង ឲ្យខ្ញុំបាទទៅពិនិត្យមើល ភ្លាមនោះ ខ្ញុំបាទក៏បានទៅមើលភ្លាមដែរ នឹងបានឃើញដូចអ្វីដែលសមត្ថកិច្ចបានប្រាប់ខ្ញុំបាទមែន ។ បន្ទាប់ពីបានពិនិត្យមើលឃើញទូដែករបស់ខ្ញុំមួយត្រូវបានបាត់ក្នុងនោះ ( មានប្រាក់ប្រហែលចំនួន **៥០.០០០ $** ( ប្រាំម៉ឺនដុល្លារអាមេរិក ) និង លុយខ្មែរចំនួន**២.០០០.០០០ រ,០០** ( ពីរលានរៀល ) ព្រមទាំងឯកសារមួយចំនួន ដូចជា លិខិតផ្ទេរសិទ្ធិប្រើប្រាស់ដីធ្លីមួយកន្លែង និង សៀវភៅធនាគារចំនួន ៣ ក្បាល, ឯកសារពាក់ព័ន្ធនិងក្រុមហ៊ុនរបស់ខ្ញុំបាទ ហើយរបស់របរផ្សេងទៀតត្រូវរើកកាយ។

ស.ឆ: ក្នុងខណៈនោះ ជនល្មើសពុំទាន់ត្រូវបានចាប់ខ្លួនបានទេ ក្រោយមកទើបសមត្ថកិច្ចកំណត់មុខសញ្ញា ដោយផ្អែកតាមរយៈកាមមីរ៉ាសុវត្ថភាពដែលបញ្ជាក់ពីមុខសញ្ញា និង តាមការពិនិត្យទៅលើក្រយៅដៃ ទើបឈានដល់ការឃាត់ខ្លួនជនល្មើសបាន ។

ស.ឆ: ក្នុងរឿងនេះ ខ្ញុំបាទប្ដឹងសុំទាមទារសំណងជាប្រាក់ដែលត្រូវបានបាត់បង់ ចំនួន **៥០.០០០ $** ( ប្រាំម៉ឺនដុល្លារអាមេរិក ) និង លុយខ្មែរចំនួន **២.០០០.០០០ ៛,០០** ( ពីរលានរៀល ) និងសម្ភារៈដែលបានបាត់បង់ជាឯកសារ និងពុំទាមទារសំណងជម្ងឺចិត្តអ្វីពីជនល្មើសទេ តែសុំឲ្យតុលាការផ្ដន្ទាទោសជនល្មើសតាមច្បាប់ចុះ ។

យើងបានឲ្យដើមបណ្ដឹងអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយដើមបណ្ដឹងមិនបានបដិសេធត្រង់ចំណុចណាទេ និង បានចុះហត្ថលេខាជាមួយយើង និង ក្រឡាបញ្ជី ។

| | | |
|---|---|---|
| **ដើមបណ្ដឹងរដ្ឋប្បវេណី** | **ក្រឡាបញ្ជី** | **ចៅក្រមស៊ើបសួរ** |

២០០១-១៦ 34/3

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្ន

សាលាដំបូងរាជធានីភ្នំពេញ

លេខ...358......(ព)ដឃដ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញមាត្រា២៤៩ មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៨០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្ថានពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-ឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) នៅលើវ ទោសពីមុនគ្មាន ជានីតិជន។

ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៣ តព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។

## យល់ឃើញថា

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី ដើម្បីរក្សាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធីដើម្បីការពារសន្តិសុខឲ្យជនជាប់ចោទដើម្បីរក្សាសណ្ដាប់ធ្នាប់កុំឲ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស ។

## ហេតុដូច្នេះសម្រេច

-បង្គាប់មកលោកប្រធានពន្ធនាគារ (ម២) ឲ្យរក្សាការឃុំខ្លួនឈ្មោះ ភេទប្រុស អាយុ ១៨ឆ្នាំ រហូតដល់បង្ហាញខ្លួននៅមុខសាលាដំបូងរាជធានីភ្នំពេញ។

រាជធានីភ្នំពេញ ថ្ងៃទី ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

បានទទួលដំណឹង

រាជធានីភ្នំពេញថ្ងៃទី ខែមករា ឆ្នាំ២០១៦

ឧ.ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជអាជ្ញារង

៥៤/១

20.01.16

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ 359 ...(ព)ជឃដ

## ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្ន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញមាត្រា២៤៩ មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្ថានពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (ស) នៅលីវ ទោសពីមុនគ្មាន ជានីតិជន។

ជាប់ចោទពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា២៩,មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៤ តព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។

### យល់ឃើញថា

-ដើម្បីបញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី ដើម្បីរក្សាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធីដើម្បីការពារសន្តិសុខឲ្យជនជាប់ចោទដើម្បីរក្សាសណ្ដាប់ធ្នាប់កុំឲ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស ។

### ហេតុដូច្នេះសម្រេច

-បង្គាប់មកលោកប្រធានពន្ធនាគារ (ម២) ឲ្យរក្សាការឃុំខ្លួនឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ រហូតដល់បង្ហាញខ្លួននៅមុខសាលាដំបូងរាជធានីភ្នំពេញ។

បានទទួលដំណឹង

រាជធានីភ្នំពេញថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១៦

ខ.ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជអាជ្ញារង

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

៣៤/១

សាលាដំបូងរាជធានីភ្នំពេញ
លេខ...១៦០......(ព)ជឃជ

# ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្ន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញមាត្រា២៤៩ មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្ថានពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) កូនគ្មាន ជានីតិជន។

ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥២៦ តព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥។

## យល់ឃើញថា

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី ដើម្បីរក្សាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធីដើម្បីការពារសន្តិសុខឲ្យជនជាប់ចោទដើម្បីរក្សាសណ្ដាប់ធ្នាប់កុំឲ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស ។

## ហេតុដូច្នេះសម្រេច

-បង្គាប់មកលោកប្រធានពន្ធនាគារ (ម១) ឲ្យរក្សាការឃុំខ្លួនឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ រហូតដល់បង្ហាញខ្លួននៅមុខសាលាដំបូងរាជធានីភ្នំពេញ។

២/១/១៦

បានទទួលដំណឹង
រាជធានីភ្នំពេញថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៦
ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៦
ចៅក្រមស៊ើបសួរ

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )

លេខ ១១០ ដដ

## ដីកាលើកលែងចោទប្រកាន់

យើង ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញមាត្រា ២៤៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៨០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញដីកាសន្និដ្ឋានឲ្យស៊ើបសួរលេខ ២៥៩៥ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់

### សំអាងហេតុ

១.ជនត្រូវចោទឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្ដឹងសុំឲ្យចៅក្រមស៊ើបសួរលើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ គប្បីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) តាមមាត្រា២៤៧ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

លើកលែងចោទប្រកាន់លើឈ្មោះ  ភេទប្រុស ,ឈ្មោះ  ភេទប្រុស និងឈ្មោះ  ភេទប្រុស (គ្មានអត្តសញ្ញាណ) ពីបទ:លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

លេខ ......៦៨......អ.យ.ទ

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

រាជធានីភ្នំពេញ ថ្ងៃទី...១៦...ខែមករា ឆ្នាំ២០១៦

ក្រឡាបញ្ជី

ចៅក្រមស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )

លេខ ៤១ ដ.ដ

# ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញ មាត្រា ២៤៧ និងមាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នលេខ៦៩៩,៦៩១,៦៦០(៣)ដឃដ ចុះថ្ងៃទី.....១៤..... ខែមករា ឆ្នាំ២០១៦។

ក្រោយពីបានពិនិត្យស៊ើបសួរចប់សព្វគ្រប់ហើយយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើ :

១.ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) នៅលីវ ជានីតិជន។

២.ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទូលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (ស) នៅលីវ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទូលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា២៩,មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤.ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្តីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការ: គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាល ទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

បញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ,ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខ: ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ព្រមទាំងវត្ថុតាង និងបញ្ជីវាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦
ចៅក្រមស៊ើបសួរ

បានទទួលដំណឹង
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦
ក្រឡាបញ្ជី
ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ :៤០៣៩
ចុះថ្ងៃទី១៣/១០/២០១៥
ជំនុំជំរះលេខ: ១៩៧
ចុះថ្ងៃទី២២/០៧/២០១៦
សាលក្រមព្រហ្មទណ្ឌ
លេខ: ១៤១ ក្រ៨ "ជ"
ចុះថ្ងៃទី២២/០៤/២០១៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**នាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៦ នៅវេលាម៉ោង ០៨.៣០នាទី ព្រឹកដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក ប្រធានក្រុមប្រឹក្សា
លោក ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជំរះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ មានជនជាប់ចោទ:

១/ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ មុខរបរដើររើសអេតចាយ ទីកន្លែងកំណើតសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិស្វាយតាអុក សង្កាត់ភ្នំពេញ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ)នៅលីវ ជាអនីតិជន ។

-ឃាត់ខ្លួននៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ២៨៣៩ ត.ព ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។

២/ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ៣៥២៦ តព ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ។

ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣/ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរដើររើសអេតចាយទីកន្លែងកំណើតស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្នភូមិស្វាយតាអុក

សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ជាអនីតិជន ទោសពីមុនគ្មាន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ២៨៣៤ តព ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥។

ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីប្តោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤/ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅសព្វថ្ងៃភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស)ម្តាយឈ្មោះ (រ)ប្តីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន(ក្រៅឃុំ) ។

ដោយមានកញ្ញា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីប្តោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរជាប្រធានក្រុមហ៊ុនស៊ីប្តោលទេសចរណ៍និងពាណិជ្ជ ទីលំនៅកំណើតឃុំកំពង់សៀម ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃផ្ទះលេខ២៧៩BEo ផ្លូវ១៨២ ភូមិ៨ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍សំយោគលេខ ២០៩ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ ២០៩ ដ.ដ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

**<u>អង្គហេតុដែលត្រូវបានចោទប្រកាន់និងបញ្ជូនមកជំនុំជម្រះ</u>**

កាលពី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទីទាបភ្លឺជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ , ឈ្មោះ , ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY 100 PLUS ពណ៌ក្រហមគ្មានស្លាកលេខ លេខម៉ាស៊ីន០១៧៤៤៦ ដោយមាន សណ្តោងរ៉ឺម៉កដែលជាកម្មសិទ្ធិរបស់ឈ្មោះ មកឈប់នៅខាងមុខក្រុមហ៊ុនស៊ិនស៊ីប្តោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន មានជនជាប់ចោទឈ្មោះ បានធ្វើសកម្មភាពយកទូឡឺវីសផ្តិះសោទ្វាខាងមុខចំណែកជនជាប់ចោទឈ្មោះ បានផ្តិះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួន១ ដែលក្នុងនេះមានប្រាក់ចំនួន

ប្រាំម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និង ឯកសារប្លង់ដីព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួន១ បន្ទាប់មកជនជាប់ចោទបានគេចខ្លួនទៅផ្ទះរបស់ឈ្មោះ ហើយបានយកប្រាក់ទាំងនេះចែកជាចំណែក ដោយឈ្មោះ ទទួលបានប្រាក់ចំនួន១លានរៀល បន្ទាប់មកជនជាប់ចោទឈ្មោះ បានយកប្រាក់ចំនួន៤,០០០$ផ្ញើទុកនៅនឹងឈ្មោះ ដែលត្រូវជាប្រពន្ធរបស់ជនជាប់ចោទរបស់ឈ្មោះ ។ ចំណែកជនជាប់ចោទឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន១ម៉ឺនដុល្លារអាមេរិក រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវហើយឃាត់ខ្លួនជនជាប់ចោទបានចំនួន២នាក់គឺឈ្មោះ និងឈ្មោះ ព្រមទាំងដកហូតបានវត្ថុតាងដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធី ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទី ខ្ញុំពិតជាបានធ្វើសកម្មភាពគាស់ទ្វាក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃដោយលួចបានទូរដែកប្រាក់ដមែន ។ មុនដំបូងឈ្មោះ បានយកម៉ូតូមួយគ្រឿងម៉ាកសេ១០០កូរ៉េឆ្លើលពណ៌ក្រហមគ្មានស្លាកលេខពីឈ្មោះ ( ) មកតកន្ទុយរ៉ឺម៉កបានដឹករូបខ្ញុំនិងបក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ ។ ពេលពួកខ្ញុំធ្វើដំណើរមកដល់ទួលស្វាយព្រៃក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោនៅខាងក្រៅ ពេលនោះពួកខ្ញុំក៏បានឈប់ម៉ូតូហើយខ្ញុំក៏បានយកទួឡឺវីសមកឆ្កឹះសោសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ឆ្កឹះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុងក្រុមហ៊ុនរើកកាយនិងលួចយកបានទូរដែក១នៅជាន់ខាងលើ ហើយក៏នាំគ្នាដឹកតាមរ៉ឺម៉កទៅផ្ទះរបស់ឈ្មោះ ដើម្បីគាស់បានឃើញលុយជាច្រើន និងឯកសាផ្សេងទៀត រួចហើយបានចែកលុយគ្នាដោយខ្ញុំទទួលបានប្រាំពាន់ដុល្លារអាមេរិក រីឯឯកសារទាំងនោះត្រូវបានដុតចោល បន្ទាប់មកខ្ញុំបានយកលុយចំនួន៤ពាន់ដុល្លារអាមេរិក ទៅផ្ញើនិងឈ្មោះ នៅសល់ប៉ុន្មានពួកខ្ញុំបានយកទៅចាយវាយនិងចែកអ្នកជិតខាង នៅស្វាយរៀង លុះដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទីរសៀលខ្ញុំកំពង់អង្គុយលេង ជាមួយឈ្មោះ និងឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ខ្ញុំពិតជាបានយកម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែកប្រាក់ដមែន ។ មុនដំបូងនៅល្ងាចថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ឈ្មោះ បានឲ្យទូរសព្ទមកខ្ញុំឲ្យយកទៅគេនៅម្តុំច្បារអំពៅ ពេលនោះខ្ញុំក៏បានជិះម៉ូតូម៉ាកសងសេ១០០ កូរ៉េឆ្លើសពណ៌ក្រមគ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូរបស់ខ្ញុំជិះរួចខ្ញុំក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញមូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរបស់ខ្ញុំគឺម៉ូតូរបស់ខ្ញុំមានប្រដាប់សន្តោងរ៉ឺម៉កស្រាប់ ។ លុះព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៧,០០នាទីឈ្មោះ បានទូរសព្ទប្រាប់ឲ្យខ្ញុំមកយកម៉ូតូ និងបានឲ្យលុយមកខ្ញុំចំនួន១លានរៀល ។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទី ខ្ញុំបានជិះម៉ូតូមកអង្គុយលេងជាមួយឈ្មោះ និងឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនខ្ញុំ និងឈ្មោះ នាំមកកាន់អធិការដ្ឋាននគរបាលតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថាៈ ខ្ញុំពិតជាបានចូលរួមគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ក្នុងនេះមានឈ្មោះ ឈ្មោះ ,ឈ្មោះ ,ឈ្មោះ ហៅ ។ ពេលនោះពួកខ្ញុំលួចបានទូរដែក១ យកទៅបើកនៅផ្ទះរបស់ខ្ញុំ ក្នុងនោះមានលុយចំនួន៥០,០០០$ រួចហើយក៏បានចែកគ្នា ដោយខ្ញុំបានចំនួន១០,០០០$ លុះសល់ពីនោះទុកឲ្យបក្សពួក៤នាក់ទៀតចែកគ្នា ចំណែកទូរដែកនេះបានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បារអំពៅ ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ នៅពេលសវនាការថាៈ កាលពី ថ្ងៃទី០៨ខែតុលា ឆ្នាំ២០១៥ ខ្ញុំបានចេញពីក្រុមហ៊ុនរបស់ខ្ញុំមានទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅ សម្រាក់នៅផ្ទះលុះដល់ម៉ោងប្រហែល៤,០០នាទីទាបភ្លឺ ចូលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពេល ខ្ញុំកំពង់សម្រាកក៏មានសមត្ថកិច្ចបានទូរសព្ទ័ប្រាប់ខ្ញុំថា ក្រុមហ៊ុនរបស់ខ្ញុំត្រូវមានចោរលួចគាស់ទ្វា ពេលនោះខ្ញុំក៏បាននមកមើល ទើបទឹងថាបាត់ទូរដែកចំនួន១ ហើយក្នុងទូរដែកនេះ មានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវ ភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្គេនចំនួន១ផងដែរ នៅក្នុងរឿងនេះខ្ញុំសុំទាមទារប្រាក់ដែលបានបាត់បង់ទៅសរុបចំនួន ៥០,០០០$ លុយខ្មែរចំនួន ២,០០០,០០០រៀល ព្រមទាំងឯកសារផ្សេងៗទៀត ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ នៅពេលសវនាថា : កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្ញុំបាន ចេញពីក្រុមហ៊ុនត្រលប់ទៅផ្ទះសម្រាក ហើយខ្ញុំបានចាក់សោរទ្វាត្រឹមត្រូវលុះទាមភ្លឺថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ប្រធានក្រុមហ៊ុនរបស់ខ្ញុំបានទូរសព្ទ័មកប្រាប់ខ្ញុំថា នៅក្រុមហ៊ុនមានចោរ ចូលគាស់ទ្វា ពេលនោះខ្ញុំក៏ប្រញាប់មកក្រុមហ៊ុន ទើបដឹងថាចោរបានលួចយកទូរដែក១នៅ ក្នុងបន្ទប់របស់ប្រធានក្រុមហ៊ុន ។

-តំណាងយ្យការធ្វើសេចក្តីសន្និដ្ឋានថាៈ ក្រោយពីបានសួរដេញដោលចប់សព្វគ្រប់ឃើញថា ជនជាប់ឈ្មោះ ,ឈ្មោះ និងឈ្មោះ បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានលួចគាស់ទ្វាក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជដោយលួចបានទូរដែកចំនួន១ ហើយនៅក្នុងទូរដែកនេះមានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្គេនចំនួន១ផងដែរ រួចហើយពួកខ្លួនក៏បានយកលុយទៅចែកគ្នាអស់ ចំណែកឯកសារផ្សេងៗពួកគេបានយកទៅបោះចោលអស់ ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ទុក នៅដដែល ដោយជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ និងឈ្មោះ

ពីបទ លួចមានស្ថានទម្ងន់ទោស សមគំនិតក្នុងអំពើលួច ដោយសារការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទូលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩និងមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ចំណែកឈ្មោះ ត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទូលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ និងឈ្មោះ បានធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិថា ៖ កូនក្តីរបស់ខ្ញុំបានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលថាខ្លួនពិតជាបានលួចគាស់ទ្វាក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជពិតប្រាកដមែនដូច្នេះសុំឲ្យលោកប្រធានក្រុមប្រឹក្សា មេត្តាជួយសម្រាលទោសឲ្យកូនក្តីខ្ញុំដោយអនុគ្រោះចំណែកខ្ញុំឈ្មោះ ខ្លួនមិនបានដឹងអីទេសូមឲ្យលោកប្រធានក្រុមហ៊ុនមេត្តាលើកលែងឲ្យកូនក្តីខ្ញុំរួចខ្លួនពីបទចោទ ។

*-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ*

*-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ*

*-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ*

*-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានាក្នុងសំណុំរឿង*

*-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ*

*-ក្រោយពីក្រុមប្រឹក្សាបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ*

**សាលាដំបូងរាជធានីភ្នំពេញ**

**យល់ឃើញថា**

១/តាមរបាយការណ៍សំយោគលេខ២០៩ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អធិការរដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា៖ ផ្អែកតាមរបាយការណ៍នគរបាលប៉ុស្តិ៍ តាមពាក្យបណ្តឹងរបស់ជនរងគ្រោះ និងតាមចម្លើយសារភាពរបស់ជនជាប់ចោទឃើញថាឈ្មោះ និងឈ្មោះ ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស (គាស់សោទ្វាក្រុមហ៊ុនលួចទូដែក) កាលពីវេលាម៉ោង៣,១៥នាទី រំលងអាធ្រាតឈានចូលថ្ងៃ ទី៩ ខែតុលា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនទេសចរណ៍ និងពាណិជ្ជដែលមានទីតាំងស្ថិតនៅផ្ទះលេខ៤១BE០ ផ្លូវ៣៦៨ ក្រុម១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រាកដមែនចំណែកជនជាប់ចោទឈ្មោះ ពិតជាបានសមគំនិត ផ្តល់មធ្យោបាយធ្វើសកម្មភាព និងទទួលផលចោលរកម្មក្នុងករណីនេះប្រាកដមែនរីឯជនជាប់ឈ្មោះ ដែលជាប្រពន្ធរបស់ជនជាប់ចោទឈ្មោះ ក៏ជាអ្នកទទួលផលចោរកម្មក្នុងករណីខាងលើនេះដែរ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា៖ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទីខ្លួនពិតជាបានធ្វើសកម្មភាពគាស់ទ្វាក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃដោយលួចបានទូរដែកប្រាកដមែន ។ មុនដំបូងឈ្មោះ បានយកម៉ូតូមួយ គ្រឿងម៉ាកសេ១០០កូរ៉េផ្លើលពណ៌ក្រហមគ្មានស្លាកលេខពីឈ្មោះ ( ) មកតកន្ទុយរ៉ឺម៉កខ្លួនបានដឹកបក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ ។ ពេលខ្លួនធ្វើដំណើរមកដល់ទួលស្វាយព្រៃក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោនៅខាងក្រៅ ពេលនោះពួកខ្លួនក៏បានឈប់ម៉ូតូហើយក៏បានយកទូឡឺវីសមកគ្នឹះសោសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ គ្នឹះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុង ក្រុមហ៊ុនរើកកាយនិងលួចយកបានទូរដែក១នៅជាន់ខាងលើហើយក៏នាំគ្នាដឹកតាមរ៉ឺម៉កទៅ ផ្ទះរបស់ឈ្មោះ ដើម្បីគាស់បានឃើញលុយជាច្រើន និងឯកសារផ្សេងទៀត រួចហើយបានចែកលុយគ្នាខ្លួនទទួលបានប្រាំពាន់ដុល្លាអាមេរិក រីឯឯកសារទាំងនោះត្រូវបានដុតចោល បន្ទាប់មកខ្លួនយកលុយចំនួន៤ពាន់

ដុល្លារអាមេរិក ទៅផ្ញើនិងឈ្មោះ នៅសល់ប៉ុន្មានខ្លួនបានយកទៅចាយវាយ និងចែកអ្នកជិតខាងនៅស្វាយរៀង លុះដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣,០០នាទីរសៀលពេលដែលខ្លួនកំពុងអង្គុយលេង ជាមួយឈ្មោះ និងឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមក ឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

៣/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា: កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ ខ្លួនពិតជាបានយកម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះ របស់គេលួចទូរដែកប្រាក់ដ៏មែន ។ មុនដំបូងនៅល្ងាចថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ឈ្មោះ បានឲ្យទូរសព្ទមកខ្លួនឲ្យយកទៅគេនៅមុំច្បារអំពៅ ពេលនោះក៏បានជិះម៉ូតូម៉ាក សងសេ១០០ កូរ៉េធ្លើសពណ៌ក្រមគ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូខ្លួនជិះរួច ខ្លួនក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញ មូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរ គឺម៉ូតូរបស់ខ្លួនមានប្រដាប់សន្តោងរ៉ឺម៉កស្រាប់ ។ លុះព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៧,០០នាទីឈ្មោះ បានទូរសព្ទប្រាប់ខ្លួនថាឲ្យមកយកម៉ូតូ និង បានឲ្យលុយខ្លួនចំនួន១លានរៀល ។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោង ប្រហែល១៣,០០នាទី ខ្លួនក៏បានជិះម៉ូតូមកអង្គុយ លេងជាមួយឈ្មោះ និងឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនជាមួយឈ្មោះ នាំមកតែ ម្តង ចំណែកឈ្មោះ បាន រត់គេចខ្លួនបាត់ ។

៤/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា: ខ្លួនពិតជាបានចូលរួម គាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ក្នុងនេះមានឈ្មោះ ឈ្មោះ , ឈ្មោះ ...,ឈ្មោះ .. ហៅ ..។ ពេលនោះពួកខ្លួនលួចបានទូដែក១ យកទៅបើកនៅ ផ្ទះខ្លួន ក្នុងនោះមានលុយចំនួន៥០,០០០$ រួចហើយក៏បានចែកគ្នា ដោយខ្លួនបានចំនួន ១០,០០០$ លុះ សល់ពីនោះទុកឲ្យបក្សពួក៤នាក់ទៀតចែកគ្នា ចំណែកទូរដែកនេះបាន បោះចោល ជាមួយឯកសារនៅក្បែរវត្តច្បារអំពៅ ។

៥/តាមចម្លើយបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឆ្លើយថា: កាលពី ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ខ្លួនបានចេញពីក្រុមហ៊ុនដែលមានទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅ សម្រាក់នៅផ្ទះលុះដល់ម៉ោងប្រហែល៤,០០នាទីទាបភ្លឺ ចូលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពេលខ្លួនកំពុងសម្រាកក៏មានសមត្ថកិច្ចបានទូរសព្ទប្រាប់ថា ក្រុមហ៊ុនរបស់ខ្លួនត្រូវមាន ចោរលួចគាស់ទ្វា ពេលនោះខ្លួនក៏បានមកមើល ទើបទឹងថាបាត់ទូរដែកចំនួន១ ហើយ ក្នុងទូរដែកនេះ មានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ ដីមួយចំនួន , សៀវ ភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ ។

៦/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ,ឈ្មោះ , ឈ្មោះ

បានឆ្លើយស៊ីសង្វាក់ទៅនឹងចម្លើយរបស់បណ្តឹងរដ្ឋប្បវេណី , ចម្លើយសាក្សីនិង ភស្តុ តាងនានានៅក្នុងសំណុំរឿងថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើលួចគាស់ទ្វា ក្រុមហ៊ុនស៊ី ហ្គោលទេសចរណ៍ និងពាណិជ្ជ ពិតប្រាកដមែន ។

៧/ជនជាប់ចោទមានស្មារតីល្អនៅពេលប្រព្រឹត្តបទល្មើស អំពើប្រព្រឹត្តរបស់ជន ជាប់ជាប់ចោទឈ្មោះ , ឈ្មោះ ពី , ឈ្មោះ , និងឈ្មោះ

បានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសណ្តាប់ធ្នាប់សង្គមយ៉ាង

ធ្ងន់ធ្ងរដែលដែលធ្វើឲ្យបាត់បង់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ និងផ្ទុយទៅនិងច្បាប់កំណត់ ។

៨/ជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ ជាអនីតិជនតុលាការគប្បីពិចារណាពីស្ថានសម្រាល ។

៩/តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

១០/មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្ដន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ , ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រ ព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្ដន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្ដន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

១១/វត្ថុចាប់យកមាន:

១១.១/ម៉ូតូមួយគ្រឿងម៉ាក CITY Pluo ពណ៌ក្រហមគ្មានស្លាកលេខ។ម៉ាស៊ីន ០១៧៤៤៦ (ម៉ូតូចាស់មានកែត្ប) និង អង្គចងចាំចំនួន១ គប្បីប្រគល់ឲ្យម្ចាស់ដើមវិញ ។

១១.២/ញញួរចំនួន២ , ដែកដាប់ចំនួន៣ , ដែកគាស់ចំនួន១ , កន្ត្រៃចំនួន១ , កូនកាំបិតចំនួន២ , កាំបិតតាំងតោចំនួន៤ , ដាវចំនួន១ និងដបសម្រាប់ដាក់គ្រឿងញៀនចំនួន១តុលាការគប្បីសម្រេចរឹបអូស ។

១២/ដើមបណ្ដឹងសុំទាមទារសំណង ជាប្រាក់ដែលបានបាត់បង់ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ,លុយខ្មែរចំនួន២,០០០,០០០រៀល (ពីរលានរៀល) និងសម្ភារៈដែល បានបាត់បង់ជាឯកសារ តុលាការគប្បីសម្រេចតាមច្បាប់ ។

**ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ**

**វិនិច្ឆ័យសេចក្ដី**

១/ផ្ដន្ទាទោស:

១.១/ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរដាក់ពន្ធនាគារកំណត់រយៈ០២ឆ្នាំ (ពីរឆ្នាំ) និងឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈពេល០៤ឆ្នាំ (បួនឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១សង្កាត់ ទួលស្វាយព្រៃ

១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១.២/ផ្តន្ទាទោសលើឈ្មោះ ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០២ឆ្នាំ (ពីរឆ្នាំ) ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១.៣/ផ្តន្ទាទោសលើឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាងគារកំណត់តយៈពេល ០៣ឆ្នាំ (បីឆ្នាំ) ពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

២/វត្ថុចាប់យកមាន:

២.១/ម៉ូតូមួយគ្រឿងម៉ាក CITY Pluo ពណ៌ក្រហមគ្មានស្លាកលេខ ម៉ាស៊ីន០១៧៤៤៦ (ម៉ូតូចាស់មានកែត្ស) និង អង្គចងចាំចំនួន១ ប្រគល់ឲ្យម្ចាស់ដើមវិញ ។

២.២/ញញួរចំនួន២ , ដែកដាប់ចំនួន៣ , ដែកគាស់ចំនួន១ , កន្ត្រៃចំនួន១ , កូនកាំបិតចំនួន២ , កាំបិតតាំងតោចំនួន៤ , ដាវចំនួន១ និងដបសម្រាប់ដក់គ្រឿងញៀនចំនួន១រឹបអូស ។

៣/បង្គាប់ឲ្យឈ្មោះ , ឈ្មោះ ,ឈ្មោះ និងឈ្មោះ រួមគ្នាសងសំណាងដែលបានបាត់បង់ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចំនួន៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) , លុយខ្មែរចំនួន ២,០០០,០០០រៀល (ពីរលានរៀល) និងសម្ភារៈ ដែល បានបាត់បង់ជាឯកសារ ទាមទារលើសពីនេះបដិសេធន៍ចោល ។

៤/បង្គាប់ឲ្យចេញដីកាចាប់នឹងឃុំខ្លួនឈ្មោះ ដើម្បីអនុវត្តទោសតាមអំណាចសាលក្រមតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ខែមេសា ឆ្នាំ ២០១៦ចំពោះមុខជនជាប់ចោទឈ្មោះ , ឈ្មោះ និងឈ្មោះ កំបាំងមុខជនជាប់ចោទឈ្មោះ និងដើមបណ្តឹងរដ្ឋប្បវេណីទុកសិទ្ធិប្តឹងទាស់ និងបើផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញ ថ្ងៃទី២២ខែមេសា ឆ្នាំ២០១៦
ក្រឡាបញ្ជី

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៧២

ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩

សាលដីកា

លេខ: ២១១

ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម ៖

១-ឯកឧត្តម ជាប្រធាន

២-លោក ជាចៅក្រម

៣-លោក ជាចៅក្រម

៤-លោក ជាចៅក្រម

៥-លោក ជាចៅក្រម

ក្រឡាបញ្ជី

លោក

តំណាងមហាអយ្យការ

លោក ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៦៥"ច" ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៧២ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ របស់តុលាការកំពូល។

<u>ពីបទ</u>៖ ចោរកម្ម និងសមគំនិតក្នុងអំពើចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៨។ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៨៣ ,៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-ជនជាប់ចោទ :

១-ឈ្មោះ ភេទប្រុស <u>អាយុ១៧ឆ្នាំ</u> កើតនៅសង្កាត់លេខ៣ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេខ២០៨$E_3$ ផ្លូវ១០៧ សង្កាត់អូរឫស្សីទី៤ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយ ឈ្មោះ (រ) ទោសពីមុនគ្មាន។ ឃុំខ្លួននៅពន្ធនាគារព្រៃស (ម$_២$)។ ក្រៅឃុំ។

២-ឈ្មោះ ភេទប្រុស អាយុ១៩ឆ្នាំ កើតនៅសង្កាត់លេខ៣ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៥៤ ផ្លូវ១១១ សង្កាត់អូរស្សីទី១ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ទោសពីមុនគ្មាន។ ឃុំខ្លួនពន្ធនាគារ ម$_១$។ ក្រៅឃុំ។

៣-ឈ្មោះ "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤៥ឆ្នាំ កើតនៅភូមិត្រពាំងសាប ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ទីលំនៅសព្វថ្ងៃផ្ទះលេខ២០៨E₃ ផ្លូវ១០៧ ក្រុម៤៥ សង្កាត់អូរឫស្សីទី៤ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (ស) មានកូន០៤នាក់។ ទោសពីមុនគ្មាន។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ២AE₃ ផ្លូវ១២៥ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា ក្រុងភ្នំពេញ។

-តាមកំណត់ហេតុបណ្តឹង ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះ បញ្ជាក់ថាខ្លួនសុំប្តឹងករណីចោរចូលលួចសំភារៈក្នុងផ្ទះ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៤ នៅម៉ោង១ ទៅ៥ភ្លឺ។ សំភារៈបាត់រួមមាន : ១-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ,២-កាតបោះឆ្នោត ,៣-ទូរស័ព្ទម៉ាក NOKIA រូបថតប្តី ,រូបថតកូនប្រុស រូបថតកូនស្រី ,លុយចំនួន១.១៦០$ ,មាសគ្រឿង០៤តំឡឹងមាស។

-បានសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖

-ចោទប្រកាន់លើ :

ក-ឈ្មោះ ភេទប្រុស <u>អាយុ១៧ឆ្នាំ</u> ពីបទ ចោរកម្ម (លួចលុយ) ប្រព្រឹត្តនៅសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា ក្រុងភ្នំពេញ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា៤៣។

ខ-ឈ្មោះ និងឈ្មោះ ពីបទ សមគំនិតក្នុងអំពើលួចលុយ ប្រព្រឹត្តនៅសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា ក្រុងភ្នំពេញ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៤ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤៨"ដ" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច៖

១-ផ្តន្ទាទោសលើ :

ក-ឈ្មោះ ភេទប្រុស <u>អាយុ១៧ឆ្នាំ</u> ដាក់ពន្ធនាគារកំណត់រយៈពេល០១ឆ្នាំ (មួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ ពីបទ ចោរកម្ម ប្រព្រឹត្តនៅសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា ក្រុងភ្នំពេញ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៤ តាមបញ្ញត្តិមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ខ-ឈ្មោះ ភេទប្រុស អាយុ១៩ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈ០១ឆ្នាំ (មួយឆ្នាំ) គិតពីឃុំខ្លួន ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៤ ពីបទ សមគំនិតក្នុងអំពើចោរកម្ម ប្រព្រឹត្តនៅសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា ក្រុងភ្នំពេញ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៤ តាមបញ្ញត្តិមាត្រា៤៣ និង៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-ឲ្យឈ្មោះ ភេទប្រុស អាយុ៤៥ឆ្នាំ រួចផុតពីការចោទប្រកាន់ ពីបទ សមគំនិតក្នុងអំពើចោរកម្ម ប្រព្រឹត្តនៅសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា ក្រុងភ្នំពេញ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៤ តាមបញ្ញត្តិមាត្រា៤៣ និង៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣-ឲ្យឈ្មោះ និងឈ្មោះ រួមគ្នាសងសំណងការខូចខាតនូវទឹកប្រាក់ចំនួន១.១៦០ដុល្លារអាមេរិក ,១០០$ ថ្លៃទូរស័ព្ទដៃ ,១០០$ ថ្លៃក្រវិលមួយគូ និងមាសចំនួន ៥ជំឡឹង ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ពេលសាលក្រមចូលជាស្ថាពរ ការទាមទារ

លើសពីនេះ បដិសេធចោល។ ក្នុងករណីឈ្មោះ មិនព្រមយកប្រាក់មកសងទេត្រូវដាក់គុកបង្ខំរូបកាយដើម្បីទារប្រាក់ធនទណ្ឌ ការដាក់គុកនេះតាមមាត្រា៧,១០ នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ។

ក្នុងករណីឈ្មោះ និងអ្នកស្រី ... ត្រូវជាឪពុកម្តាយឈ្មោះ ជាអាណាព្យាបាលដោយផ្ទាល់ មុនប្រព្រឹត្តបទល្មើសទទួលបន្ទុកចេញសងជំនួស បើគ្មានប្រាក់ចេញសងជំនួសទេ ត្រូវរឹបអូសទ្រព្យសម្បត្តិដែលមានលក់ សងតាមបញ្ញត្តិមាត្រា១២៤ នៃក្រឹត្យច្បាប់លេខ៣៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា។

៤-សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទឈ្មោះ ,ឈ្មោះ ,ឈ្មោះ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងរយៈពេល០២ខែ ដោយគិតចាប់តាំងពីថ្ងៃប្រកាសសាលក្រមតទៅ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឈ្មោះ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៨៤"ដ" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: តាមអង្គហេតុនិងចម្លើយ ជនជាប់ចោទឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញាមែនហេតុនេះ សុំឲ្យតម្កល់សាលក្រមដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៦៥"ច" ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់ឈ្មោះ ... ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៤ "ដ" ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការដដែល។

៣-សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ១៩៣ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ឈ្មោះ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៦៥"ច" ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា:

អាស្រ័យដូចបានជំរាបខាងលើដើម្បីការពារផលប្រយោជន៍ច្បាប់ និងផលប្រយោជន៍យុត្តិធម៌ចំពោះជនរងគ្រោះ ចំពោះសំណុំរឿងព្រហ្មទណ្ឌនេះតំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោមៈ

-បដិសេធចោលបណ្តឹងសាទុក្ខរបស់ឈ្មោះ ចាត់ទុកថាខុសនឹង គតិច្បាប់។

-តំកល់សាលដីការបស់សភាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

-បានស្តាប់ប្រធានសួរសារពាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ : នាពេលសវនាការថាៈខ្ញុំប្តឹងសាទុក្ខមកនេះគឺ សាលាឧទ្ធរណ៍ឲ្យខ្ញុំសងគេច្រើនហួសហេតុពេកខ្ញុំសូមសងម្នាក់២០០ដុល្លា តែគេឲ្យខ្ញុំសង១០០០ដុល្លាគឺវាច្រើនពេកគ្រាន់តែខ្ញុំដឹងថាក្នុងហោប៉ៅកូនខ្ញុំមានលុយបន្តិចបន្តួច ហើយគេប្រាប់ខ្ញុំថាក្នុងហោប៉ៅខោកូនតាឯងមានលុយច្រើនណាស់រឿងនេះខ្ញុំអត់ដឹងទេ។

សំណូមពរៈ សំណងខ្ញុំសូមសងតែ២០០ដុល្លា តាមលទ្ធភាពខ្ញុំ។

ខ្ញុំទទួលស្គាល់ព្រោះកូនខ្ញុំរធ្វើបាបខ្ញុំជាឪពុក។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៩៣ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ឈ្មោះ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៨ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា តាមចម្លើយរបស់ម្ចាស់បណ្តឹងសាទុក្ខឈ្មោះ នៅចំពោះមុខសវនាការតុលាការកំពូលថា បណ្តឹងសាទុក្ខរបស់ខ្លួន ធ្វើឡើងតែលើផ្នែកសំណងរដ្ឋប្បវេណីតែប៉ុណ្ណោះ ខ្លួនពុំមានលទ្ធភាពសងតាមការសំរេចរបស់សាលាឧទ្ធរណ៍ ទេដោយហេតុថាខ្លួនមានមុខរបររកស៊ីជាអ្នកសំលៀងកាំបិត ខ្លួនសុំសងត្រឹមតែ២០០ USD ប៉ុណ្ណោះ ការសុំនេះតុលាការកំពូលពុំអាចសំរេចតាមបានទេ ដោយព្យុះសនកម្ម នៃអំពើល្មើសមានទំហំធំ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌ៦៥"ច" ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី

១-បដិសេធបណ្តឹងសាទុក្ខលេខ១៩៣ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ឈ្មោះ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៦៥"ច" ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ទាំងមូល។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|

---

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២

ក្រឡាបញ្ជី

បានឃើញ

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២

ជ.ប្រធានតុលាការកំពូល

អនុប្រធាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ១៨១
ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩
សាលដីកា
លេខៈ ២៦៧
ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម ៖

| | |
|---|---|
| ១-ឯកឧត្តម | ជាប្រធាន |
| ២-លោកស្រី | ជាចៅក្រម |
| ៣-លោក | ជាចៅក្រម |
| ៤-លោក | ជាចៅក្រម |
| ៥-លោក | ជាចៅក្រម |

ក្រឡាបញ្ជី

លោក

តំណាងមហាអយ្យការ

លោក ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៤៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ របស់តុលាការកំពូល។

ពីបទ: នាំពង្រត់ និងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ឃុំកំពង់ស្វាយ ស្រុកសិរីសៅភ័ណ្ឌ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៧។ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីបង្ក្រាប់អំពើនាំពង្រត់ លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស និងមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ។

-ជនជាប់ចោទឈ្មោះ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ទីលំនៅសព្វថ្ងៃនៅភូមិ៣ ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មុខរបររកស៊ីគ្មាន ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "រ" ទោសពីមុនគ្មាន។

-មានមេធាវីលោក និង

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ "ម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤២ឆ្នាំ ទីលំនៅសព្វថ្ងៃនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មុខរបរមេផ្ទះទូរស័ព្ទលេខ០១២ ៧០១ ៧១៨ (ត្រូវជាម្តាយជនរងគ្រោះ)។

-ជនរងគ្រោះឈ្មោះ ភេទស្រី អាយុ១៨ឆ្នាំ មុខរបរសិស្ស។

-តាមពាក្យបណ្តឹងចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ឈ្មោះ ថាកាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង១៣:០០នាទី នាងខ្ញុំទើបតែមកពីផ្សារ ចូលផ្ទះភ្លាមក៏លឺស្វរ ខ្វរជញ្ជាំងក្តារកន្លែងបន្ទប់កូនស្រីរបស់ខ្លួនឈ្មោះ អាយុ១៨ឆ្នាំ លឺដូច្នេះខ្លួនក៏ចូលទៅមើលក្នុងបន្ទប់កូនស្រីរបស់ខ្លួនៗឃើញស្នាមជើងឡើងលើពិដាន ខ្លួនឡើងតាមមើលក៏ឃើញឈ្មោះ ភេទប្រុស អាយុ១៦ឆ្នាំ នៅពួនលើពិដានផ្ទះក្នុងសភាពអាក្រាត ខ្លួនក៏បណ្តេញចេញពីផ្ទះ។ ក្រោយបន្តិចមកខ្លួនទៅផ្សារលុះម៉ោង៣:០០នាទីរសៀល ខ្លួនក៏ត្រលប់មកផ្ទះវិញ ក៏ស្រាប់តែបាត់កូនស្រីនាងខ្ញុំរហូតដល់សព្វថ្ងៃនេះ។

-បានឃើញដីកាសម្រេចលើកលែងចោទប្រកាន់លេខ៣៥៧ ដសលច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេចៈ

១-លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩១ ជាតិខ្មែរ កើតនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិ៣ ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មុខរបរនៅផ្ទះ នៅលីវ ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "រ" ទោសពីមុនគ្មាន ពីបទរំលោភសេពសន្ថវៈ និងនាំព្រាត់មនុស្ស ប្រព្រឹត្តនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៧ តាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើនាំពង្រត់លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស។

២-ឲ្យឈ្មោះខាងលើមានសេរីភាពឡើងវិញ ប្រសិនបើឈ្មោះនេះ មិនត្រូវបានចោទប្រកាន់ពីបទល្មើសអ្វីផ្សេងទៀត។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះ ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចលើកលែងចោទប្រកាន់លេខ៣៥៧ ដសលច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ គ្រប់ចំនុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈគួរគប្បីឲ្យរួចពីការចោទប្រកាន់ និងសុំឲ្យតម្កល់ដីកាលើកលែងចោទប្រកាន់ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៤៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចៈ

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់លេខ៣៥៧ ដសលច ចុះថ្ងៃទី១០ ខែកក្កដាឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះប្រកាសនាពេលសវនាការអសាធារណៈនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨។ បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ១៧២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៤៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា:

-ទទួលបណ្តឹងសាទុក្ខលេខ១៧២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៤៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តា ពិនិត្យនិងសំរេចតាមច្បាប់។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ការពារជនជាប់ចោទឈ្មោះ នាពេលសវនាការថាៈកូនក្តីខ្ញុំជាមួយ ពិតជាស្រលាញ់គ្នាពិតប្រាកដគ្មានការរំលោភទេ ព្រោះ បានឆ្លើយថានាងខ្ញុំ និង បានស្រលាញ់គ្នាយូរហើយ កូនក្តីខ្ញុំជាមួយនាង បានស្រលាញ់គ្នាតាំងពីឆ្នាំ២០០៦ តែដោយសាកាបង្កាប់លុយក្នុងការរៀបកា ខាងស្រីបានឲ្យកូនក្តីខ្ញុំបង់លុយក្នុងការរៀបការច្រើនពេក តែកូនក្តីខ្ញុំមានតែ៥០០$ ទើបបានខាង ស្រីប្តឹងចោទថាកូនក្តីខ្ញុំចាប់រំលោភ។

សំណូមពរ: តម្កល់សាលដីការបស់សាលាឧទ្ធរណ៍។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៧២ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា តាមកំណត់ហេតុសួរចម្លើយចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨ របស់តុលាការខេត្តបន្ទាយមានជ័យ ក៏ដូចជានាពេលសវនាការនៅតុលាការអង្គសេចក្តីផងដែរ ឈ្មោះ និងឈ្មោះ បានឆ្លើយប្រាប់តុលាការថាពួកខ្លួនទាំងពីរនាក់បានស្រលាញ់គ្នាពិតប្រាកដមែនដោយគ្មានការបង្ខិតបង្ខំ ឬគំរាមកំហែងអ្វីឡើយ ហើយឪពុកម្តាយអ្នកទាំងពីរក៏បានដឹងឮថាអ្នកទាំងពីរបានស្រលាញ់គ្នាដែរ មូលហេតុដែលឈ្មោះ និងឈ្មោះ ព្រមព្រៀងគ្នារត់ចេញពីផ្ទះនោះដោយសារតែ ឪពុកម្តាយមិនព្រមរៀបការឲ្យពួកគេ ហើយសព្វថ្ងៃនេះអ្នកទាំងពីរកំពុងរស់នៅជាមួយគ្នាជាប្តីប្រពន្ធទៀតផង។ ដូច្នេះឃើញថាពុំមានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកក្នុងការចោទប្រកាន់លើជនជាប់ចោទពីបទ: នាំពង្រត់ និងរំលោភសេពសន្ថវៈដូចពាក្យបណ្តឹងចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ឈ្មោះ នោះទេ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៨៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចមកនេះ ត្រឹមត្រូវតាមគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-បដិសេធបណ្តឹងសាទុក្ខលេខ១៧២ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ

។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១៦ ខែវិច្ឆកា ឆ្នាំ២០១២ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២។

ប្រធាន ចៅក្រម ចៅក្រម ចៅក្រម ចៅក្រម ក្រឡាបញ្ជី

---

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ៦ ឆ្នាំ២០១២

**ក្រឡាបញ្ជី**

បានឃើញ

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ៦ ឆ្នាំ២០១២

**ជ.ប្រធានតុលាការកំពូល**

**អនុប្រធាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ២១៧
ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩
សាលដីកា
លេខ៖ ១៣៩
ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១២

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម ៖

១-ឯកឧត្តម ជាប្រធាន
២-លោក ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោក ជាចៅក្រម

ក្រឡាបញ្ជី
លោក

តំណាងមហាអយ្យការ
លោក ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ០២"គ" ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ របស់តុលាការកំពូល។

ពីបទ៖ ប្លន់ (លួចគ្នាច្រើន) ប្រព្រឹត្តនៅខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

១-ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់បឹងសាឡាង ខណ្ឌទួលគោក ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិត្នោត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ទោសពីមុនគ្មាន។ ឃុំខ្លួន ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧។

២-ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិត្នោត សង្កាត់ ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិត្នោត ផ្លូវលំ ក្រុមទី១៤ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ទោសពីមុនគ្មាន។ ឃុំខ្លួន ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៧។

៣-ជនជាប់ចោទឈ្មោះ "ម្ចាស់បណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ ១៨ឆ្នាំ កើតនៅស្រុកកៀនស្វាយ ខេត្តកណ្ដាល សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិត្នោត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ មុខរបរមិនពិតប្រាកដ នៅលីវ ឪពុកឈ្មោះ កក្កដា (ស) ម្ដាយឈ្មោះ (រ) ទោសពីមុនគ្មាន។ ឃុំខ្លួន ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧។

-មេធាវី : លោក

កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៣ វេលាម៉ោងមិនចាំ នៅចំណុចភូមិព្រៃកទាល់ សង្កាត់ ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ មានករណីប្លន់ (លួចគ្នាច្រើន) មួយបានកើតឡើង ដែលប្រព្រឹត្តដោយឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ,ឈ្មោះ ភេទប្រុស អាយុ១៦ឆ្នាំ ,ឈ្មោះ ភេទប្រុស អាយុ១៣ឆ្នាំ និងឈ្មោះ បាននាំគ្នាលួចគាស់ផ្ទះមួយកន្លែងស្ថិតនៅក្នុងភូមិ ព្រៃកទាល់ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ពេលដែលម្ចាស់ផ្ទះមិននៅ ហើយលួចបានលុយចំនួន១២ដុល្លាអាមេរិក ,ស្បែកជើង២គូ ,ខោចំនួន២ និងអាវចំនួន២ រួចក៏បាននាំគ្នារត់គេចខ្លួនបាត់តែម្ដង បន្ទាប់មកទើបសមត្ថកិច្ចឃាត់ខ្លួនបញ្ជូនមកតុលាការ។

-បានឃើញសេចក្ដីសន្និដ្ឋានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា៖

ចោទប្រកាន់លើឈ្មោះ :

១- ភេទប្រុស អាយុ១៨ឆ្នាំ

២-ឈ្មោះ ភេទប្រុស អាយុ១៦ឆ្នាំ

៣-ឈ្មោះ ភេទប្រុស អាយុ១៣ឆ្នាំ

ពីបទ ប្លន់ (លួចគាស់ផ្ទះ) ប្រព្រឹត្តនៅភូមិព្រៃកទាល់ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៣ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៩១ "ឍ" ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច៖

១-ក.ផ្ដន្ទាទោសលើឈ្មោះ ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុ១៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល២ឆ្នាំ ៦ខែ (ពីរឆ្នាំប្រាំមួយខែ) អនុវត្ត ទោសបន្តពីសាលក្រមលេខ១០១ "ឍ" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ តទៅ។

ខ.ផ្ដន្ទាទោសលើឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល៥ឆ្នាំ (ប្រាំឆ្នាំ) អនុវត្តទោសបន្តពីសាលក្រមលេខ១០១ "ឍ" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៤។

អ្នកទាំងបីនាក់ ខាងលើជាប់ចោទពីបទប្លន់ (លួចគាស់ផ្ទះ) ប្រព្រឹត្តនៅខណ្ឌមានជ័យ ក្រុងភ្នំពេញ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៣ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារ។

២-សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ សំរេចបើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤២៤ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧ របស់ឈ្មោះ ប្តឹងមិនសុខចិត្តនឹង សាលក្រមព្រហ្មទណ្ឌលេខ៩១ "ឈ" ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច (ខ) នៃសាលក្រមព្រហ្មទណ្ឌទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ ជនល្មើសបានទទួលស្គាល់ អំពីសកម្មភាពរបស់ខ្លួនហើយ សុំតម្កល់សាលក្រមរបស់តុលាការថ្នាក់ក្រោមទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០២"គ" ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចៈ

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៤២៤ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧ របស់ជនជាប់ចោទឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៩១ "ឈ" ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ របស់ សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣-បង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទបន្តទៀត។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទ ,មេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ ចំពោះមុខមេធាវីការពារជនជាប់ចោទ ,កំបាំងមុខជនជាប់ចោទ និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៨៤ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ឈ្មោះ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០២"គ" ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថាៈ

-មានភស្តុតាង ច្បាស់លាស់ និងគ្រប់គ្រាន់បញ្ជាក់ពីបទល្មើសប្លន់ក្នុងទំនាស់ខាងលើនេះ។

-ការប្តឹងចោទប្រកាន់ដើមបណ្តឹងរដ្ឋប្បវេណីគឺមានភស្តុតាងសម្រាប់ដាក់បន្ទុកលើជនជាប់ចោទដូច្នេះបើពិនិត្យអំពីស្ថានភាពរបស់ជនជាប់ចោទ និងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌគឺមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទខាងលើពីបទប្លន់ ដែលតម្រូវឲ្យមានការចោទប្រកាន់ស្របតាមក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ។

អាស្រ័យដូចបានជំរាបជូនខាងលើ ដើម្បីការពារផលប្រយោជន៍ច្បាប់ និងផលប្រយោជន៍យុត្តិធម៌ចំពោះជនរងគ្រោះ ចំពោះសំណុំរឿងព្រហ្មទណ្ឌនេះតំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចដូចខាងក្រោមៈ

+បដិសេធបណ្តឹងសាទុក្ខចោល ដោយចាត់ទុកថា ខុសនឹងគតិច្បាប់

+តម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក គង់ ហេង មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ

នាពេលសវនាការថា: កូនក្តីខ្ញុំបាទបានអះអាងថាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៣ កូនក្តីខ្ញុំបាទមិនបានធ្វើសកម្មភាពជាមួយឈ្មោះ និងឈ្មោះ ទេ ហើយកូនក្តីខ្ញុំក៏បានសារភាពដែលថាគេបានប្រព្រឹត្តបទល្មើសម្តងដែរ តែមិនមែនដូចថ្ងៃខាងលើទេ ដូច្នេះការប្រព្រឹត្តរបស់កូនក្តីខ្ញុំជាលើកទីមួយគឺព្យុះសនកម្មតិចតួចណាស់ គឺមិនមានបទល្មើសកើតឡើងធំដុំដូចគេចោទប្រកាន់នោះទេ។

សំណូមពរ: សុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាបន្ធូរបន្ថយកូនក្តីខ្ញុំបាទឲ្យស្រាលជាទីបំផុត។

-បានស្តាប់តំណាងមហាអយ្យការតុលាការកំពូល គ្មានយោបល់អ្វីបន្ថែមទៀតទេ!

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់របស់មេធាវីការពារក្តីរបស់ជនត្រូវចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤៥ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ឈ្មោះ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះ ដែលជាម្ចាស់បណ្តឹងសាទុក្ខបានបដិសេធថាខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ការដោះសារនេះពុំមានភស្តុតាងបញ្ជាក់ទេ ផ្ទុយទៅវិញចម្លើយរបស់ឈ្មោះ នេះ នៅនគរបាល និងចម្លើយរបស់ជនត្រូវចោទម្នាក់ទៀតឈ្មោះ ថាខ្លួនរួមជាមួយឈ្មោះ និងឈ្មោះ ឈ្មោះ បានធ្វើសកម្មភាពគាស់ផ្ទះរបស់គេយកសម្ភារៈប្រាក់ដមែន។ ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ពីបទ: ប្លន់តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-យល់ឃើញថា ដោយក្រមព្រហ្មទណ្ឌបានចូលជាធរមាន អង្គហេតុនេះត្រូវបានកំណត់ជាបទលួច តាមមាត្រា៣៥៧ ចំណុចទី២ ហើយទណ្ឌកម្មមានលក្ខណៈស្រាលជាង ដូចនេះគប្បីតុលាការអនុវត្តតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះ អះអាងថាខ្លួនមានអាយុ១៦ឆ្នាំ ប៉ុន្តែពុំមានភស្តុតាងដូចជាសំបុត្រកំណើត,សៀវភៅគ្រួសារជាដើមបញ្ជាក់ទេ ផ្ទុយទៅវិញចម្លើយរបស់ឈ្មោះនេះនៅចៅក្រមស៊ើបសួរថាខ្លួនមានអាយុ១៨ឆ្នាំ។

-យល់ឃើញថា មហាអយ្យការអមតុលាការកំពូលបានកោះហៅត្រឹមត្រូវតាមនិតិវិធីក៏ប៉ុន្តែជនត្រូវចោទពុំចូលខ្លួន តុលាការកំពូលគប្បីលើកយករឿងក្តីនេះមកជំនុំជម្រះ។

-យល់ឃើញថា សាលដីកាសភាព្រហ្មទណ្ឌ លេខ០២ "គ" ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ លើកលែងតែទណ្ឌកម្ម។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី

១-ទទួល បណ្តឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌ លេខ០២ "គ" ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែទណ្ឌកម្មត្រូវបដិសេធចោល។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ២១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះសាជាថ្មីឡើងវិញ លើចំណុចទណ្ឌកម្ម។

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១២។

ប្រធាន ចៅក្រម ចៅក្រម ចៅក្រម ចៅក្រម ក្រឡាបញ្ជី

---

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។
រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១២
ក្រឡាបញ្ជី

បានឃើញ
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១២
ជ-ប្រធានតុលាការកំពូល
អនុប្រធាន